ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

រាជធានីភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០២០

# មាតិកា


មាតិកា ..... i

បញ្ជីតារាង ..... ii

អារម្ភកថា ..... iii

១. **សេចក្តីផ្តើម** ..... ១

១.១. សាវតារនៃវិស័យកសិ-ឧស្សាហកម្ម ..... ១

១.២. ការប្រឈម ..... ១

១.៣. កាលានុវត្តភាព ..... ២

២. **គោលការណ៍ និងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ** ..... ៣

២.១. គោលការណ៍ ..... ៣

២.២. ដំណើរការនៃការរៀបចំ ..... ៣

៣. **ទិសដៅយុទ្ធសាស្ត្រ** ..... ៤

៣.១. ចក្ខុវិស័យ ..... ៤

៣.២. បេសកកម្ម ..... ៤

៣.៣. គោលបំណង ..... ៤

៤. **ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ..... ៥

៤.១. វិសាលភាព ..... ៥

៤.២. គោលដៅយុទ្ធសាស្ត្រ ..... ៦

៤.៣. សកម្មភាពយុទ្ធសាស្ត្រ ..... ៦

៥. **ក្របខ័ណ្ឌហិរញ្ញប្បទាន** ..... ១៧

៦. **ការរៀបចំការអនុវត្ត** ..... ១៩

៧. **ហានិភ័យ និងការគ្រប់គ្រងហានិភ័យ** ..... ២០

៨. **ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ..... ២៣

៨.១. គោលបំណង ..... ២៣

៨.២. ឋានានុក្រម និងស្ថាប័នទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..... ២៣

៨.៣. ការប្រមូល ការគ្រប់គ្រង ការវិភាគព័ត៌មាន តាមដាននិងវាយតម្លៃ និងប្រព័ន្ធរាយការណ៍ ..... ២៤

៩. **សេចក្តីសន្និដ្ឋាន** ..... ២៨

ឧបសម្ព័ន្ធទី១÷ សាវតារកសិ-ឧស្សាហកម្មជាតិ ..... ៣១

ឧបសម្ព័ន្ធទី២÷ ផលិតកម្មកសិកម្មតាមកិច្ចសន្យា ..... ៥៩

ឧបសម្ព័ន្ធទី៣÷ អភិបាលកិច្ចសុវត្ថិភាពចំណីអាហារ ..... ៦២

ឧបសម្ព័ន្ធទី៤÷ បណ្តុំកសិ-ឧស្សាហកម្ម ..... ៦៤

ឧបសម្ព័ន្ធទី៥÷ ថ្នាលបណ្តុះកសិធុរកិច្ច ..... ៦៦

ឧបសម្ព័ន្ធទី៦÷ ការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកសិពាណិជ្ជកម្ម ..... ៦៨

# បញ្ជីតារាង


តារាងទី១. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)........................................៧

តារាងទី២. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)........................................៨

តារាងទី៣. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)........................................៩

តារាងទី៤. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)........................................ ១០

តារាងទី៥. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)........................................ ១១

តារាងទី៦. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)........................................ ១១

តារាងទី៧. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)........................................ ១៣

តារាងទី៨. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)........................................ ១៤

តារាងទី៩. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)........................................ ១៤

តារាងទី១០. គម្រោងគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០ (ដុល្លារអាមេរិក)........ ១៦

តារាងទី១១. ស្ថានភាពថវិកាទ្រទ្រង់ដំណាក់កាលទី១នៃផែនការយុទ្ធសាស្ត្រ (ដុល្លារអាមេរិក)........................ ១៨

តារាងទី១២. ហានិភ័យ និងការឆ្លើយតបចំពោះហានិភ័យ........................................................................ ២១

តារាងទី១៣. ប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ........................................................២៥

តារាងទី១៤. ការនាំចេញរបស់កម្ពុជាអំឡុងឆ្នាំ២០១០-២០១៨ (លានដុល្លារអាមេរិក)........................................ ៣៤

តារាងទី១៥. ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម (ចម្ងាយទៅកាន់ច្រកទ្វារព្រំដែន)........................................ ៣៦

តារាងទី១៦. ពិន្ទុភាពងាយស្រួលក្នុងការសម្រួលឡជីស្ទីក សរុប និងតាមលំដាប់........................................ ៣៦

# អារម្ភកថា

ប្រទេសកម្ពុជាបាននិងកំពុងផ្លាស់ប្តូរមុខមាត់ និងអភិវឌ្ឍជាលំដាប់ តាមរយៈការប្រកាន់យកនូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរីចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក។ នាពេលកន្លងមកនេះ វិស័យកសិកម្មបានដើរតួនាទីជាសសរស្តម្ភសេដ្ឋកិច្ចជាតិមួយដ៏សំខាន់ ដោយបានផ្គត់ផ្គង់ស្បៀង និងអាហារូបត្ថម្ភ បង្កើតការងារនៅតាមជនបទ ស្រូបទាញប្រាក់ចំណូលពីក្រៅប្រទេស និងជួយជ្រោមជ្រែងដល់ការអភិវឌ្ឍសសរស្តម្ភសេដ្ឋកិច្ចពីរផ្សេងទៀត គឺវិស័យឧស្សាហកម្ម និងសេវាកម្ម។

នាពេលកន្លងទៅ សន្តិសុខស្បៀងធ្លាប់ជាបញ្ហាចម្បងនៅក្នុងដំណើរការអភិវឌ្ឍជាតិ ប៉ុន្តែក្នុងអំឡុងជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានផលិតស្បៀងលើសពីសេចក្តីត្រូវការក្នុងស្រុក និងបាននាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានឆ្លងចូលដំណាក់កាលអភិវឌ្ឍន៍មួយទៀត ដែលទាមទារនូវចក្ខុវិស័យអភិវឌ្ឍន៍រយៈពេលវែង និងមានវិសាលភាពទូលាយជាងមុន។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានកំណត់គោលដៅអភិវឌ្ឍន៍ ដោយឈរលើមូលដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចដែលមានលក្ខណៈ ចីរភាព បរិយាប័ន្ន និងរឹងមាំ សំដៅលើកស្ទួយប្រទេសជាតិឱ្យក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីសក្តានុពលអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មដំណាក់កាលទី៤។

ក្នុងទិសដៅរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យនេះ វិស័យកសិកម្មនឹងត្រូវការពិពិធកម្មសកម្មភាពសេដ្ឋកិច្ចដែលផ្តល់តម្លៃបន្ថែមខ្ពស់ ដោយប្រើប្រាស់បច្ចេកវិជ្ជាទំនើប នវានុវត្តន៍ខ្ពស់ និងប្រកបដោយចីរភាព។ នេះមានន័យថា ការលើកស្ទួយ និងការពន្លឿនកិច្ចអភិវឌ្ឍន៍វិស័យកសិ-ធុរកិច្ច ឬនិយាយជារួមថាវិស័យកសិ-ឧស្សាហកម្ម បានក្លាយជាការងារអាទិភាព។ អាទិភាពការងារថ្មីនេះស្តែងឱ្យឃើញតាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០** ដែលផែនការនេះបានកើតចេញពីកិច្ចឧបត្ថម្ភគាំទ្រ និងឆ្លងកាត់ការពិគ្រោះយោបល់ពីសំណាក់ភាគីពាក់ព័ន្ធជាច្រើន រួមមាន ស្ថាប័នរដ្ឋ វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍កសិកម្មជាដើម។ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០** ដែលបានដាក់ចេញនាពេលនេះ នឹងជាមូលដ្ឋានគ្រឹះរឹងមាំមួយសម្រាប់អនុវត្តជាក់ស្តែង និងឆ្លើយតបទៅនឹង ***"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥"*** របស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា គ្រប់អង្គភាពជំនាញស្ថាប័នពាក់ព័ន្ធ ពិតជានឹងចូលរួមអនុវត្តសកម្មភាពការងារដែលបានដាក់ចេញនេះ ពិសេសសហគមន៍អន្តរជាតិនឹងបន្តផ្តល់ជំនួយទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីរួមចំណែកជួយទ្រទ្រង់ដល់ដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងប្រកបដោយប្រសិទ្ធភាពតាមផែនការ និងការរំពឹងទុក។

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# ១. សេចក្តីផ្តើម

## ១.១. សារៈសំខាន់នៃវិស័យកសិ-ឧស្សាហកម្ម

កសិ-ឧស្សាហកម្មជាផ្នែកមួយដ៏សំខាន់នៃសេដ្ឋកិច្ចជាតិ (សេចក្តីលម្អិតមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី១)។ នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ វិស័យកសិ-ឧស្សាហកម្មមានការរីកចម្រើន និងតាងឱ្យ ៧៦% នៃសហគ្រាសឧស្សាហកម្មសរុបចំនួន ៣ ៧២៨ នៅក្នុងប្រទេស។ ការរីកចម្រើននេះត្រូវបានបាត់បង់ដោយសារសង្គ្រាមស៊ីវិលអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ និង១៩៨០។ សម័យក្រោយមកទៀត វិស័យមួយនេះបានរើបឡើងវិញ។ នៅឆ្នាំ២០០៥ វិស័យកសិធុរកិច្ចមានសហគ្រាសចំនួន ៤៥ ៨៩៤ ក៏ប៉ុន្តែក្នុងនោះ ៩១% សុទ្ធសឹងជាសហគ្រាសខ្នាតតូច ដែលមាននិយោជិកក្រោម៥នាក់ និងមានដើមទុនតិចជាង ១ ០០០ ដុល្លារអាមេរិក។

នាពេលបច្ចុប្បន្ននេះ ស្ថិតិអំពីវិស័យកសិ-ឧស្សាហកម្មហាក់មានការខ្វះខាត។ ជំរឿនសហគ្រាសឆ្នាំ២០១១ បានរកឃើញថា មានសហគ្រាសសរុបចំនួន ៥០៥ ១៣៤ នៅទូទាំងប្រទេស រាប់ទាំងសហគ្រាសដែលមានសកម្មភាពទាក់ទងនឹងការកែច្នៃវត្ថុធាតុដើមពីកសិផលផងដែរ។ ទោះបីជាយ៉ាងនេះក្តី គេពិបាកសន្និដ្ឋានឱ្យបានច្បាស់អំពីចំនួនសហគ្រាសនៅក្នុងវិស័យកសិ-ឧស្សាហកម្ម។ ផ្អែកតាមព័ត៌មានកសិ-ឧស្សាហកម្មតាមខេត្ត ដែលចងក្រងដោយបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទូទាំងប្រទេសមានសហគ្រាសកសិ-ឧស្សាហកម្មយ៉ាងតិចចំនួន ៣ ២៣៤[១] ក្នុងនោះមួយភាគតូចជាសហគ្រាសខ្នាតធំ និងភាគច្រើនជារោងម៉ាស៊ីនកិនស្រូវ (៧៨%)។

នៅក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" ដោយមានចែងអំពីវិធានការ និងគោលដៅជាក់លាក់ ដែលរួមចំណែកជំរុញការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។ គោលដៅនោះគឺ *"បង្កើនការនាំចេញទំនិញកែច្នៃកសិកម្ម (រាប់ទាំងផលិតផលកែច្នៃកសិផលថ្មីៗ) ឱ្យបាន ១២% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០២៥"* ដោយផ្តើមចេញពីអនុបាត ៧,៩% នៅឆ្នាំ២០១៣។ ដូចនេះ គោលដៅប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៨ មានអនុបាត ៨% រីឯឆ្នាំ២០២០ និង២០២៥ គឺរៀងគ្នាចំនួន ១០% និង ១២%។ បន្ទាប់ពីបានអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មនេះបានមួយឆ្នាំរួចមក ការនាំចេញទំនិញកែច្នៃកសិកម្មនៅឆ្នាំ២០១៦ មានតែ ៤,៦% នៃការនាំចេញសរុបប៉ុណ្ណោះ គឺទាបជាងគោលដៅដែលបានកំណត់ពីខាងដើម។

## ១.២. ការប្រឈម

ឆ្លើយតបនឹងតម្រូវការនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលព្រមទាំងស្ថាប័នពាក់ព័ន្ធបាននិងកំពុងប្រឹងប្រែងធ្វើកិច្ចការជាច្រើនទៅតាមសមត្ថកិច្ច និងធនធានរបស់ខ្លួន ដើម្បីបង្កើនឧត្តមភាពសេដ្ឋកិច្ចជាតិ ដោយបន្តសម្រួលបរិយាកាសធុរកិច្ច និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រពាណិជ្ជកម្ម (ឡូជីស្ទីក) ឱ្យមានលក្ខណៈកាន់តែអំណោយផលថែមទៀត ទាំងសម្រាប់ការវិនិយោគ និងការរីកលូតលាស់នៃវិស័យឧស្សាហកម្ម

---

[១] *ស្ថិតិនេះគ្របដណ្តប់តែ ១៣ ខេត្តប៉ុណ្ណោះ ពោលគឺពុំបានរាប់បញ្ចូល រាជធានីភ្នំពេញ កំពង់ចាម កណ្តាល ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង ក្រចេះ ស្ទឹងត្រែង បន្ទាយមានជ័យ ព្រះសីហនុ និងកោះកុង។*

រាប់ទាំងកសិ-ឧស្សាហកម្មផងដែរ។ ក៏ប៉ុន្តែ ឧត្តមភាពសេដ្ឋកិច្ចជាតិនៅពុំទាន់ស្មើឬឈានមុខប្រទេសជិតខាងឬក្នុងតំបន់នៅឡើយ។ ស្ថានភាពនេះកើតឡើង ម្យ៉ាងគឺដោយសារប្រទេសដទៃទាំងលើពិភពលោកនិងក្នុងតំបន់ ជាពិសេសប្រទេសជិតខាង (វៀតណាម និងថៃ) ក៏កំពុងខ្នះខ្នែងបង្កើនឧត្តមភាពសេដ្ឋកិច្ចខ្លួនផងដែរ (ឧបសម្ព័ន្ធទី១)។

កត្តាទន់ខ្សោយខាងឧត្តមភាពសេដ្ឋកិច្ចនេះ បានកម្រិតសមត្ថភាពរបស់ប្រទេស ក្នុងការទាញយកវិនិយោគទុនផ្ទាល់ពីបរទេស ដើម្បីអភិវឌ្ឍវិស័យឧស្សាហកម្មរបស់ខ្លួន។ ជាលទ្ធផល កសិផលស្រស់ដែលជាវត្ថុធាតុដើមបានបន្តហូរចេញទៅកាន់រោងចក្រកែច្នៃនៅក្រៅប្រទេស វៀរលែងពេលខ្លះដែលគ្មានតម្រូវការ។ ហេតុនេះ ការសម្រេចគោលដៅនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នៅជួបការរាំងស្ទះជាច្រើន ទោះបីមានកិច្ចខិតខំប្រឹងប្រែងជាច្រើនកន្លងមកហើយក៏ដោយ។ ឆ្លើយតបទៅនឹងបរិការណ៍នេះ យុទ្ធសាស្ត្រថ្មីនឹងត្រូវផ្តោតលើទំនើបកម្មធុរកិច្ច ឬផ្លាស់ប្តូរក្របខ័ណ្ឌការងារ ដោយបង្កើតឱ្យមានទម្លាប់ច្នៃប្រឌិតថ្មីជាបន្តបន្ទាប់ ដើម្បីរក្សាឧត្តមភាពសេដ្ឋកិច្ចរបស់ខ្លួនឱ្យនៅជួរមុខ។

## ១.៣. កាលានុវត្តភាព

ឱកាសមាសសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅតែមាន ថ្វីបើបន្តជួបការប្រឈមយ៉ាងណាក្តី។ វិស័យកសិកម្មបានផ្តល់នូវកសិផលជាច្រើន ដែលអាចជាវត្ថុធាតុដើមសម្រាប់កសិ-ឧស្សាហកម្ម ដោយក្នុងនោះមានដូចជា ស្រូវ ដំឡូងមី ស្វាយចន្ទី កៅស៊ូ និងស្វាយជាដើម។ ក៏ប៉ុន្តែកសិផលទាំងនេះភាគច្រើនត្រូវបាននាំចេញទាំងស្រស់។ ការបង្កបង្កើនផលដំណាំទាំងនេះទៀតសោត វៀរលែងតែកៅស៊ូលក្ខណៈក្រុមហ៊ុនចេញ ភាគច្រើនធ្វើឡើងដោយគ្រួសារកសិករខ្នាតតូច ដែលពុំបានចងក្រងជាសហគមន៍រឹងមាំ និងពុំទាន់បានប្រើបច្ចេកទេសកសិកម្មឱ្យបានត្រឹមត្រូវ និងបច្ចេកវិជ្ជាកសិកម្មទំនើបនៅឡើយ។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់នៅមានលក្ខណៈដាច់ដោយដុំនៅឡើយ។

វិធានការរបស់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម មានលក្ខណៈអំណោយផលដល់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម។ វិធានការទាំងនោះមានដូចជា ការផ្តល់ការអនុគ្រោះពន្ធដល់វិនិយោគិន ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ការអនុវត្តអត្រាថ្លៃអគ្គិសនីទាបចំពោះផលិតកម្មវេនយប់ ការកសាងព្រលានយន្តហោះថ្មី និងកំពង់ផែសមុទ្រទឹកជ្រៅជាដើម។ ការសម្រេចគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជារួម នឹងជួយដោះស្រាយបញ្ហាចម្បងៗទាក់ទិននឹងការបង្កើតបរិយាកាសអំណោយផលដល់ធុរកិច្ច។ ការប្តេជ្ញារបស់រាជរដ្ឋាភិបាលនេះអាចទម្លាយនូវចំណុចកដប ដែលរាំងស្ទះដល់ការបង្កើនឧត្តមភាពសេដ្ឋកិច្ចជាតិ និងបើកផ្លូវឱ្យវិស័យឧស្សាហកម្មអាចចាក់ឫសល្អិតល្អន់ដល់សក្តានុពលជាអតិបរមា។ ជាក់ស្តែង ការប្តេជ្ញានេះត្រូវបានសឱ្យឃើញតាមរយៈចំណាត់ការសម្រួលបរិយាកាសធុរកិច្ចមួយចំនួន ជាអាទិ៍÷ ការរំសាយកាំកុងត្រូលតាមច្រកទ្វារព្រំដែន ការរំសាយកាំសាបពីច្រកទ្វារកំពង់ផែសមុទ្រ ការលុបចោលតម្រូវការវិញ្ញាបនបត្រប្រភពដើមទំនិញ ការដាក់ចេញនូវអនុក្រឹត្យលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម។ ការសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ក៏នឹងជួយកាត់បន្ថយចំណាយថ្លៃហេដ្ឋារចនាសម្ព័ន្ធគាំទ្រពាណិជ្ជកម្មក្នុងការនាំចេញផងដែរ។

ដើម្បីចាប់យកនូវគុណប្រយោជន៍ និងបន្តរក្សាសន្ទុះនៃការប្តេជ្ញានេះ ចាំបាច់ត្រូវមានផែនការយុទ្ធសាស្ត្រជាក់លាក់ សម្រាប់ជាមគ្គុទេសក៍ដល់ដំណើរការអភិវឌ្ឍន៍ ដោយឈរលើក្របខ័ណ្ឌស្ថាប័នដែលមានស្រាប់។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវមានគោលដៅធ្វើឱ្យកសិ-ឧស្សាហកម្មមានឧត្តមភាពសេដ្ឋកិច្ចខ្ពស់ ហើយបន្ទាប់នឹងតម្រូវការទីផ្សារទើបអាចបង្វែរស្ថានភាពលំហូរចេញនៃវត្ថុធាតុដើមកសិផលទៅកាន់ប្រទេសជិតខាងទៅបាន ដែលរួមមាន ដំឡូងមី គ្រាប់ស្វាយចន្ទី កៅស៊ូ ស្វាយ ពោត ស្រូវ គោ ជាដើម ទាំងស្រស់និងក្នុងទម្រង់ពាក់កណ្តាលសម្រេច។ ដរាបណាកសិ-ឧស្សាហកម្មមានឧត្តមភាពសេដ្ឋកិច្ចប្រហាក់ប្រហែល ឬខ្ពស់ជាងប្រទេសជិតខាង វត្ថុធាតុដើមពីកសិផលទាំងនោះនឹងអាចស្ថិតនៅក្នុងស្រុក (វៀរលែងតែផ្គត់ផ្គង់បរិបូរណ៍) ហើយអាចបង្កើតតម្លៃបន្ថែមសម្រាប់សេដ្ឋកិច្ចជាតិផងដែរ។

## ២. គោលការណ៍ និងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រ

### ២.១. គោលការណ៍

ផែនការយុទ្ធសាស្ត្រនេះ មានគោលដៅគាំទ្រដល់បេសកកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានអនុលោមតាមចក្ខុវិស័យ និងទិសដៅវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ហើយជាពិសេសគឺស្របតាម÷

(១). ចក្ខុវិស័យនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥

(២). ចក្ខុវិស័យអភិវឌ្ឍន៍វិស័យកសិកម្ម និង

(៣). ចក្ខុវិស័យវែងឆ្ងាយរបស់កម្ពុជា។

ការរៀបចំផែនការយុទ្ធសាស្ត្រនេះ គឺបានផ្អែកលើ÷ (១)យុទ្ធសាស្ត្រនិងគោលនយោបាយដែលមានស្រាប់ ដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឯកសារគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ សេចក្តីព្រាងផែនការមេវិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៩-២០២៣ និង (២)ប្រភពទិន្នន័យដែលមានស្រាប់ រួមមាន÷ ជំរឿនសហគ្រាស ជំរឿនកសិកម្ម ព័ត៌មានអំពីវិស័យកសិកម្ម និងកសិផលកែច្នៃ ព្រមទាំងព័ត៌មានកសិ-ឧស្សាហកម្មតាមខេត្តដែលចងក្រងដោយបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ២.២. ដំណើរការនៃការរៀបចំ

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានតាក់តែងឡើងដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ រួមមានតំណាងអង្គភាពជំនាញរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន តំណាងកសិករ និងសហគមន៍កសិកម្ម ដោយមានការពិគ្រោះយោបល់ និងទទួលធាតុចូល។ ក្នុងដំណើរការនេះ ភាគីពាក់ព័ន្ធជាច្រើនត្រូវបានប្រាស្រ័យទាក់ទង ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យនានា សម្រាប់រៀបចំចងក្រងព័ត៌មានកសិ-ឧស្សាហកម្ម។ សិក្ខាសាលាពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធចំនួនពីរលើកត្រូវបានរៀបចំឡើង បន្ថែមលើវេទិកាក្រសួង ដើម្បីប្រមូលធាតុចូល និងមតិយោបល់ឆ្លើយតបនានា។ ផែនការយុទ្ធសាស្ត្រនេះ ក៏ត្រូវបានចែកចាយ និងធ្វើបទបង្ហាញដល់ក្រុមការងារបច្ចេកទេសនៃវិស័យកសិកម្មផងដែរ។

ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំតាក់តែងឡើងជាប្រាំបីជំពូក រួមមាន÷ (១)ទិសដៅយុទ្ធសាស្ត្រ (២) ក្របខ័ណ្ឌយុទ្ធសាស្ត្រ (៣)សកម្មភាពយុទ្ធសាស្ត្រ (៤)ក្របខ័ណ្ឌហិរញ្ញប្បទាន (៥)ការអនុវត្ត (៦)ហានិភ័យ និងការគ្រប់គ្រងហានិភ័យ (៧)ការតាមដាន និងការត្រួតពិនិត្យការអនុវត្តគោលនយោបាយ និង (៨)សេចក្តីសន្និដ្ឋាន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៩-២០៣០ គឺជាផែនការយុទ្ធសាស្ត្ររយៈពេលវែង ដែលត្រូវបានតាក់តែងឡើងសម្រាប់អភិវឌ្ឍកសិ-ឧស្សាហកម្មកម្ពុជាចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០ និងតទៅហៅកាត់ថា "ផែនការយុទ្ធសាស្ត្រ"។

## ៣. ទិសដៅយុទ្ធសាស្ត្រ

### ៣.១. ចក្ខុវិស័យ

នៅឆ្នាំ២០៣០ ប្រទេសកម្ពុជានឹងមានកសិ-ឧស្សាហកម្មបែបទំនើបមួយ ដែលមានឧត្តមភាពសេដ្ឋកិច្ចខ្ពស់ មានលក្ខណៈបរិយាប័ន្ន មានភាពរឹងមាំ និងប្រកបដោយចីរភាព។ ចក្ខុវិស័យនេះនឹងត្រូវសម្រេចបានទៅតាមដំណាក់កាលចំនួនបីគឺ÷ (១)ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្ម គិតពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ (២)ពិពិធកម្មនិងបន្លាស់ប្តូរគិតពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦ និង (៣)ការកែច្នៃនិងការបង្កើតថ្មីគិតពីឆ្នាំ២០២៧ ដល់ឆ្នាំ២០៣០។

ដំណើរការវិវត្តលូតលាស់នៃកសិ-ឧស្សាហកម្ម នឹងមានលក្ខណៈបន្តជាប់គ្នាជាលំដាប់នៅដំណាក់កាលទី១ និងទី២ ហើយនឹងមានលក្ខណៈជាដំណាក់ៗវិញនៅចន្លោះដំណាក់កាលទី២និងទី៣ ដោយឆ្លងកាត់ដំណាក់កាលអន្តរកាលដ៏ខ្លីមួយរវាងដំណាក់កាលទាំងពីរ។

### ៣.២. បេសកកម្ម

ផែនការយុទ្ធសាស្ត្រនេះមានបេសកកម្ម ផ្តល់ក្របខ័ណ្ឌអនុវត្ត ដែលគាំទ្រដល់ការអភិវឌ្ឍកសិ-ឧស្សាហកម្មជាតិ។ បេសកកម្មនេះនឹងត្រូវសហការដឹកនាំ សម្របសម្រួល និងគាំទ្រដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមាននាយកដ្ឋានកសិ-ឧស្សាហកម្មជាសេនាធិការទទួលបន្ទុកអនុវត្ត។

### ៣.៣. គោលបំណង

គោលបំណងចម្បងនៃផែនការយុទ្ធសាស្ត្រនេះ គឺបង្កើនការនាំចេញផលិតផលកែច្នៃកសិកម្ម (រាប់ទាំងផលិតផលកែច្នៃថ្មីៗ) ឱ្យបានស្មើនឹង ១៥% នៃការនាំចេញសរុបនៅឆ្នាំ២០៣០។ នៅក្នុងរយៈពេលមធ្យម ពោលគឺត្រឹមឆ្នាំ២០២៥ ត្រូវបង្កើនការនាំចេញនេះរហូតស្មើនឹង ១២[២]% នៃការនាំចេញសរុប។

គោលបំណងនេះ អនុលោមតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ ជាងនេះទៅទៀត ការសម្រេចគោលបំណងនេះនឹងចូលរួមចំណែកដល់ការសម្រេចគោលបំណងរយៈពេលវែងរបស់

---

[២] នេះជាគោលបំណង ដែលចែងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

រាជរដ្ឋាភិបាល ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០។

# ៤. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

## ៤.១. ទិសោលភាព

និយមន័យនៃកសិ-ឧស្សាហកម្មមានលក្ខណៈទូលំទូលាយ ដោយគ្របដណ្តប់ចាប់តាំងពីសកម្មភាពក្រោយប្រមូលផលក្នុងវិស័យកសិកម្ម ការកែច្នៃវត្ថុធាតុដើមពាក់កណ្តាលសម្រេចចេញពីកសិផល ការកែច្នៃចំណីអាហាររហូតដល់កសិធុរកិច្ច (អត្ថបទទី១នៃឧបសម្ព័ន្ធទី១)។ និយមន័យទូលំទូលាយនេះមានន័យថា ដែនសមត្ថកិច្ចនិងការទទួលខុសត្រូវក្នុងការអភិវឌ្ឍកសិ-ឧស្សាហកម្ម មានការទាក់ទងនឹងស្ថាប័នរដ្ឋជាច្រើន។ ក្នុងន័យនេះ កិច្ចការលើកកម្ពស់និងអភិវឌ្ឍន៍វិស័យនេះ អាស្រ័យលើការសម្របសម្រួលរវាងស្ថាប័នពាក់ព័ន្ធទាំងអស់ ហើយជាពិសេសគឺទាមទារនូវពេលវេលា និងធនធានយ៉ាងច្រើនដើម្បីសម្រេចនូវគោលបំណងនៃផែនការយុទ្ធសាស្ត្រនេះ ។

ដោយពិចារណាលើភាពស្មុគស្មាញនៃការសម្របសម្រួល និងគោលបំណងរបស់រាជរដ្ឋាភិបាលដែលចង់លើកកម្ពស់ និងជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ព្រមទាំងបង្កើនសេដ្ឋកិច្ចជាតិ ទាំងក្នុងរយៈពេលមធ្យមនិងវែង ផែនការយុទ្ធសាស្ត្រនេះនឹងផ្តោតលើកសិធុរកិច្ច ដោយយោងតាមនិយមន័យរបស់អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (អត្ថបទទី១នៃឧបសម្ព័ន្ធទី១)។ ក្នុងន័យនេះ នាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវដើរតួនាទីយ៉ាងសំខាន់ ទាំងការងារសម្របសម្រួល និងការងារអនុវត្ត ប៉ុន្តែទាមទារនូវការគាំទ្ររបស់ថ្នាក់ដឹកនាំ ដែលសម្រួលដល់ការបើកទូលាយកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

ផែនការយុទ្ធសាស្ត្រនេះអាចសម្រេចទៅបាន លុះត្រាណាឧត្តមភាពសេដ្ឋកិច្ចជាតិត្រូវបានបង្កើនតាមរយៈការអនុវត្តនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥ និងគោលនយោបាយពាក់ព័ន្ធផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធ (ជាអាទិ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)។

ថ្វីបើផែនការយុទ្ធសាស្ត្រនេះ ពាក់តែងឡើងក្នុងគោលបំណងធ្វើជាផែនការយុទ្ធសាស្ត្ររយៈពេលវែងយ៉ាងណាក្តី ឯកសារនេះត្រូវមានលក្ខណៈរស់រវើក ដោយទាមទារនូវការធ្វើបច្ចុប្បន្នភាពជាទៀងទាត់ និងតាមកាលកំណត់ តាមរយៈការដកបទពិសោធន៍ពីការអនុវត្តជាក់ស្តែង និងតាមរយៈយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីរក្សានូវសង្គតិភាពជាមួយទិសដៅអភិវឌ្ឍន៍ជាតិ និងតាមឱ្យទាន់សភាពការណ៍ ក៏ដូចជានិន្នាការអភិវឌ្ឍន៍ថ្នាក់តំបន់និងសកលលោក។

## ៤.២. គោលដៅយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះបានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ២ ដែលមានលក្ខណៈស្របទៅនឹងគោលដៅ និងយុទ្ធសាស្ត្ររយៈពេលមធ្យមនិងវែងរបស់រាជរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលរួមមានដូចជា÷

(១). ជំរុញការកែច្នៃនិងបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ដែលឆ្លើយតបនឹងតម្រូវការទីផ្សារប្រកបដោយគុណភាព និងសុវត្ថិភាព និង

(២). បង្កើតការងារនៅជនបទ ដែលប្រកបដោយគុណភាព និងបរិយាប័ន្ន។

## ៤.៣. សកម្មភាពយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានតាក់តែងឡើងសម្រាប់រយៈពេល១២ឆ្នាំ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០។ ក្នុងថេរវេលាដ៏វែងនេះ ការអនុវត្តនូវផែនការយុទ្ធសាស្ត្រត្រូវបានចែកជា ៣ ដំណាក់កាល។ ដំណាក់កាលនីមួយៗ មានរយៈពេល ៤ ឆ្នាំ។ ដំណាក់កាលទាំងនេះ មានដូចខាងក្រោម÷

១. ដំណាក់កាលទី១÷ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០២២
(ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម)

២. ដំណាក់កាលទី២÷ ការធ្វើពិពិធកម្ម និងបំប្លែងកសិ-ឧស្សាហកម្មឆ្នាំ២០២៣-២០២៦
(ដំណាក់កាលវឌ្ឍនាការកសិ-ឧស្សាហកម្ម)

៣. ដំណាក់កាលទី៣÷ ការច្នៃប្រឌិត និងការបង្កើតថ្មីក្នុងកសិ-ឧស្សាហកម្មឆ្នាំ២០២៧-២០៣០
(ដំណាក់កាលនវានុវត្តន៍កសិ-ឧស្សាហកម្ម)

ដំណើរការរីកលូតលាស់នៃកសិ-ឧស្សាហកម្ម នឹងមានលក្ខណៈបន្តជាប់គ្នាជាលំដាប់ នៅក្នុងដំណាក់កាលទី១និងទី២។ ដំណើរការនេះនឹងប្រែទៅជាមានលក្ខណៈដាច់ៗ នៅក្នុងដំណាក់កាលអន្តរកាលរវាងដំណាក់កាលទី២ និងទី៣ បន្ទាប់ពីមូលដ្ឋានគ្រឹះកសិ-ឧស្សាហកម្មត្រូវបានសំយោគចូលគ្នា ហើយក្រោយមកទៀត នឹងប្រែត្រឡប់ទៅរកលក្ខណៈបន្តជាប់គ្នាជាលំដាប់វិញ។ បណ្តាកម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពយុទ្ធសាស្ត្រ នឹងត្រូវបានអនុវត្តទៅតាមដំណាក់កាលនីមួយៗ។

ដូចបានគូសបញ្ជាក់ពីខាងដើម ផែនការយុទ្ធសាស្ត្រនេះត្រូវមានលក្ខណៈរស់រវើក។ ហេតុនេះ រាល់កម្មវិធី អនុកម្មវិធី គម្រោង និងសកម្មភាពនានា នៃគ្រប់ដំណាក់កាលទាំងអស់ អាចនឹងត្រូវបានកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ជាពិសេសនៅដំណាក់កាលទី២និងទី៣។ ការកែសម្រួលនេះអាចជាការចាំបាច់ ដើម្បីឱ្យកសិ-ឧស្សាហកម្មមានលក្ខណៈសមស្រប អាចវិវឌ្ឍដោយខ្លួនឯង និងរក្សាបាននូវឧត្តមភាពសេដ្ឋកិច្ចរបស់ខ្លួន។

### ៤.៣.១. ដំណាក់កាលទី១÷ ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម

នៅក្នុងដំណាក់កាលនេះ ផែនការយុទ្ធសាស្ត្រនឹងធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចមាត្រដ្ឋានរបស់សកម្មភាពកសិ-ឧស្សាហកម្មទាំងឡាយណា ដែលមានសក្តានុពលសម្រាប់ធ្វើពាណិជ្ជូបនីយកម្ម និងដែលអាចបង្កើតឱកាស

ការងារប្រកបដោយគុណភាពនៅតាមទីជនបទដែលជាមូលដ្ឋានផលិតកម្មកសិកម្ម។ សេដ្ឋកិច្ចមាត្រដ្ឋានទាំងខាងក្នុង និងខាងក្រៅនឹងអាចសម្រេចទៅបានក្នុងដំណាក់កាលនេះ តាមរយៈការពង្រឹងនិងការធ្វើទំនើបកម្មឱ្យដល់សហគ្រាសកសិធុរកិច្ចដែលមានស្រាប់ ដែលកែច្នៃផលិតផលសក្តានុពលសម្រាប់នាំចេញ[៣] និងជំនួសការនាំចូល។

**ដំណាក់កាលទី១**មានរយៈពេលពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ និងមានកម្មវិធីចំនួន ៣ ដែលចែកចេញជា ៧ អនុកម្មវិធី។ ខ្ទង់ថវិកាសម្រាប់ដំណាក់កាលទី១ មានទឹកប្រាក់ប្រហែល ១១,៨៥ លានដុល្លារអាមេរិក។

*ដំណាក់កាលទី១ កម្មវិធីទី១÷ កម្មវិធីកសាង និងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ*

**កម្មវិធីទី១នៃដំណាក់កាលទី១** មានគោលបំណង÷ (ក)កសាងនិងពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធលើផ្នែកស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ និង(ខ)អភិវឌ្ឍនិងពង្រឹងសមត្ថភាពស្ថាប័នដែលមានស្រាប់ទាក់ទងនឹងក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយ។ កម្មវិធីនេះនឹងត្រូវការខ្ទង់ថវិកាប្រហែល ២,១ លានដុល្លារអាមេរិក សម្រាប់គម្រោងចំនួន ៥ ដែលស្ថិតក្រោមអនុកម្មវិធីចំនួន ២ (តារាងទី១)។

តារាងទី១. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ១ | កម្មវិធីកសាង និងពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ | ៥៤១,០ | ៥៥៦,០ | ៥៥៦,០ | ៤៤១,០ | ២ ០៩៤,០ |
| ១.១ | អនុកម្មវិធីកសាងនិងអភិវឌ្ឍន៍សមត្ថភាព | ៦០,០ | ២៦០,០ | ២១០,០ | ២១០,០ | ៧៤០,០ |
| ១.១.១ | គម្រោងកសាង និងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ | ៣០,០ | ១៨០,០ | ១៣០,០ | ១៣០,០ | ៤៧០,០ |
| ១.១.២ | គម្រោងអភិវឌ្ឍន៍ជំនាញវិភាគ និងត្រួតពិនិត្យលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ | ៣០,០ | ៨០,០ | ៨០,០ | ៨០,០ | ២៧០,០ |
| ១.២ | អនុកម្មវិធីអភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពស្ថាប័ន | ៤៨១,០ | ២៩៦,០ | ៣៤៦,០ | ២៣១,០ | ១ ៣៥៤,០ |
| ១.២.១ | គម្រោងពង្រឹងស្ថាប័ន និងអភិវឌ្ឍន៍ក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌគោលនយោបាយ | ៣៩,០ | ៦៤,០ | ១១៩,០ | ៦៩,០ | ២៩១,០ |
| ១.២.២ | គម្រោងពង្រឹងសមត្ថភាពនាយកដ្ឋានកសិ-ឧស្សាហកម្ម | ១២២,០ | ១៤២,០ | ១២៧,០ | ១២២,០ | ៥១៣,០ |
| ១.២.៣ | គម្រោងអភិវឌ្ឍន៍មន្ទីរពិសោធន៍ | ៣២០,០ | ៩០,០ | ៣៧០,០ | ៣១០,០ | ១ ០៩០,០ |

[៣] គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានចាត់ទុកការនាំចេញជាគោលដៅដ៏សំខាន់មួយ។ យុទ្ធសាស្ត្រដើម្បីសម្រេចបានគោលដៅនាំចេញនេះ គួរផ្តោតលើផលិតផលដែលខ្ញុំមនិងមានសក្តានុពល ដូចជា អង្ករក្រអូប អង្ករក្រអូបសរីរាង្គ និងផលិតផលផ្សេងៗដែលកែច្នៃពី ដំឡូងមី ស្វាយចន្ទី ស្វាយ បន្លែ មៀន ចេកលឿង សណ្តែកសៀង សណ្តែកដី បសុសត្វ និងជលផលសមុទ្រ។

### *ដំណាក់កាលទី១ កម្មវិធីទី២÷ កម្មវិធីផ្ទេរបច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង*

**កម្មវិធីទី២នៃដំណាក់កាលទី១**មានគោលបំណង÷ (ក)កសាង ចែករំលែក និងផ្ទេរចំណេះដឹង និង(ខ)ផ្ទេរបច្ចេកវិជ្ជាពាក់ព័ន្ធនឹងកសិ-ឧស្សាហកម្មដែលអាចប្រើប្រាស់បាន។ កម្មវិធីនេះមានអនុកម្មវិធីចំនួន ២ ដែលនីមួយៗមានគម្រោងចំនួន ២ ផងដែរ។ កម្មវិធីនេះត្រូវការខ្ទង់ថវិកាប្រហែល **១,១៦** លានដុល្លារអាមេរិក (តារាងទី២)។

តារាងទី**២**. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ២ | កម្មវិធីផ្ទេរបច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | ១២៣,០ | ៤១៦,០ | ៣៥៩,០ | ២៥៩,០ | ១១៥៧.,០ |
| ២.១ | អនុកម្មវិធីផ្ទេរ និងគ្រប់គ្រងចំណេះដឹង | ៨៣,០ | ២០៦,០ | ១៤៩,០ | ១៤៩,០ | ៥៨៧,០ |
| ២.១.១ | គម្រោងអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | ៥៣,០ | ១៧១,០ | ១២៤,០ | ១២៤,០ | ៤៧២,០ |
| ២.១.២ | គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា (ឧបសម្ព័ន្ធទី២) | ៣០,០ | ៣៥,០ | ២៥,០ | ២៥,០ | ១១៥,០ |
| ២.២ | អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្ត និងផ្ទេរបច្ចេកវិជ្ជា | ៤០,០ | ២១០,០ | ២១០,០ | ១១០,០ | ៥៧០,០ |
| ២.២.១ | គម្រោងស្រាវជ្រាវកម្រិតអនុវត្តអំពីកសិ-ឧស្សាហកម្ម | ២៥,០ | ១៦៥,០ | ១៦៥,០ | ៦៥,០ | ៤២០,០ |
| ២.២.២ | គម្រោងអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | ១៥,០ | ៤៥,០ | ៤៥,០ | ៤៥,០ | ១៥០,០ |

### *ដំណាក់កាលទី១ កម្មវិធីទី៣÷ កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល និងកសិ-ពាណិជ្ជកម្ម*

**កម្មវិធីទី៣នៃដំណាក់កាលទី១**នេះមានចំនួន ៧ គម្រោង ដែលស្ថិតក្រោមអនុកម្មវិធីចំនួន ៣ (តារាងទី៣) និងត្រូវការថវិកាប្រហែល ៩,៤៥ លានដុល្លារអាមេរិក។ កម្មវិធីនេះមានគោលបំណង÷ (ក)ធានាគុណភាពកសិ-ឧស្សាហផលដែលកំពុងត្រូវបានផលិតឡើង (ខ)បង្កើតកសិ-ឧស្សាហផលថ្មី និងសក្តានុពលដែលអាចប្រកួតប្រជែងលើទីផ្សារ (គ)បង្កើតវេទិកាផ្តួចផ្តើមកសិធុរកិច្ចដែលលើកកម្ពស់ និងបណ្តុះនូវសហគ្រាសកសិ-ឧស្សាហកម្មបើកថ្មី និងមានសក្តានុពលខ្ពស់ និង (ឃ)ជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដែលមានឧត្តមភាពសេដ្ឋកិច្ចខ្ពស់ ដោយជំរុញការអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្ម (Agro-Industry Cluster)។

តារាងទី៣. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី១ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្ដីបរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ៣ | កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | ៩១៣,៦ | ៣ ១៨៨,៦ | ២ ៧៤៩,៦ | ២ ៥៩៩,៦ | ៩ ៤៥១,៤ |
| ៣.១ | អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | ៤៤០,៦ | ៥៩០,៦ | ៦៦០,៦ | ៥៨០,៦ | ២ ២៧២,៤ |
| ៣.១.១ | គម្រោងពង្រឹងគុណភាពផលិតផល (ឧបសម្ព័ន្ធទី៣) | ២២៥,០ | ២៧៥,០ | ៣៣៥,០ | ២៥៥,០ | ១ ០៩០,០ |
| ៣.១.២ | គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | ២១៥,៦ | ៣១៥,៦ | ៣២៥,៦ | ៣២៥,៦ | ១ ១៨២,៤ |
| ៣.២ | អនុកម្មវិធីអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្ម (ឧបសម្ព័ន្ធទី៤) | ៤១៥,០ | ២ ៣៩០,០ | ១ ៨០៦,០ | ១ ៧៥៦,០ | ៥ ៣៦៧,០ |
| ៣.២.១ | គម្រោងអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | ១៨២,៥ | ២១០,០ | ១២៨,០ | ១២៨,០ | ៦៤៨,៥ |
| ៣.២.២ | គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | ១៨២,៥ | ២១០,០ | ១២៨,០ | ១២៨,០ | ៦៤៨,៥ |
| ៣.២.៣ | គម្រោងបង្កើតវេទិកាផ្ដួចផ្ដើមកសិធុរកិច្ច (ឧបសម្ព័ន្ធទី៥) | ៥០,០ | ១ ៩៧០,០ | ១ ៥៥០,០ | ១ ៥០០,០ | ៥ ០៧០,០ |
| ៣.៣ | អនុកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | ៥៨,០ | ២០៨,០ | ២៨៣,០ | ២៦៣,០ | ៨១២,០ |
| ៣.៣.១ | គម្រោងអភិវឌ្ឍន៍ទីផ្សារក្នុងស្រុក | ២៥,០ | ៧០,០ | ១២០,០ | ១០០,០ | ៣១៥,០ |
| ៣.៣.២ | គម្រោងអភិវឌ្ឍន៍ទីផ្សារអន្តរជាតិ | ៣៣,០ | ១៣៨,០ | ១៦៣,០ | ១៦៣,០ | ៤៩៧,០ |

## ៤.៣.២. ដំណាក់កាលទី២÷ ដំណាក់កាលវឌ្ឍនាការកសិ-ឧស្សាហកម្ម

សមិទ្ធផលនៃការអនុវត្តសកម្មភាពរបស់កម្មវិធីទាំងបីខាងលើ នឹងជួយឱ្យសហគ្រាសកសិ-ឧស្សាហកម្មដែលមានស្រាប់ភាគច្រើនប្រែទៅជាមានលក្ខណៈរៀបរយ និងពេញសមត្ថភាពនៅចុងដំណាក់កាលទី១។ មានន័យថា កសិ-ឧស្សាហកម្មទាំងមូលអាចសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋានខាងក្រៅរបស់ខ្លួន ទោះបីជានៅចុងដំណាក់កាលទី១ នៅតែមានសហគ្រាសខ្លះពុំទាន់អាចពង្រឹងប្រសិទ្ធភាព ឬប្រសិទ្ធផលរបស់ខ្លួន ឬក៏ពុំទាន់អាចសម្រេចបានសេដ្ឋកិច្ចមាត្រដ្ឋានខាងក្នុងក្ដី ដោយសារកត្តានានា (ជាឧទាហរណ៍ ទំហំ ការគ្រប់គ្រងខ្សោយ កង្វះយុទ្ធសាស្ត្រអាជីវកម្ម ឬនៅប្រើប្រាស់បច្ចេកវិជ្ជាហួសសម័យកាល ។ល។)។

នៅពេលឈានដល់**ដំណាក់កាលទី២** បណ្ដាសហគ្រាសដែលពុំទាន់អាចពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលរបស់ខ្លួនបាននៅឡើយនោះ អាចនឹងនៅបន្តអាជីវកម្មរបស់ខ្លួន ហើយស្វះស្វែងសម្រេចឱ្យបាននូវសេដ្ឋកិច្ចមាត្រដ្ឋានខាងក្នុងរបស់ខ្លួន។ ចំណែកឯកសិ-ឧស្សាហកម្មទាំងមូលវិញ នឹងបន្តពង្រឹងសេដ្ឋកិច្ចមាត្រដ្ឋានខាងក្រៅ ធ្វើពិពិធកម្មទាំងផលិតផល និងទីផ្សារបន្ថែមទៀត និងព្យាយាមបំប្លែងមូលដ្ឋានគ្រឹះបច្ចេកវិជ្ជារបស់ខ្លួន។ នៅដំណាក់កាលទី២នេះ កសិ-ឧស្សាហកម្មទាំងមូលនឹងត្រៀមបំប្លែងទៅដំណាក់កាលបច្ចេកវិជ្ជាខ្ពស់ ដែលក្នុងនោះ ទាំងដំណើរការគ្រប់គ្រងបច្ចេកវិជ្ជា និងផលិតផលនឹងប្រែក្លាយជាមានលក្ខណៈទំនើប និងថ្មៃប្រឌិតខ្ពស់។ ជាមួយគ្នានេះ ក៏អាចនឹងមាន

តម្រូវការការងារបន្ថែមផងដែរ ប៉ុន្តែសុទ្ធសឹងទាមទារនូវគុណវុឌ្ឍិខ្ពស់ជាងមុន។ ដើម្បីត្រៀមឆ្លើយតបនឹងតម្រូវការនេះ ការអប់រំកសិកម្ម និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងត្រូវរំពឹងថាបានរៀបចំផែនការបណ្តុះបណ្តាលរបស់ខ្លួនឱ្យបានសមស្រប។

**ដំណាក់កាលទី២**នឹងប្រព្រឹត្តទៅពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៦ និងត្រូវការខ្ទង់ថវិកាប្រហែល ១២,២ លានដុល្លារអាមេរិក។ ដូចគ្នានឹងដំណាក់កាលទី១ដែរ ដំណាក់កាលនេះមានកម្មវិធីចំនួន៣ ដែលរួមមានអនុកម្មវិធីចំនួន៧។

*ដំណាក់កាលទី២ កម្មវិធីទី១÷ កម្មវិធីកសាង និងពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ*

**កម្មវិធីទី១នៃដំណាក់កាលទី២**ចែកជាអនុកម្មវិធីចំនួន ២ ដែលមានគម្រោងសរុបចំនួន ៥(តារាងទី៤) និងត្រូវការថវិកាប្រហែល ២,៣៨ លានដុល្លារអាមេរិក។ កម្មវិធីនេះមានគោលបំណងពង្រឹង និងសំយោគនូវសមត្ថភាពជំនាញ និងស្ថាប័នដែលត្រូវបានកសាង និងអភិវឌ្ឍរួចមកហើយនៅក្នុងដំណាក់កាលទី១។

តារាងទី៤. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប |
|---|---|---|---|---|---|---|
| ១ | កម្មវិធីកសាង និងពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ | ៧៦៦,០ | ៥១១,០ | ៥៥៦,០ | ៥៥១,០ | ២ ៣៨៤,០ |
| ១.១ | អនុកម្មវិធីសំយោគសមត្ថភាព | ២១០,០ | ២១០,០ | ២១០,០ | ២១០,០ | ៨៤០,០ |
| ១.១.១ | គម្រោងពង្រឹងជំនាញការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពនិងសុវត្ថិភាពចំណីអាហារ | ១៣០,០ | ១៣០,០ | ១៣០,០ | ១៣០,០ | ៥២០,០ |
| ១.១.២ | គម្រោងពង្រឹងជំនាញស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ និងការវិភាគ និងត្រួតពិនិត្យគុណភាពចំណីអាហារ | ៨០,០ | ៨០,០ | ៨០,០ | ៨០,០ | ៣២០,០ |
| ១.២ | អនុកម្មវិធីពង្រឹងស្ថាប័ន | ៥៥៦,០ | ៣០១,០ | ៣៤៦,០ | ៣៤១,០ | ១ ៥៤៤,០ |
| ១.២.១ | គម្រោងសំយោគក្របខណ្ឌច្បាប់និងគោលនយោបាយ និងស្ថាប័ន | ២៩,០ | ២៩,០ | ២៩,០ | ២៩,០ | ៩៦,០ |
| ១.២.២ | គម្រោងពង្រឹងមុខងារនាយកដ្ឋានកសិ-ឧស្សាហកម្ម | ១២៧,០ | ១២២,០ | ១២៧,០ | ១២២,០ | ៤៩៨,០ |
| ១.២.៣ | គម្រោងពង្រឹងប្រតិបត្តិការមន្ទីរពិសោធន៍ | ៤០០,០ | ១៥០,០ | ២០០,០ | ២០០,០ | ៩៥០,០ |

*ដំណាក់កាលទី២ កម្មវិធីទី២÷ កម្មវិធីអភិវឌ្ឍន៍បច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង*

**កម្មវិធីទី២នៃដំណាក់កាលទី២**នេះមានគោលបំណង÷ (១)ពង្រឹងចំណេះដឹងនិងចំណេះធ្វើ និងធានាគុណភាពនៃចំណេះដឹង និងចំណេះធ្វើក្នុងកសិ-ឧស្សាហកម្ម និង (២)អភិវឌ្ឍបច្ចេកវិជ្ជាថ្មី និងលើកកម្ពស់ពាណិជ្ជកម្ម។

កម្មវិធីនេះមានអនុកម្មវិធីចំនួន ២ ដែលចែកជា ៤ គម្រោង និងត្រូវការថវិកាប្រហែល ១,០៤ លានដុល្លារអាមេរិក (តារាងទី៥)។

តារាងទី៥. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)

| លេខរៀង | សេចក្តីបរិយាយ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប |
|---|---|---|---|---|---|---|
| ២ | កម្មវិធីអភិវឌ្ឍន៍បច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | ២៥៩,០ | ២៥៤,០ | ២៦៤,០ | ២៦៤,០ | ១ ០៤១,០ |
| ២.១ | អនុកម្មវិធីពង្រឹងការគ្រប់គ្រងចំណេះដឹង | ១៤៩,០ | ១៥៤,០ | ១៤៩,០ | ១៤៩,០ | ៦០១,០ |
| ២.១.១ | គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | ១២៤,០ | ១២៤,០ | ១២៤,០ | ១២៤,០ | ៤៩៦,០ |
| ២.១.២ | គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | ២៥,០ | ៣០,០ | ២៥,០ | ២៥,០ | ១០៥,០ |
| ២.២ | អនុកម្មវិធីអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិជ្ជា | ១១០,០ | ១០០,០ | ១១៥,០ | ១១៥,០ | ៤៤០,០ |
| ២.២.១ | គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | ៦៥,០ | ៦៥,០ | ៦៥,០ | ៦៥,០ | ២៦០,០ |
| ២.២.២ | គម្រោងអភិវឌ្ឍន៍ និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | ៤៥,០ | ៣៥,០ | ៥០,០ | ៥០,០ | ១៨០,០ |

*ដំណាក់កាលទី២ កម្មវិធីទី៣៖ កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល និងពង្រីកពាណិជ្ជកម្ម*

**កម្មវិធីទី៣នៃដំណាក់ទី២**មានគោលដៅ៖ (១)ពង្រឹងនិងសំយោគលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីពីមុននៅក្នុងដំណាក់កាលកន្លងទៅ និង (២)ធ្វើពិពិធកម្មផលិតផលនិងទីផ្សារ និងពង្រីកវិសាលភាពទាំងទីផ្សារនិងភូមិសាស្ត្រគោលដៅរបស់កសិ-ឧស្សាហកម្ម។ កម្មវិធីនេះមានអនុកម្មវិធីចំនួន ៣ ដែលរួមមាន ៨ គម្រោង និងត្រូវការថវិកា ៨,៧៤ លានដុល្លារអាមេរិក (តារាងទី៦)។

តារាងទី៦. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី២ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប |
|---|---|---|---|---|---|---|
| ៣ | កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល និងពង្រីកពាណិជ្ជកម្ម | ២ ៨៦២.១ | ២ ២៨៩,០ | ២ ១៥៧,០ | ២ ០៧៧,០ | ៩ ៣៨៥,១ |
| ៣.១ | អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | ៦៤០,៦ | ៤៩៥,០ | ៥៣៥,០ | ៤៧៥,០ | ២ ១៤៥,៦ |
| ៣.១.១ | គម្រោងធានាគុណភាពផលិតផល | ៣១៥,០ | ២៧៥,០ | ៣១៥,០ | ២៥៥,០ | ១ ១៦០,០ |
| ៣.១.២ | គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | ៣២៥,៦ | ២២០,០ | ២២០,០ | ២២០,០ | ៩៨៥,៦ |
| ៣.២ | អនុកម្មវិធីពង្រីក និងសំយោគតំបន់កសិ-ឧស្សាហកម្ម | ១ ៩៣៨,៥ | ១ ៥១៦,០ | ១ ៣៣៤,០ | ១ ៣៣៤,០ | ៦ ១៤២,០ |
| ៣.២.១ | គម្រោងពង្រីក និងសំយោគតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | ១២៨,០ | ១២៨,០ | ១០៨,០ | ១០៨,០ | ៤៧២,០ |
| ៣.២.២ | គម្រោងពង្រីក និងសំយោគតំបន់ | ១២៨,០ | ១២៨,០ | ១០៨,០ | ១០៨,០ | ៤៧២,០ |

| លេខ | សេចក្តីបរិយាយ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប |
|---|---|---|---|---|---|---|
| | កសិ-ឧស្សាហកម្មភាគបូព៌ា | | | | | |
| ៣.២.៣ | គម្រោងសំយោគវេទិកាផ្តួចផ្តើមកសិធុរកិច្ច | ១ ៥០០,០ | ១ ០៥០,០ | ១ ០០០,០ | ១ ០០០,០ | ៤ ៥៥០,០ |
| ៣.២.៤ | គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | ១៨២,៥ | ២១០,០ | ១២៨,០ | ១២៨,០ | ៦៤៨,៥ |
| ៣.៣ | អនុកម្មវិធីពង្រីក និងសំយោគពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | ២៨៣,០ | ២៧៨,០ | ២៧៨,០ | ២៥៨,០ | ១ ០៩៧,០ |
| ៣.៣.១ | គម្រោងពង្រីក និងសំយោគទីផ្សារក្នុងស្រុក | ១២០,០ | ១២០,០ | ១២០,០ | ១០០,០ | ៤៦០,០ |
| ៣.៣.២ | គម្រោងពង្រីក និងសំយោគទីផ្សារអន្តរជាតិ | ១៦៣,០ | ១៥៨,០ | ១៥៨,០ | ១៥៨,០ | ៦៣៧,០ |

### ៤.៣.៣. ដំណាក់កាលទី៣÷ ដំណាក់កាលនវានុវត្តកសិ-ឧស្សាហកម្ម

នៅចុងដំណាក់កាលទី២ កសិ-ឧស្សាហកម្មបានឈានដល់ដំណាក់កាលរីកចម្រើនខ្លាំង និងអាចឈានទៅដំណាក់កាលមួយដែលមានលក្ខណៈទំនើបខ្លាំងថែមទៀត។ នៅក្នុង**ដំណាក់កាលទី៣**នេះ កសិ-ឧស្សាហកម្មនឹងមានសមត្ថភាពចាប់យកបច្ចេកវិទ្យាឌីជីថល បញ្ញាសិប្បនិមិត្ត និងប្លុកឆេន មកប្រើបានយ៉ាងទូលំទូលាយ។ រីឯចំណាយថ្លៃដើមឯកតានៃសហគ្រាសនីមួយៗនិងវិស័យទាំងមូលនឹងឈានទៅរកសូន្យ។

កសិ-ឧស្សាហកម្មនៅដំណាក់កាលទី៣នឹងកាន់តែពឹងផ្អែកខ្លាំងទៅលើបច្ចេកវិទ្យា ចំណេះដឹង និងជំនាញ។ សហគ្រាសនីមួយៗ និងវិស័យទាំងមូលនឹងមានប្រសិទ្ធផលខ្ពស់ មានភាពឆ្លាតវៃ និងអាចបង្កើតតម្លៃបន្ថែមបានច្រើនជាងកសិ-ឧស្សាហកម្មនៅក្នុងដំណាក់កាលមុនៗ បើគិតក្នុងមួយឯកតាធនធានប្រើប្រាស់ដូចគ្នា។ កសិ-ឧស្សាហកម្មក្នុងដំណាក់នេះ នឹងបន្តបង្កើតការងារបន្ថែម ហើយការងារទាំងនោះជាការងារដែលទាមទារនូវចំណេះដឹង និងជំនាញបច្ចេកវិទ្យាកាន់តែខ្ពស់ ពោលគឺជំនាញបង្កើតថ្មី និងនវានុវត្តន៍។

ដើម្បីគាំទ្រដល់ដំណាក់កាលនេះ រាជរដ្ឋាភិបាលនឹងដាក់ចេញ÷ (១)ការអនុវត្តកម្មវិធីអភិវឌ្ឍន៍ចំណេះដឹងភាសាអង់គ្លេស និងបច្ចេកវិទ្យាសម្រាប់ក្មេងៗជំនាន់ក្រោយ ដើម្បីអាចឆ្លើយតបតម្រូវការការងារ និង (២)ការពង្រឹង និងពង្រីកកម្មវិធីគាំពារសង្គមសម្រាប់ពលរដ្ឋសកម្ម ដែលកាន់តែមានអាយុច្រើន និងពុំទាន់អាចសម្របខ្លួនឬតាមទាន់សន្ទុះនៃការអភិវឌ្ឍបច្ចេកវិទ្យាសម័យថ្មី។

**ដំណាក់កាលទី៣**នឹងចាប់ផ្តើមពីឆ្នាំ២០២៧ ដល់ឆ្នាំ២០៣០ និងត្រូវការថវិកាចំនួនប្រហែល ១២,៤២ លានដុល្លារអាមេរិក។ ស្រដៀងគ្នានឹងដំណាក់កាលទី១ និងទី២ដែរនោះ ដំណាក់កាលនេះមាន ៣ កម្មវិធី ដែលរួមមានអនុកម្មវិធីចំនួន ៧។

### *ដំណាក់កាលទី៣ កម្មវិធីទី១÷ កម្មវិធីនវានុវត្តន៍លើសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ*

**កម្មវិធីទី១នៃដំណាក់ទី៣**មានគោលដៅ÷ (១)បញ្ជ្រាបជំនាញបង្កើតថ្មីនិងនវានុវត្តន៍ និងកសាងទេពកោសល្យក្នុងកសិ-ឧស្សាហកម្ម និង (២)លើកកម្ពស់ និងអភិវឌ្ឍបណ្តាស្ថាប័ននវានុវត្តន៍។ កម្មវិធីនេះមានអនុកម្មវិធីចំនួន ២ ដែលរួមមាន ៥ គម្រោង និងត្រូវការថវិកាប្រហែល ២,២៤ លានដុល្លារអាមេរិក (**តារាងទី៧**)។

តារាងទី៧. ថវិកាសម្រាប់កម្មវិធីទី១នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|
| ១ | កម្មវិធីនវានុវត្តន៍លើសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ | ៧៩១,០ | ៤៨៦,០ | ៤៩១,០ | ៤៧៦,០ | ២ ២៤៤.១ |
| ១.១ | អនុកម្មវិធីអភិវឌ្ឍន៍ជំនាញ និងទេពកោសល្យបង្កើតថ្មីនិងនវានុវត្ត | ៣២៥,០ | ២២៥,០ | ២២៥,០ | ២២៥,០ | ១ ០០០,០ |
| ១.១.១ | គម្រោងនវានុវត្តន៍លើការអភិវឌ្ឍជំនាញនិងទេពកោសល្យខាងស្តង់ដារ នៃគុណភាពនិងសុវត្ថិភាពចំណីអាហារ ការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តប្រព័ន្ធកំណត់អត្តសញ្ញាណវាយតម្លៃ (HACCP) | ២០៥,០ | ១៣០,០ | ១៣០,០ | ១៣០,០ | ៥៩៥,០ |
| ១.១.២ | គម្រោងនវានុវត្តន៍លើការអភិវឌ្ឍជំនាញនិងទេពកោសល្យ ខាងការវិភាគនិងការត្រួតពិនិត្យគុណភាពចំណីអាហារ | ១២០,០ | ៩៥,០ | ៩៥,០ | ៩៥,០ | ៤០៥,០ |
| ១.២ | អនុកម្មវិធីបង្កើតឡើងវិញ និងនវានុវត្តន៍ស្ថាប័ន | ៤៦៦,០ | ២៦១,០ | ២៦៦,០ | ២៥១,០ | ១ ២៤៤,០ |
| ១.២.១ | គម្រោងនវានុវត្តន៍លើការអភិវឌ្ឍក្របខ័ណ្ឌច្បាប់និងក្របខ័ណ្ឌគោលនយោបាយ | ៨៤,០ | ៨៤,០ | ៨៤,០ | ៨៤,០ | ៣៣៦,០ |
| ១.២.២ | គម្រោងបង្កើតឡើងវិញនៃនាយកដ្ឋានកសិ-ឧស្សាហកម្ម | ១៦៧,០ | ១៦២,០ | ១៥៧,០ | ១៥២,០ | ៦៣៨,០ |
| ១.២.៣ | គម្រោងវិមជ្ឈការ និងឯកជនភាវូបនីយកម្មនៃសេវាមន្ទីរពិសោធន៍ | ២១៥,០ | ១៥,០ | ២៥,០ | ១៥,០ | ២៧០,០ |

### *ដំណាក់កាលទី៣ កម្មវិធីទី២÷ កម្មវិធីនវានុវត្តន៍បច្ចេកវិជ្ជានិងគ្រប់គ្រងចំណេះដឹង*

**កម្មវិធីទី២នៃដំណាក់កាលទី៣**មានគោលបំណង÷ (១)សម្រួលនិងលើកកម្ពស់ការប្រើប្រាស់នូវដំណើរការគ្រប់គ្រង បច្ចេកទេស និងបច្ចេកវិជ្ជាចុងក្រោយសម្រាប់កសិ-ឧស្សាហកម្ម និង (២)សម្រួលកិច្ចអភិវឌ្ឍន៍ និងការប្រើប្រាស់ឧបករណ៍ឌីជីថល បញ្ញាសិប្បនិម្មិត និងបច្ចេកវិជ្ជាប្លុកឆេន ដែលគាំទ្រដល់ការធ្វើឱ្យប្រសើរឡើងនៃកសិ-ឧស្សាហកម្ម។ កម្មវិធីនេះមានអនុកម្មវិធីចំនួន ២ ដែលរួមមាន ៤ គម្រោង និងត្រូវការថវិកាចំនួន ១,៣១ លានដុល្លារអាមេរិក (តារាងទី៨)។

តារាងទី៨. ថវិកាសម្រាប់កម្មវិធីទី២នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|
| ២ | កម្មវិធីនវានុវត្តន៍បច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | ៣៦៩,០ | ៣១៣,០ | ៣១៣,០ | ៣១៣,០ | ១.៣០៨,០ |
| ២.១ | អនុកម្មវិធីស្រាវជ្រាវមូលដ្ឋាន និងផ្ទេរបច្ចេកវិជ្ជា | ២០៤,០ | ១៤៨,០ | ១៤៨,០ | ១៤៨,០ | ៦៤៨,០ |
| ២.១.១ | គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | ១២៤,០ | ១២៤,០ | ១២៤,០ | ១២៤,០ | ៤៩៦,០ |
| ២.១.២ | គម្រោងអភិវឌ្ឍន៍ និងអនុវត្តប្រព័ន្ធឌីជីថលលើផលិតកម្មកសិកម្មតាមកិច្ចសន្យា | ៨០,០ | ២៤,០ | ២៤,០ | ២៤,០ | ១៥២,០ |
| ២.២ | អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្ត និងផ្ទេរបច្ចេកវិជ្ជា | ១៦៥,០ | ១៦៥,០ | ១៦៥,០ | ១៦៥,០ | ៦៦០,០ |
| ២.២.១ | គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | ៨០,០ | ៨០,០ | ៨០,០ | ៨០,០ | ៣២០,០ |
| ២.២.២ | គម្រោងនវានុវត្តន៍លើការអភិវឌ្ឍដំណើរនិងបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | ៨៥,០ | ៨៥,០ | ៨៥,០ | ៨៥,០ | ៣៤០,០ |

*ដំណាក់កាលទី៣ កម្មវិធីទី៣÷ កម្មវិធីនវានុវត្តន៍កសិ-ឧស្សាហផល និងពាណិជ្ជកម្ម*

**កម្មវិធីទី៣នៃដំណាក់ទី៣**មានអនុកម្មវិធីចំនួន ៣ ហើយមានគម្រោងសរុបចំនួន ៨។ កម្មវិធីនេះនឹងត្រូវការថវិកាចំនួនប្រហែល ៨,៨៧ លានដុល្លារអាមេរិក (តារាងទី៩) និងមានគោលបំណង÷ (១)បង្កើនមុខផលិតផលបន្ថែមទៀតដែលកែច្នៃចេញពីកសិផល និងដែលមានលក្ខណៈនវានុវត្តន៍ និងគុណភាពខ្ពស់ និង (២)ធានានូវការផ្គត់ផ្គង់កសិ-ឧស្សាហផលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដើម្បីបន្តពង្រីកវិសាលភាពទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ។

តារាងទី៩. ថវិកាសម្រាប់កម្មវិធីទី៣នៃដំណាក់កាលទី៣ (ពាន់ដុល្លារអាមេរិក)

| លេខ | សេចក្តីបរិយាយ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|
| ៣ | កម្មវិធីនវានុវត្តន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | ២ ៣៩២,០ | ២ ១៤២,០ | ២ ១៨២,០ | ២ ១៥២,០ | ៨ ៨៦៨,០ |
| ៣.១ | អនុកម្មវិធីនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | ៥៨០,០ | ៥៤០,០ | ៥៨០,០ | ៥២០,០ | ២ ២២០,០ |
| ៣.១.១ | គម្រោងធានាគុណភាពកសិ-ឧស្សាហផល | ៣១៥,០ | ២៧៥,០ | ៣១៥,០ | ២៥៥,០ | ១ ១៦០,០ |
| ៣.១.២ | គម្រោងនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | ២៦៥,០ | ២៦៥,០ | ២៦៥,០ | ២៦៥,០ | ១ ០៦០,០ |
| ៣.២ | អនុកម្មវិធីបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្ម | ១ ៤៣៤,០ | ១ ៣២៤,០ | ១ ៣២៤,០ | ១ ៣៧៤,០ | ៥ ៤៥៦,០ |

| លេខ | សេចក្តីបរិយាយ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប |
|---|---|---|---|---|---|---|
| ៣.២.១ | គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | ១០៨,០ | ១០៨,០ | ១០៨,០ | ១០៨,០ | ៤៣២,០ |
| ៣.២.២ | គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | ១០៨,០ | ១០៨,០ | ១០៨,០ | ១០៨,០ | ៤៣២,០ |
| ៣.២.៣ | គម្រោងបង្កើតឡើងវិញនូវវេទិកាផ្តួចផ្តើមកសិធុរកិច្ច | ១ ១១០,០ | ១ ០០០,០ | ១ ០០០,០ | ១ ០៥០,០ | ៤ ១៦០,០ |
| ៣.២.៤ | គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | ១០៨,០ | ១០៨,០ | ១០៨,០ | ១០៨,០ | ៤៣២,០ |
| ៣.៣ | អនុកម្មវិធីនវានុវត្តន៍លើពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | ៣៧៨,០ | ២៧៨,០ | ២៧៨,០ | ២៥៨,០ | ១ ១៩២,០ |
| ៣.៣.១ | គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារក្នុងស្រុក | ១២០,០ | ១២០,០ | ១២០,០ | ១០០,០ | ៤៦០,០ |
| ៣.៣.២ | គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារអន្តរជាតិ | ២៥៨,០ | ១៥៨,០ | ១៥៨,០ | ១៥៨,០ | ៧៣២,០ |

ជារួម ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនេះមាន៣ដំណាក់កាល និងត្រូវការថវិកាចំនួន ៣៧,៩៣ លានដុល្លារអាមេរិក សម្រាប់ថេរវេលា ១២ឆ្នាំ ពីឆ្នាំ២០១៩ ដល់២០៣០ (តារាងទី១០)។ ថវិកានេះនឹងត្រូវយកមកប្រើសម្រាប់គម្រោងចំនួន៥០។ គម្រោងទាំងអស់នេះអាចនឹងកែសម្រួល អាស្រ័យលើលទ្ធផលអនុវត្តន៍ជាក់ស្តែងនៃផែនការយុទ្ធសាស្ត្រ។

## ៥. ក្របខ័ណ្ឌហិរញ្ញប្បទាន

ការផ្គត់ផ្គង់ធនធានគ្រប់គ្រាន់មានសារសំខាន់ណាស់ដើម្បីអនុវត្តផែនការ។ សម្រាប់ដំណាក់កាលនីមួយៗនៃផែនការយុទ្ធសាស្ត្រនេះ បណ្ដាធនធានទាំងឡាយត្រូវផ្គត់ផ្គង់ឱ្យបានទាន់ពេលវេលា ជាពិសេសធនធានថវិកា។ ដោយសារថាដំណាក់កាលទី១នៃផែនការយុទ្ធសាស្ត្របានចាប់ផ្ដើមហើយ ហេតុនេះការផ្គត់ផ្គង់ធនធានថវិកានឹងត្រូវផ្ដល់អាទិភាពខ្ពស់។

នៅដំណាក់កាលដំបូងនេះ ពុំទាន់មានប្រភពហិរញ្ញប្បទានជាក់លាក់នៅឡើយ សម្រាប់ទ្រទ្រង់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដូចនេះមានតែប្រើប្រាស់ខ្ទង់ថវិកាដែលមានស្រាប់របស់នាយកដ្ឋានកសិ-ឧស្សាហកម្មប៉ុណ្ណោះ ដែលជាថវិកាវិភាជន៍របស់រាជរដ្ឋាភិបាលផ្ទាល់។ ទោះបីយ៉ាងនេះក្ដី ខ្ទង់ថវិកានេះមានទំហំតូច (តារាងទី១១) និងគ្រោងប្រើសម្រាប់តែកម្មវិធីដែលមានស្រាប់របស់នាយកដ្ឋាននេះតែប៉ុណ្ណោះ។ មានន័យថា គម្លាតហិរញ្ញប្បទាននឹងកើតមានឡើង។

ថវិកាកម្មវិធីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម ដែលទទួលបានពីរាជរដ្ឋាភិបាល បានកើនឡើងជាមធ្យម ១៧% ក្នុងមួយឆ្នាំ។ នៅឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានវិភាជថវិកាចំនួន ០,៤៧ លានដុល្លារ សម្រាប់ទ្រទ្រង់កម្មវិធីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម។ ប្រសិនបើប្រើថវិកាវិភាជន៍នេះ គ្រាន់តែសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រមួយមុខ ក៏គម្លាតហិរញ្ញប្បទាននៅតែកើតមានផងដែរក្នុងឆ្នាំ២០១៩ គឺមានទំហំទឹកប្រាក់ខ្វះយ៉ាងហោចណាស់ ១,១ លានដុល្លារ (ឬ ៦៨,៣៦% នៃថវិកាប៉ាន់ប្រមាណ)។ ស្ថានភាពកង្វះថវិកានេះអាចនឹងបន្តកើតឡើងរហូតដល់ឆ្នាំ២០២៧ ពោលគឺមុនឈានចូលដំណាក់កាលទី៣ (២០២៨-២០៣០) នៃផែនការយុទ្ធសាស្ត្រ ប្រសិនបើថវិកាវិភាជន៍នៅមានទំហំដដែល។

តម្រូវការធនធានហិរញ្ញវត្ថុនៅក្នុងដំណាក់កាលទី១មានចំនួន ១២,៧០ លានដុល្លារ។ ចំណែកឯតម្រូវការនៅក្នុងដំណាក់កាលទី២និងទី៣វិញ មានទឹកប្រាក់រៀងគ្នាចំនួន ១២,៨១ លានដុល្លារ និង ១២,៤២ លានដុល្លារ។ ដូចបានបង្ហាញក្នុងតារាងទី១១ គម្លាតហិរញ្ញប្បទាននៅដំណាក់កាលទី១មានទំហំទឹកប្រាក់ចំនួន ១០,២៨ លានដុល្លារ ហើយនៅដំណាក់កាលទី២និងទី៣ មានរៀងគ្នា ៨,១៩ លានដុល្លារ និង ៣,៦១ លានដុល្លារ។ ដូច្នេះ ការកៀរគរធនធានហិរញ្ញវត្ថុជាការចាំបាច់ ជាពិសេសសម្រាប់ដំណាក់កាលទី១ ដោយសារតែរយៈពេលកន្លះឆ្នាំបានកន្លងទៅហើយក្នុងឆ្នាំ២០១៩ ដែលជាឆ្នាំដំបូងនៃផែនការយុទ្ធសាស្ត្រនេះ។ ទន្ទឹមនឹងការអនុវត្តសកម្មភាពនៃដំណាក់កាលទី១ ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ដំណាក់កាលទី២ ក៏នឹងប្រព្រឹត្តទៅផងដែរ។ យន្តការដូចគ្នានេះនឹងត្រូវយកមកអនុវត្តសម្រាប់ដំណាក់ទី៣។

ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ផែនការយុទ្ធសាស្ត្រ អាចធ្វើឡើងតាមរយៈ÷ (១)បង្កើនថវិកាវិភាជន៍របស់រាជរដ្ឋាភិបាលសម្រាប់កសិ-ឧស្សាហកម្ម (២)ស្នើជំនួយហិរញ្ញវត្ថុពីសំណាក់ដៃគូអភិវឌ្ឍន៍ (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល) និង(៣)ទាក់ទាញវិនិយោគទុនពីវិស័យឯកជន (វិនិយោគិនក្នុងស្រុកនិងបរទេស)។

## តារាងទី១១. ស្ថានភាពថវិកាទ្រទ្រង់ដំណាក់កាលទី១នៃផែនការយុទ្ធសាស្ត្រ (ដុល្លារអាមេរិក)

| ដំណាក់កាល / កម្មវិធី | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | សរុប (មិនទាន់អប្បហា) |
|---|---|---|---|---|---|
| *ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកម្មកសិ-ឧស្សាហកម្ម)* | *1,577,600.0* | *4,160,600.0* | *3,664,600.0* | *3,299,600.0* | *12,702,400.0* |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 541,000.0 | 556,000.0 | 556,000.0 | 441,000.0 | 2,094,000.0 |
| ២. កម្មវិធីផ្ទេរបច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | 123,000.0 | 416,000.0 | 359,000.0 | 259,000.0 | 1,157,000.0 |
| ៣. កម្មវិធីអភិវឌ្ឍន៍ កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | 913,600.0 | 3,188,600.0 | 2,749,600.0 | 2,599,600.0 | 9,451,400.0 |
| *ដំណាក់កាលទី២៖ ការធ្វើពិពិធកម្ម និងបំប្លែង កសិ-ឧស្សាហកម្ម ឆ្នាំ២០២៣-២០២៦ (ដំណាក់កាលវឌ្ឍនាការ កសិ-ឧស្សាហកម្ម)* | *3,887,100.0* | *3,054,000.0* | *2,977,002.0* | *2,892,002.0* | *12,810,104.0* |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 766,000.0 | 511,000.0 | 556,002.0 | 551,002.0 | 2,384,004.0 |
| ២. កម្មវិធីអភិវឌ្ឍន៍ បច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | 259,000.0 | 254,000.0 | 264,000.0 | 264,000.0 | 1,041,000.0 |
| ៣. កម្មវិធីអភិវឌ្ឍន៍ កសិ-ឧស្សាហផលនិងពង្រីកពាណិជ្ជកម្ម | 2,862,100.0 | 2,289,000.0 | 2,157,000.0 | 2,077,000.0 | 9,385,100.0 |
| *ដំណាក់កាលទី៣៖ ការច្នៃប្រឌិតនិងការបង្កើតថ្មីក្នុងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៧-២០៣០ (ដំណាក់កាលនវានុវត្តកសិ-ឧស្សាហកម្ម)* | *3,552,000.0* | *2,941,000.0* | *2,986,000.0* | *2,941,000.0* | *12,420,000.0* |
| ១. កម្មវិធីនវានុវត្តលើ សមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 791,000.0 | 486,000.0 | 491,000.0 | 476,000.0 | 2,244,000.0 |
| ២. កម្មវិធីនវានុវត្តបច្ចេកវិជ្ជានិងគ្រប់គ្រងចំណេះដឹង | 369,000.0 | 313,000.0 | 313,000.0 | 313,000.0 | 1,308,000.0 |
| ៣. កម្មវិធីនវានុវត្តកសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | 2,392,000.0 | 2,142,000.0 | 2,182,000.0 | 2,152,000.0 | 8,868,000.0 |
| ថវិកាសរុប | 9,016,700.0 | 10,155,600.0 | 9,627,602.0 | 9,132,602.0 | 37,932,504.0 |
| ប្រៀបធៀបថវិកាកម្មវិធីរបស់ផែនការយុទ្ធសាស្ត្រ និងរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម(វិភាជន៍ពីរាជរដ្ឋាភិបាល) | | | | | |
| ឆ្នាំ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប (មិនទាន់អប្បហា) |
| ថវិកាកម្មវិធីនៅក្នុងឯកសារផែនការយុទ្ធសាស្ត្រ (ប៉ាន់ស្មាន) | 1,577,600.0 | 4,160,600.0 | 3,664,600.0 | 3,299,600.0 | 12,702,400.0 |
| ថវិកាកម្មវិធីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម (ព្យាករណ៍, មិនរាប់ឆ្នាំ២០១៩) | 468,500.0 | 550,450.7 | 646,736.3 | 759,864.4 | 2,425,551.4 |
| **គម្លាតថវិកា** | **(1,109,100.0)** | **(3,610,149.3)** | **(3,017,863.7)** | **(2,539,735.6)** | **(10,276,848.6)** |
| ឆ្នាំ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | សរុប (មិនទាន់អប្បហា) |
| ថវិកាកម្មវិធីនៅក្នុងឯកសារផែនការយុទ្ធសាស្ត្រ (ប៉ាន់ស្មាន) | 3,887,100.0 | 3,054,000.0 | 2,977,002.0 | 2,892,002.0 | 12,810,104.0 |
| ថវិកាកម្មវិធីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម (ព្យាករណ៍) | 892,780.9 | 1,048,947.4 | 1,232,430.8 | 1,448,009.4 | 4,622,168.5 |
| **គម្លាតថវិកា** | **(2,994,319.1)** | **(2,005,052.6)** | **(1,744,571.2)** | **(1,443,992.6)** | **(8,187,935.5)** |
| ឆ្នាំ | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | សរុប (មិនទាន់អប្បហា) |
| ថវិកាកម្មវិធីនៅក្នុងឯកសារផែនការយុទ្ធសាស្ត្រ (ប៉ាន់ស្មាន) | 3,552,000.0 | 2,941,000.0 | 2,986,000.0 | 2,941,000.0 | 12,420,000.0 |
| ថវិកាកម្មវិធីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម (ព្យាករណ៍) | 1,701,297.3 | 1,998,890.6 | 2,348,539.4 | 2,759,349.3 | 8,808,076.6 |
| **គម្លាតថវិកា** | **(1,850,702.7)** | **(942,109.4)** | **(637,460.6)** | **(181,650.7)** | **(3,611,923.4)** |
| *សរុបកង្វះថវិកា* | **(5,954,121.8)** | **(6,557,311.3)** | **(5,399,895.5)** | **(4,165,379.0)** | **(22,076,707.5)** |

ក្នុងពេលបច្ចុប្បន្ន ការចាត់ចែងថវិកាទៅតាមវិស័យរបស់រាជរដ្ឋាភិបាល គឺតិចតួចណាស់ដូចដែលបានបង្ហាញក្នុងតារាង១១ ខាងលើ។ ផ្អែកលើការវិវឌ្ឍនៃសេដ្ឋកិច្ច និងទំហំនៃប្រាក់ចំណូលរបស់ប្រទេស រាជរដ្ឋាភិបាលនឹងបង្កើនថវិកាសម្រាប់វិស័យនេះ។ ប៉ុន្តែទំហំនៃការបង្កើនមិនអាចព្យាករណ៍ទុកនោះទេ ដោយសារតែរាជរដ្ឋាភិបាលមានអាទិភាព និងតម្រូវការបន្ទាន់ផ្សេងទៀត ជាពិសេសការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍសង្គម (ដើម្បីអាចដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ)។

មកដល់បច្ចុប្បន្ន ជំនួយពីដៃគូអភិវឌ្ឍន៍លើវិស័យនេះនៅមានកម្រិតនៅឡើយ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសនាយកដ្ឋានកសិ-ឧស្សាហកម្ម នឹងធ្វើការយ៉ាងជិតស្និទ្ធ និងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល) ដើម្បីកៀរគរការគាំទ្រផ្នែកហិរញ្ញវត្ថុ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នរដ្ឋផ្សេងទៀត (ជាពិសេស ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

ក្រសួងពាណិជ្ជកម្ម) នឹងជំរុញដៃគូអភិវឌ្ឍន៍ឱ្យពិចារណានិងបញ្ចូលផែនការយុទ្ធសាស្ត្រនេះ ចូលក្នុងផែនការផ្តល់ជំនួយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ពួកគេដល់កម្ពុជា។

ទោះបីជាមានកិច្ចប្រឹងប្រែង និងការចាត់ចែងថវិការបស់វិស័យសាធារណៈក៏ដោយ កសិ-ឧស្សាហកម្មអាចអភិវឌ្ឍនិងរីកលូតលាស់បាន លុះត្រាតែមានការចូលរួមផុរផុស ទាំងសកម្មភាព និងការវិនិយោគពីសំណាក់វិស័យឯកជន។ ដូចបានរំលេចនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងបណ្តាសកម្មភាពចំណាត់ការរបស់ខ្លួននាពេលថ្មីៗនេះ រាជរដ្ឋាភិបាលនឹងបន្តធ្វើឱ្យប្រសើរឡើងបន្ថែមទៀត នូវបរិយាកាសអំណោយផលដល់ធុរកិច្ច ដើម្បីបង្កលក្ខណៈទាក់ទាញ និងភាពងាយស្រួលដល់វិនិយោគិនឯកជន ដើម្បីចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

នៅក្នុងន័យនេះ បណ្តាសកម្មភាពខាងក្រោមនឹងត្រូវអនុវត្តបន្ថែមទៀត សំដៅទាក់ទាញនិងសម្រួលដល់ការវិនិយោគលើកសិ-ឧស្សាហកម្ម។ សកម្មភាពទាំងនោះ[៤]មានដូចខាងក្រោម÷

១. រៀបរៀងនិងផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវសៀវភៅមគ្គុទ្ទេសក៍វិនិយោគ និងការវិភាគអំពីឱកាសវិនិយោគលើសកម្មភាពអាជីវកម្មក្នុងវិស័យកសិ-ឧស្សាហកម្ម
២. បង្កើតនិងដំណើរការវែបសាយ និងកម្មវិធីទូរស័ព្ទងាយស្រួលប្រើ ដែលផ្តល់ព័ត៌មានអំពីការវិនិយោគនៅក្នុងវិស័យកសិ-ឧស្សាហកម្ម
៣. ចាក់ផ្សាយស្ប៉ត់ពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយឯកជន ទាំងរបស់ជាតិ និងអន្តរជាតិដែលល្បីឈ្មោះ ដើម្បីបង្ហាញឱកាសវិនិយោគក្នុងវិស័យកសិ-ឧស្សាហកម្ម
៤. រៀបចំឱ្យមានទំនាក់ទំនងជាទៀងទាត់ជាមួយដៃគូអភិវឌ្ឍន៍ និងស្ថានទូតបរទេសនៅកម្ពុជា ដើម្បីលើកកម្ពស់ការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម
៥. សហការនិងសម្របសម្រួលជាមួយមន្ត្រីផ្នែកពាណិជ្ជកម្មរបស់ស្ថានទូតកម្ពុជា ដើម្បីលើកកម្ពស់ការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម និង
៦. រៀបចំជាទៀងទាត់នូវវេទិកាស្តីពីការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដោយមានការបង្ហាញអំពីឱកាសវិនិយោគក្នុងវិស័យនេះ។

## ៦. ការរៀបចំការអនុវត្ត

កសិ-ឧស្សាហកម្មមានលក្ខណៈប្រទាក់ក្រឡាជាអន្តរវិស័យ និងមានទំនាក់ទំនងទៅនឹងស្ថាប័ន និងភាគីពាក់ព័ន្ធជាច្រើន។ បើពិនិត្យមើលតាមដែនសមត្ថកិច្ចចំពោះវិស័យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទទួលបន្ទុកលើការកែច្នៃបឋម ដែលរាប់ទាំងធុរកិច្ចចំណីអាហារផងដែរ (ឧបសម្ព័ន្ធទី៦)។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ផ្តោតសំខាន់លើការកែច្នៃបន្ទាប់ ខណៈដែលក្រសួងពាណិជ្ជកម្មយកចិត្តទុកដាក់ទៅលើទីផ្សារ ឬពាណិជ្ជកម្មផលិតផល។ ដោយឡែក ក្រសួងទេសចរណ៍ត្រួតពិនិត្យលើសេវាកម្មភោជនីយដ្ឋាន និងអាហារដ្ឋានសម្រាប់ភ្ញៀវ

---

[៤] *សកម្មភាពទាំងនេះ ភាគច្រើនស្ថិតក្រោមទំនួលខុសត្រូវ និងការដឹកនាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប៉ុន្តែត្រូវបានបញ្ចូលក្នុងគម្រោងដែលដាក់ស្នើក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនេះ។*

ទេសចរណ៍។ ការបែងចែកអំពីតួនាទី ភារកិច្ច និងដែនសមត្ថកិច្ចទាំងនេះ ត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល។

ហេតុនេះ ការអភិវឌ្ឍកសិ-ឧស្សាហកម្មត្រូវប្រកាន់យកអភិក្រមខ្សែច្រវាក់តម្លៃគ្រប់ជ្រុងជ្រោយ។ ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ពុំអាចអនុវត្តការងារអភិវឌ្ឍន៍វិស័យនេះដាច់ដោយឡែកពីគ្នាបានឡើយ។ ការអភិវឌ្ឍកសិ-ឧស្សាហកម្មអាចសម្រេចជោគជ័យបានត្រូវពឹងផ្អែកលើ÷ (១)កិច្ចខិតខំប្រឹងប្រែងដែលមានលក្ខណៈសង្គតិភាព និងកិច្ចសម្របសម្រួលដ៏ជិតស្និទ្ធក្នុងចំណោមស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ និង(២)ការផ្តោតលើភូមិសាស្ត្រដែលមានសក្តានុពល និងការជ្រើសរើសខ្សែច្រវាក់តម្លៃច្បាស់លាស់ និងមានសក្តានុពលខ្ពស់ (ជាឧទាហរណ៍ ខ្សែច្រវាក់តម្លៃដំឡូងមី ខ្សែច្រវាក់តម្លៃស្វាយចន្ទី ខ្សែច្រវាក់តម្លៃស្វាយ ខ្សែច្រវាក់តម្លៃមាន់ស្រែ ឬខ្សែច្រវាក់តម្លៃចេក)។

ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ នាយកដ្ឋានកសិ-ឧស្សាហកម្មនឹងដើរតួនាទី÷ (១)អនុវត្តចំពោះតែសកម្មភាពដែលស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន[៥] (២)សម្របសម្រួល និងផ្តល់កិច្ចគាំទ្រដល់អង្គភាពផ្សេងទៀតចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំពោះការអនុវត្តសកម្មភាពដែលស្ថិតក្រោមការទទួលខុសត្រូវរបស់អង្គភាពទាំងនោះ និង (៣)ចរចានិងពិភាក្សាជាមួយក្រសួងផ្សេងទៀត ដើម្បីជំរុញការអនុវត្តសកម្មភាពដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងទាំងនោះ។

## ៧. ហានិភ័យ និងការគ្រប់គ្រងហានិភ័យ

ហានិភ័យនិងកត្តាប្រឈមមួយចំនួន អាចបង្កជាឧបសគ្គដល់ការសម្រេចជោគជ័យនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ក្នុងនោះមានហានិភ័យកើតចេញពីនយោបាយអន្តរជាតិចំនួន ១ និងហានិភ័យកម្រិតម៉ាក្រូចំនួន ៣ ដែលរួមមាន (១)ការប្រឈមកើតចេញពីកិច្ចសម្របសម្រួលអន្តរស្ថាប័នពាក់ព័ន្ធ ដោយសារមានភាពត្រួតស៊ីគ្នានៃដែនសមត្ថកិច្ច ជាពិសេសនៅពេលអនុវត្តសកម្មភាពរបស់ផែនការយុទ្ធសាស្ត្រ (២)កត្តាបម្រែបម្រួលអាកាសធាតុ និង (៣)ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក។ បញ្ហាដែលអាចកើតមាន កម្រិតនៃផលប៉ះពាល់ លទ្ធភាពដែលអាចកើតឡើង និងវិធានការដោះស្រាយចំពោះហានិភ័យទាំងនេះ ត្រូវបានបង្ហាញនៅតារាងទី១២។

[៥] *ឧបសម្ព័ន្ធទី៦បង្ហាញអំពីលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់អំពីតួនាទី និងភារកិច្ចរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម។ ឯកសារផ្សេងទៀតដែលចែងទាក់ទងនឹងតួនាទី និងភារកិច្ចរបស់នាយកដ្ឋាននេះ រួមមាន៖ ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ ៣៥៨ (២០០២), លេខ ៣៣៤ (២០០៧), លេខ ៣៤៦ (២០០៩) និងលេខ ២០៤ (២០១៨) និងសេចក្តីសម្រេចលេខ ១៩៦ (២០១៧)។*

## តារាងទី១២. ហានិភ័យ និងការឆ្លើយតបចំពោះហានិភ័យ

| ហានិភ័យ | បញ្ហា | ផលប៉ះពាល់ | ភាពអាចកើតឡើង | ដំណោះស្រាយ |
|---|---|---|---|---|
| **ការប្រឈមកើតចេញពីកិច្ចសម្របសម្រួលអន្តរស្ថាប័នពាក់ព័ន្ធ** | ស្ថាប័នជាច្រើនទទួលខុសត្រូវ និងមានដែនសមត្ថកិច្ចលើសកម្មភាពជាក់លាក់ ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍកសិ-ឧស្សាហកម្ម។ ស្ថាប័នទាំងនោះអាចប្រកាន់នូវគោលជំហរ ផ្ដោតទៅលើតែតួនាទី មុខងារ និងការទទួលខុសត្រូវរបស់ខ្លួនតែម្យ៉ាង។<br>ចំណុចនេះអាចបង្កជាការប្រឈមយ៉ាងខ្លាំងសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម ដែលមានភាពប្រទាក់ក្រឡាជាអន្តរវិស័យ ហើយដែលទាមទារនូវកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ។ | ផែនការយុទ្ធសាស្ត្រនឹងត្រូវអនុវត្តដាច់ដោយដុំ គឺពុំមានសង្គតិភាព ហើយនឹងទទួលបានលទ្ធផលតិចតួច<br>កសិ-ឧស្សាហកម្មជាតិនឹងនៅតែមិនអភិវឌ្ឍ ហើយប្រទេសជាតិនឹងបន្តបាត់បង់តម្លៃបន្ថែមយ៉ាងសម្បើមពីការកែច្នៃកសិផល។ ដូច្នេះ ការនាំចេញវត្ថុធាតុដើមកសិកម្មនឹងបន្តកើតមានឡើង។ | មធ្យម | ស្ថាប័នដែលទទួលបន្ទុកសម្របសម្រួល និងផ្ដល់កិច្ចគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ (ជាពិសេស នាយកដ្ឋានកសិ-ឧស្សាហកម្ម) ត្រូវមានធនធាននិងសមត្ថភាពគ្រប់គ្រាន់។ នាយកដ្ឋានកសិ-ឧស្សាហកម្មត្រូវមានភាពជាអ្នកដឹកនាំខ្លាំង និងប្រើអភិក្រមខ្សែច្រវាក់តម្លៃគ្រប់ជ្រុងជ្រោយ ដើម្បីអនុវត្ត និងសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ |
| **កត្តាបម្រែបម្រួលអាកាសធាតុ** | បម្រែបម្រួលអាកាសធាតុគឺពិតប្រាកដ និងមានផលប៉ះពាល់ដ៏សម្បើមមកលើសេដ្ឋកិច្ចជាតិ ជាពិសេសចំពោះវិស័យកសិកម្ម។<br>កត្តានេះនឹងអាចផ្លាស់ប្ដូរលំនាំតម្រូវការ និងអាទិភាពវិនិយោគនៃវិស័យសាធារណៈ និងវិស័យឯកជន។ | ផលជះអវិជ្ជមាននៃបម្រែបម្រួលអាកាសធាតុមកលើវិស័យកសិកម្មមានន័យថា ការផលិតវត្ថុធាតុដើមកសិកម្មដែលត្រូវការចាំបាច់សម្រាប់កសិ-ឧស្សាហកម្មនឹងថយចុះ។<br>ការផ្លាស់ប្ដូរនៃលំនាំតម្រូវការ និងវិនិយោគក៏អាចនឹងមានផលជះដល់កសិ-ឧស្សាហកម្មផងដែរ។ | ខ្ពស់ | ភាពជាដៃគូរវាងរដ្ឋ និងឯកជន(PPP) ក្នុងការវិនិយោគលើកសិកម្មធន់ទ្រាំនឹងអាកាសធាតុនឹងត្រូវបានលើកកម្ពស់ លើកទឹកចិត្ត និងសម្របសម្រួល។ |
| **ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក** | ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក នឹងប៉ះពាល់ដល់ចំណូលរបស់អ្នកប្រើប្រាស់។ | តម្រូវការសរុប (ទាំងក្នុងស្រុក និងអន្តរជាតិ) និងការចំណាយរបស់អ្នកប្រើប្រាស់លើកសិ-ឧស្សាហផល អាចប៉ះពាល់អំឡុងពេលនៃវិបត្តិសេដ្ឋកិច្ច ដោយសារតែអ្នកប្រើប្រាស់នឹងបង្វែរអាទិភាពចំណាយ សម្រាប់តែតម្រូវការមូលដ្ឋាន។ | មធ្យម | វិធានការលើកទឹកចិត្តនឹងត្រូវអនុវត្ត ពិសេសវិធានការមួយចំនួនមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។<br>ម្យ៉ាងទៀត នឹងលៃលកបង្កើនការចំណាយ និងការវិនិយោគសាធារណៈ។ នេះជាវិធានការឆ្លើយតបបន្ទាន់ |

| ហានិភ័យ | បញ្ហា | ផលប៉ះពាល់ | ភាពអាចកើតឡើង | ដំណោះស្រាយ |
|---|---|---|---|---|
| | បន្ថែមពីលើនោះ ក្នុងអំឡុងនៃវិបត្តិសេដ្ឋកិច្ច លំហូរចេញនៃមូលធនពីប្រទេសនឹងកើតមានឡើង។ | ខណៈដែលមូលធនត្រូវបានហូរចេញពីសេដ្ឋកិច្ចក្នុងស្រុក នោះការវិនិយោគក្នុងវិស័យនេះនឹងត្រូវប៉ះពាល់។<br><br>ជាទូទៅ ការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោកនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់ការវិនិយោគក្នុងវិស័យនេះ ហើយនឹងជះឥទ្ធិពលដល់ដំណើរការ និងការអភិវឌ្ឍនៃវិស័យនេះដែរ។ | | ទៅនឹងផលប៉ះពាល់ ដែលមានគោលបំណងសម្រាប់អត្ថប្រយោជន៍រយៈពេលវែង (ឧ. ចំណាយអភិវឌ្ឍន៍វចនាសម្ព័ន្ធ ការវិនិយោគអភិវឌ្ឍន៍ជំនាញ ការផ្តល់មូលនិធិសម្រាប់នវានុវត្តបច្ចេកវិជ្ជា)។ |
| **នយោបាយអន្តរជាតិ** | សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិកនៅតែបន្តជាទីផ្សារសំខាន់សម្រាប់ផលិតផលកម្ពុជា។ | ការពឹងផ្អែកលើចំនួនទីផ្សារតិចមានហានិភ័យខ្ពស់។ បន្ថែមពីលើនោះ នយោបាយអន្តរជាតិ (រួមទាំងការគាំពារនិយមសង្គ្រាមពាណិជ្ជកម្ម របៀបវារៈសិទ្ធិមនុស្ស និងប្រជាធិបតេយ្យនៃទីផ្សារទាំងនេះ) អាចពន្យារឬរាំខានការនាំចេញ (រាប់ទាំងការនាំចេញកសិ-ឧស្សាហផលផងដែរ)។ ការនាំចេញអង្ករទៅកាន់ទីផ្សារសហភាពអឺរ៉ុបគឺជាឧទាហរណ៍ថ្មីៗ។ | មធ្យម | ត្រូវធ្វើពិពិធកម្មទីផ្សារនាំចេញ ដោយចាប់យកនូវសក្តានុពលទីផ្សារផ្សេងទៀត ដូចជាទីផ្សារចិន អាស៊ានឥណ្ឌា មជ្ឈិមបូព៌ា និងអាហ្វ្រិក។ |

## ៨. ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ៨.១. គោលបំណង

ផែនការយុទ្ធសាស្ត្រមានគោលបំណង បង្កើនការនាំចេញទំនិញកែច្នៃកសិកម្មឱ្យបាន ១៥% នៃបរិមាណនាំចេញសរុបនៅឆ្នាំ២០៣០។ ផែនការនេះមានគោលបំណងជាយុទ្ធសាស្ត្រចំនួន ៣។ ការសម្រេចបាននូវគោលដៅ និងកម្មវិធីទាំងនេះ នឹងរួមចំណែកទៅក្នុងគោលដៅអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ និងទូលំទូលាយរបស់រាជរដ្ឋាភិបាល និងប្រទេសទាំងមូល។ ដើម្បីបញ្ជាក់នូវការសម្រេចបាននេះ ចាំបាច់ត្រូវមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងឆ្លើយតបចំពោះគោលបំណងយ៉ាងតិច ៣ រួមមាន÷ (១)តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នូវដំណើរការ និងការសម្រេចបាននៃផែនការនេះ (២)តាមដាន និងធ្វើបច្ចុប្បន្នភាព ហានិភ័យ និងការប្រឈមដែលអាចនឹងកើតមាន និង (៣)ចងក្រងជាឯកសារនូវមេរៀនដែលទទួលបាន និងកំណត់នូវឱកាសដែលអាចត្រូវបានប្រើ ដើម្បីធ្វើឱ្យការបំពេញការងារកាន់តែប្រសើរជាងមុន និងដើម្បីបង្កើតផែនការ យុទ្ធសាស្ត្រនាពេលអនាគតឱ្យកាន់តែល្អជាងមុន។ លទ្ធផលនិងរបកគំហើញ ពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះក៏នឹងមានសារៈសំខាន់ខ្លាំងណាស់ដែរសម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត។

ដើម្បីបំពេញតាមគោលដៅនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនេះបាន លុះត្រាតែប្រព័ន្ធនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអាចមានលទ្ធភាពផ្តល់ និងបង្កើតនូវព័ត៌មាន/ទិន្នន័យ ដែលត្រឹមត្រូវនិងអាចជឿទុកចិត្តបានក្នុងពេលសមរម្យមួយ ដែលគ្រប់ភាគីពាក់ព័ន្ធអាចចូលមើលបាន ហើយអ្វីដែលសំខាន់បំផុតនោះ គឺងាយស្រួលក្នុងការបកស្រាយ និងស្រួលយល់។ ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោង និងកម្មវិធីក្នុងផែនការយុទ្ធសាស្ត្រត្រូវតែស៊ីសង្វាក់ និងស្របគ្នាទៅវិញទៅមក។ ថ្វីបើដូច្នេះក៏ដោយ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងត្រូវតែផ្អែកលើកម្មវិធីដែលគម្រោងនោះចូលរួមចំណែក។ បន្ទាប់មក ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីត្រូវតែបង្កើតឡើងជុំវិញប្រព័ន្ធនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ វៀរលែងតែវិស័យណាមួយនោះបានធ្វើឡើងរួចទៅហើយ។

### ៨.២. ឋានានុក្រម និងស្ថាប័នទទួលបន្ទុកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដ៏ល្អត្រូវ÷ (១)បញ្ជាក់អំពីប្រភេទទិន្នន័យដែលត្រូវការ និងឋានានុក្រមនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (២)កំណត់និងចាត់ចែងស្ថាប័នទទួលខុសត្រូវទៅតាមកម្រិតពាក់ព័ន្ធ និង(៣)ផ្តល់ការណែនាំអំពីប្រព័ន្ធ និងវិធីសាស្ត្រប្រមូលព័ត៌មាន គ្រប់គ្រង វិភាគទិន្នន័យ និងផ្សព្វផ្សាយលទ្ធផលនៃរបកគំហើញអំពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ក្នុងន័យនេះ ត្រូវមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទាំងខាងក្នុងនិងខាងក្រៅសម្រាប់ផែនការយុទ្ធសាស្ត្រ។

ផ្អែកលើរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រ ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មាន ៤ កម្រិត÷ កម្រិតសកម្មភាពយុទ្ធសាស្ត្រ កម្រិតគោលដៅយុទ្ធសាស្ត្រ កម្រិតគោលបំណង និងកម្រិតចក្ខុវិស័យ (តារាងទី១៣)។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងកម្រិតផ្សេងៗត្រូវតែអាចរាយការណ៍ពីលទ្ធផល និងរបកគំហើញក្នុងកម្រិត

នីមួយៗនៃខ្សែច្រវាក់លទ្ធផល។ ដំណើរការឈានទៅរកការសម្រេចបាននូវកម្រិតសំខាន់ៗ រួមមាន÷ គោលបំណង គោលដៅ និងចក្ខុវិស័យយុទ្ធសាស្ត្រនេះ នឹងអាចតាមដាន និងរាយការណ៍បានក្នុងមួយឆ្នាំៗ ខណៈដែលកម្រិតផ្សេងទៀត រាប់ទាំងសកម្មភាពយុទ្ធសាស្ត្រអាចធ្វើបានរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងគួរតែត្រូវបានអនុវត្ត និងសម្របសម្រួលដោយភ្នាក់ងារដែលទទួលខុសត្រូវសម្រាប់ការអនុវត្តគម្រោង ខណៈដែលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់កម្មវិធី គួរតែជាការទទួលខុសត្រូវរបស់អង្គភាព ឬក្រុមដែលទទួលខុសត្រូវក្នុងការអនុវត្តកម្មវិធី។ ភ្នាក់ងារ/ក្រុមដែលទទួលខុសត្រូវចំពោះកម្មវិធីនេះ គួរតែត្រូវបានផ្តល់ភារកិច្ចចងក្រងរាល់ព័ត៌មាន/ទិន្នន័យតាមដាន និងវាយតម្លៃគម្រោង លទ្ធផល និងរបកគំហើញនៃកម្មវិធីដែលរួមចំណែកទៅក្នុងការសម្រេចបាននូវផែនការយុទ្ធសាស្ត្រ។ ម៉្យាងវិញទៀត ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ និងការចងក្រងរាល់ព័ត៌មាន/ទិន្នន័យ លទ្ធផល និងរបកគំហើញនៃការតាមដាន និងវាយតម្លៃកម្មវិធី គួរតែជាការទទួលខុសត្រូវនៃអង្គភាពដែលគ្រប់គ្រងការអនុវត្ត ដឹកនាំ ឬសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលក្នុងករណីនេះ នាយកដ្ឋានកសិ-ឧស្សាហកម្មគឺជាអ្នកអនុវត្ត។

ដើម្បីធានាការងារនេះ គំរូ និងទម្រង់បទដ្ឋាន សម្រាប់ការប្រមូលព័ត៌មាន/ទិន្នន័យ និងការរាយការណ៍ ការតាមដាននិងវាយតម្លៃដែលត្រូវបានប្រើសម្រាប់គម្រោង កម្មវិធី និងផែនការយុទ្ធសាស្ត្រ នឹងត្រូវបានបង្កើត និងអាចរកបាន។ គំរូបទដ្ឋាននោះ គួរតែមានផ្នែកណែនាំ ផ្តល់ព័ត៌មាន/ទិន្នន័យ និងការវិភាគនៃប្រសិទ្ធភាព ប្រសិទ្ធផល ផលប៉ះពាល់ ចីរភាព មេរៀន នវានុវត្តន៍ និងផែនការពង្រីកវិសាលភាព ហើយក៏ត្រូវមានផ្នែកសេចក្តីសន្និដ្ឋានដែរ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ គួរតែអាចរាយការណ៍បានពីស្ថានភាពនៃសូចនាករវាស់វែងក្នុងគម្រោង កម្មវិធី និងផែនការយុទ្ធសាស្ត្រ។

## ៤.៣. ការប្រមូល ការគ្រប់គ្រង ការវិភាគព័ត៌មាន តាមដាននិងវាយតម្លៃ និងប្រព័ន្ធរាយការណ៍

វិធីសាស្ត្រប្រមូលទិន្នន័យក្នុងការតាមដាននិងវាយតម្លៃ ត្រូវតែស្របគ្នាក្នុងចំណោមគម្រោង កម្មវិធី និងផែនការយុទ្ធសាស្ត្រ ដែលនឹងអាចធ្វើឱ្យមានការប្រៀបធៀបដោយមានអត្ថន័យក្នុងគម្រោង កម្មវិធី និងសម្រាប់ការចងក្រងឱ្យបានសមស្របសម្រាប់ផែនការយុទ្ធសាស្ត្រទាំងមូល។ ព័ត៌មាន/ទិន្នន័យដែលប្រមូលបាន និងចងក្រងតាមរយៈការតាមដាននិងវាយតម្លៃនឹងត្រូវធ្វើឡើងទាំងជាទម្រង់បរិមាណវិស័យ និងគុណវិស័យ។

ដើម្បីធានាថា ព័ត៌មាន/ទិន្នន័យជាបរិមាណវិស័យ និងគុណវិស័យ ត្រូវបានកត់ត្រានៅក្នុងការអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ មធ្យោបាយប្រមូលព័ត៌មាន/ទិន្នន័យខាងក្រោមគួរតែត្រូវបានប្រើ÷ (១)អង្កេត (២)ការសិក្សាបែបសង្កេតក្នុងរយៈពេលកំណត់ និង (៣)វិធីសាស្ត្របែបគុណវិស័យ (ជាពិសេសការជជែកពិភាក្សាតាមក្រុមជាក់លាក់ និងករណីសិក្សា)។ ការប្រើប្រាស់នូវមធ្យោបាយទាំងអស់នេះរួមបញ្ចូលគ្នា មិនត្រឹមតែអាចឱ្យមានការប្រមូលព័ត៌មានបែបបរិមាណវិស័យ និងគុណវិស័យប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់វិធីសាស្ត្រសិក្សាដើម្បីផ្ទៀងផ្ទាត់ និងសម្រាប់បំពេញបន្ថែមផងដែរ។

# តារាងទី១៣. ប្រព័ន្ធគ្រប់គ្រងលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ

| កម្រិត | សេចក្តីបរិយាយ | សូចនាករ | ទិន្នន័យ/របាយការណ៍ | ហានិភ័យ |
|---|---|---|---|---|
| **អតិផល** | **ចក្ខុវិស័យ** | | | |
| ^^^^^ | នៅត្រឹមឆ្នាំ២០៣០ ប្រទេសកម្ពុជានឹងមានកសិ-ឧស្សាហកម្មបែបទំនើបមួយ ដែលមានឧត្តមភាពសេដ្ឋកិច្ចខ្ពស់ មានលក្ខណៈបរិយាប័ន្ន មានភាពរឹងមាំ។ | ផ.ស.ស ក្នុងម្នាក់<br>ចំនួនការងារក្នុងកសិ-ឧស្សាហកម្ម បែងចែកតាមយេនឌ័រ | . គណនេយ្យជាតិ<br>. ជំរឿនសេដ្ឋកិច្ច | នយោបាយ អន្តរជាតិ |
| **សមិទ្ធផល** | **គោលបំណង** | | | |
| ^^^^^^^^^^^ | បង្កើនការនាំចេញផលិតផលកែច្នៃកសិកម្ម (រាប់ទាំងផលិតផលកែច្នៃថ្មី ៗ) ឱ្យបានស្មើនឹង ១២% នៃការនាំចេញសរុបនៅឆ្នាំ ២០២៥ (គោលនយោបាយ អភិវឌ្ឍន៍វិស័យឧស្សាហកម្ម) និង ១៥% នៃការនាំចេញសរុបនៅឆ្នាំ ២០៣០។ (ការសម្រេចគោលបំណងនេះ នឹងចូលរួមចំណែក ដល់ការសម្រេចគោលបំណងរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យកម្ពុជាក្លាយ ជាប្រទេសមាន ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០) | អនុបាតនៃការនាំចេញកសិ-ឧស្សាហផលធៀបនឹងការនាំចេញសរុប (បែងចែកតាមមុខផលិតផល) | . គណនេយ្យជាតិ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ | ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក |
| **លទ្ធផល** | **គោលដៅយុទ្ធសាស្ត្រ** | | | |
| ^^^^^ | ជំរុញការកែច្នៃនិងបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ដែលឆ្លើយតបនឹងតម្រូវការទីផ្សារ ប្រកបដោយគុណភាពនិងសុវត្ថិភាព | - តម្លៃបន្ថែមដុល(GVA)នៃវិស័យក្រៅពីស្រូវ បែងចែកតាមអនុវិស័យ<br>- តម្លៃបន្ថែមនៃកសិ-ឧស្សាហកម្ម (រាប់ទាំងកិនស្រូវ) បែងចែកតាមអនុវិស័យ | . ក.ស.ក/ផា. ផែនការនិងស្ថិតិ<br>. វិទ្យាស្ថានជាតិស្ថិតិ<br>. អង្កេតកម្លាំងពលកម្ម | គគ្គាបម្រែបម្រួលអាកាសធាតុ |
| ^^^ | បង្កើតការងារនៅជនបទ ដែលប្រកបដោយគុណភាពនិងបរិយាប័ន្ន | ប្រាក់ឈ្នួលក្នុងកសិ-ឧស្សាហកម្ម (បែងចែកតាមយេនឌ័រ) | . គណនេយ្យជាតិ<br>. អង្កេតកម្លាំងពលកម្ម | កង្វះជំនាញនីជីថល និងភាសាអង់គ្លេស |
| **សកម្មភាព** | **សកម្មភាពយុទ្ធសាស្ត្រ** | | | |
| | ***ដំណាក់កាលទី១÷ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម)*** | | | |
| | ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាព របស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | . ចំនួនភាគីពាក់ព័ន្ធដែលបានពង្រឹងសមត្ថភាព<br>. ចំនួនលិខិតូបករណ៍ដែលបានដាក់ចេញ ដើម្បីឆ្លើយតបនឹងតម្រូវការ<br>. កម្រិតប្រសើរឡើងនៃសមត្ថភាព ធានាគុណភាពនិងសុវត្ថិភាពចំណីអាហារ | . របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនៃផែនការយុទ្ធសាស្ត្រ | . ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>. ជំនួយបច្ចេកទេសគ្រប់គ្រាន់ |
| | ២. កម្មវិធីផ្ទេរបច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | . ស្ថានភាពដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង(KMS) ដោយប្រើបច្ចេកវិជ្ជាឌីជីថល<br>. កម្រិតប្រសើរឡើងនៃដំណើរការគ្រប់គ្រងកសិ-ឧស្សាហកម្ម<br>. អត្រាកំណើននៃការប្រើប្រាស់បច្ចេកវិជ្ជាទំនើបនិងនវានុវត្តន៍ នៅក្នុងកសិ-ឧស្សាហកម្ម | | |
| | ៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | . ចំនួនមុខកសិ-ឧស្សាហផល ដែលបានអភិវឌ្ឍ ផលិត លក់ក្នុងទីផ្សារក្នុងស្រុក និងនាំចេញ<br>. ចំនួនមុខកសិ-ឧស្សាហផលដែលបាននាំចេញ | | |

| | | | | |
|---|---|---|---|---|
| **ដំណាក់កាលទី២៖ ការធ្វើពិពិធកម្ម និងបំប្លែងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៣-២០២៦ (ដំណាក់កាលវឌ្ឍនាការ កសិ-ឧស្សាហកម្ម)** | | | | |
| | ១. កម្មវិធីកសាង និងពង្រឹងសមត្ថភាព របស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | . ចំនួនភាគីពាក់ព័ន្ធដែលបានពង្រឹងសមត្ថភាព<br>. ចំនួនលិខិតូបករណ៍ដែលបានដាក់ចេញ ដើម្បីឆ្លើយតបនឹងតម្រូវការ<br>. កម្រិតប្រសើរឡើងនៃសមត្ថភាព ធានាគុណភាពនិងសុវត្ថិភាពចំណីអាហារ | . របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនៃផែនការយុទ្ធសាស្ត្រ | . ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>. ជំនួយបច្ចេកទេសគ្រប់គ្រាន់ |
| | ២. កម្មវិធីអភិវឌ្ឍន៍បច្ចេកវិទ្យា និងគ្រប់គ្រងចំណេះដឹង | . ស្ថានភាពដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង(KMS) ដោយប្រើបច្ចេកវិទ្យាឌីជីថល<br>. កម្រិតប្រសើរឡើងនៃដំណើរការគ្រប់គ្រងកសិ-ឧស្សាហកម្ម<br>. អត្រាកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងនវានុវត្តន៍ នៅក្នុងកសិ-ឧស្សាហកម្ម | | |
| | ៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល និងពង្រីកពាណិជ្ជកម្ម | . ចំនួនមុខកសិ-ឧស្សាហផល ដែលបានអភិវឌ្ឍ ផលិត លក់ក្នុងទីផ្សារក្នុងស្រុក និងនាំចេញ<br>. ចំនួនមុខកសិ-ឧស្សាហផលដែលបាននាំចេញ | | |
| **ដំណាក់កាលទី៣៖ ការផ្លាស់ប្តូរ និងនិងការបង្កើតថ្មីក្នុងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៧-២០៣០ (ដំណាក់កាលនវានុវត្តន៍ កសិ-ឧស្សាហកម្ម)** | | | | |
| | ១. កម្មវិធីនវានុវត្តលើសមត្ថភាព របស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | . ចំនួនភាគីពាក់ព័ន្ធដែលបានពង្រឹងសមត្ថភាព<br>. ចំនួនលិខិតូបករណ៍ដែលបានដាក់ចេញ ដើម្បីឆ្លើយតបនឹងតម្រូវការ<br>. កម្រិតប្រសើរឡើងនៃសមត្ថភាព ធានាគុណភាពនិងសុវត្ថិភាពចំណីអាហារ | . របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនៃផែនការយុទ្ធសាស្ត្រ | . ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>. ជំនួយបច្ចេកទេសគ្រប់គ្រាន់ |
| | ២. កម្មវិធីនវានុវត្តន៍បច្ចេកវិទ្យានិងគ្រប់គ្រងចំណេះដឹង | . ស្ថានភាពដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន (MIS) និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង(KMS) ដោយប្រើបច្ចេកវិទ្យាឌីជីថល<br>. កម្រិតប្រសើរឡើងនៃដំណើរការគ្រប់គ្រងកសិ-ឧស្សាហកម្ម<br>. អត្រាកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងនវានុវត្តន៍ នៅក្នុងកសិ-ឧស្សាហកម្ម | | |
| | ៣. កម្មវិធីនវានុវត្តន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | . ចំនួនមុខកសិ-ឧស្សាហផល ដែលបានអភិវឌ្ឍ ផលិត លក់ក្នុងទីផ្សារក្នុងស្រុក និងនាំចេញ<br>. ចំនួនមុខកសិ-ឧស្សាហផលដែលបាននាំចេញ | | |

ព័ត៌មាន/ទិន្នន័យ ដែលប្រមូលសម្រាប់គម្រោងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃធ្វើឡើងដោយអង្គភាពដែលអនុវត្តគម្រោង ហើយសម្រាប់កម្មវិធីត្រូវធ្វើឡើងដោយអង្គភាពដែលទទួលខុសត្រូវក្នុងអនុវត្តកម្មវិធីគ្របដណ្តប់គម្រោងទាំងនេះ។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ ត្រូវបានកំណត់ប្រគល់ឱ្យនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមានការគាំទ្រដោយអង្គភាពពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដើម្បីអាចអនុវត្តនូវការងារនេះបាន ក្នុងរយៈពេលមធ្យម និងរយៈពេលវែង នាយកដ្ឋានកសិ-ឧស្សាហកម្មនឹងត្រូវតែបំពាក់ជាមួយ និងធ្វើទំនើបកម្មប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្តោតលើការប្រើប្រាស់បច្ចេកវិជ្ជាព័ត៌មាន បង្កើនសមត្ថភាពបុគ្គលិក ភាគីពាក់ព័ន្ធ ព្រមទាំងបង្កើតបណ្តាញ និងភ្ជាប់ទំនាក់ទំនងជាមួយនឹងវិស័យឯកជនក្នុងការប្រមូល ផ្តល់ និងចែករំលែកព័ត៌មាន/ទិន្នន័យ ដាក់ឱ្យដំណើរការ និងថែរក្សាប្រព័ន្ធនោះ។ ការប្រមូលយោបល់ត្រលប់ និងគំនិតសាធារណជនជាទៀងទាត់ស្តីពីវិស័យនេះ និងផែនការយុទ្ធសាស្ត្រ ត្រូវបានដាក់ជាផ្នែកមួយនៃការអនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃក្នុងគ្រប់កម្រិត។

សូចនាករវាស់វែងសំខាន់ ដែលការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវយកមកប្រើសម្រាប់គម្រោង និងកម្មវិធី ត្រូវតែពាក់ព័ន្ធនឹងផ្នែកនៃគម្រោង និងកម្មវិធីទាំងនោះ។ ក្នុងកម្រិតមួយដែលអាចធ្វើទៅបាន សូចនាករវាស់វែងបែបនោះ ត្រូវតែមានទំនាក់ទំនង និងស្របនឹងផែនការយុទ្ធសាស្ត្រ (តារាងទី១៣)។

ថ្វីបើការប្រមូលព័ត៌មាន/ទិន្នន័យ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងត្រូវធ្វើឡើងដោយអង្គភាពនីមួយៗដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោង និងកម្មវិធីក្នុងកម្រិតផ្សេងៗ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលជាទូទៅ ការគ្រប់គ្រងព័ត៌មាន/ទិន្នន័យ ការតាមដាននិងវាយតម្លៃ និងរាប់ទាំងការទុកដាក់ឯកសារផងដែរនោះគួរប្រមូលផ្តុំនៅមជ្ឈមណ្ឌលកណ្តាលមួយ។ គេគួរប្រើប្រព័ន្ធស៊ើវើ(server) ឬកម្មវិធីរក្សាទុកនិងគ្រប់គ្រងទិន្នន័យនៅមជ្ឈមណ្ឌលកណ្តាល សម្រាប់ដាក់ដំណើរការក្នុងគោលបំណងនេះ។ ចំណុចនេះមានន័យថា រាល់អង្គភាពដែលទទួលខុសត្រូវចំពោះការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅគ្រប់កម្រិត នឹងត្រូវបានតភ្ជាប់ទៅនឹងប្រព័ន្ធស៊ើវើឬកម្មវិធីនោះ ដែលអាចជាប្រព័ន្ធមេគ្រប់គ្រងទិន្នន័យកសិ-ឧស្សាហកម្ម/កម្មវិធី ដែលភ្ជាប់ទៅនឹងប្រព័ន្ធទិន្នន័យស្ថិតិកសិកម្មថ្នាក់ជាតិ។ ប្រព័ន្ធទិន្នន័យមេនេះនឹងអាចផ្តល់ព័ត៌មាន/ទិន្នន័យទាន់ពេលវេលា ដែលអាចត្រូវបានពិនិត្យមើល ផ្ទៀងផ្ទាត់ និងដកស្រង់ក្នុងគោលបំណងធ្វើរបាយការណ៍ និងការវិភាគបឋម។

កម្មវិធីកុំព្យូទ័រប្រើសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវតែដូចគ្នាទាំងអស់សម្រាប់គ្រប់អង្គភាពអនុវត្ត និងក្នុងគ្រប់កម្រិត។ កម្មវិធីនោះមានដូចជា MS SQL Server, MS Access ឬ MS Excel។ ប្រហែលជា MS Excel អាចជាជម្រើសដ៏ល្អមួយ ដោយសារតែកម្មវិធីនេះងាយស្រួលប្រើ និងត្រូវបានគេប្រើប្រាស់ជាទូទៅ និងទម្លាប់សម្រាប់បុគ្គលិកទូទៅ និងសម្រាប់អ្នកប្រើប្រាស់កុំព្យូទ័រភាគច្រើន។

គេអាចប្រើបច្ចេកទេសស្ថិតិបែបពិណនា (descriptive statistics) និងស្ថិតិបែបសន្និដ្ឋាន (inferential statistics) ដើម្បីវិភាគនិងធ្វើរបាយការណ៍ដែលប្រើទិន្នន័យបរិមាណវិស័យ។ គេក៏អាចប្រើបច្ចេកទេសស្ថិតិខ្ពស់ជាងនេះបានផងដែរប្រសិនបើមានតម្រូវការ ទៅតាមអធ្យាស្រ័យរបស់អ្នកប្រើប្រាស់ និងគោលបំណងវិភាគលទ្ធផល។

ព័ត៌មាន/ទិន្នន័យ និងរបាយការណ៍ នៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងត្រូវបានចែកចាយឱ្យបានទៀងទាត់ និងទូលំទូលាយ។ ព័ត៌មាន/ទិន្នន័យ និងរបាយការណ៍ទាំងនោះអាចឱ្យសាធារណជនចូលមើលបាន។ របាយការណ៍ស្តីពីរបកគំហើញ និងលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងត្រូវបានផ្សព្វផ្សាយយ៉ាងហោចណាស់ពីរដងក្នុងមួយឆ្នាំ ហើយការចែកចាយនៃរបកគំហើញ និងលទ្ធផល នឹងត្រូវធ្វើឡើងជារៀងរាល់ឆមាស។ ការធ្វើបែបនេះអាចលើកកម្ពស់ការអនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដែលមានលក្ខណៈចូលរួម និងប្រកបដោយតម្លាភាព ដែលភាគីពាក់ព័ន្ធទាំងអស់ ទាំងដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសាធារណជនអាចចូលរួមបាន។ ការចែកចាយរបាយការណ៍ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ អាចធ្វើឡើងបានតាមរយៈវេទិកាសាធារណៈ វេទិការវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ គេហទំព័រ វិទ្យុ ទូរទស្សន៍ កាសែត កម្មវិធីទូរស័ព្ទដៃ ។ល។

របកគំហើញ និងលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃអាចត្រូវបានផលិតក្នុងទម្រង់ផ្សេងៗសម្រាប់ឱ្យសាធារណជនអាចអាន និងដោយផ្អែកលើប្រភេទនៃអ្នកអាន និងគោលបំណងនៃការប្រើប្រាស់ព័ត៌មានទាំងនេះ ដូចជាព្រឹត្តិបត្រព័ត៌មាន ខិត្តប័ណ្ណ ប័ណ្ណព័ត៌មាន គោលនយោបាយសង្ខេប របាយការណ៍លម្អិតស៊ីជម្រៅ ។ល។ គួរតែត្រូវបានផលិត និងចែកចាយ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានចងក្រងឡើង និងដាក់ឱ្យដំណើរការដោយមានលក្ខណៈងាយស្រួលប្រើ និងអាចឱ្យអ្នកប្រើប្រាស់ផលិតចេញជារបាយការណ៍សាមញ្ញធម្មតាដោយខ្លួនឯងបាន ប្រសិនបើចាំបាច់។

## ៩. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនេះ ជាផែនការរយៈពេលវែងនៃការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មនៅកម្ពុជា ដែលនឹងមានរយៈពេលរហូតដល់១២ឆ្នាំ ចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០៣០។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមដ៏សកម្មពីសំណាក់ដៃគូអភិវឌ្ឍន៍ (រួមទាំងអង្គការមិនមែនរដ្ឋាភិបាល) វិស័យឯកជន និងសហគមន៍កសិករ បានប្តេជ្ញាចិត្តនិងតាំងចិត្តយ៉ាងមុតមាំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

ផែនការយុទ្ធសាស្ត្រនេះ មានសង្គតិភាពយ៉ាងល្អទៅនឹង (១)គោលដៅ និងទស្សនវិស័យអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលលើវិស័យឧស្សាហកម្ម និង (២)គោលដៅ និងចក្ខុវិស័យអភិវឌ្ឍន៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើវិស័យកសិកម្ម។ ការបង្កើតផែនការនេះ ផ្អែកលើដំណើរការចូលរួម ដោយមានធាតុចូលពីភាគីពាក់ព័ន្ធសំខាន់ៗក្នុងអង្គភាពជំនាញនានារបស់រាជរដ្ឋាភិបាល បណ្តាដៃគូអភិវឌ្ឍន៍នានា សហគមន៍កសិករ និងវិស័យឯកជន និងផ្អែកលើទិន្នន័យជាប្រភេទទិន្នន័យបឋម និងទិន្នន័យស្រាប់។

អំឡុងពេល១២ឆ្នាំ ផែនការយុទ្ធសាស្ត្រនេះត្រូវបានបែងចែកចេញជា៣ដំណាក់កាល។ ដំណាក់កាលទី១ (២០១៩-២០២២) នឹងធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម។ នៅក្នុងដំណាក់កាលទី២ (២០២៣-២០២៦) កសិ-ឧស្សាហកម្មនឹងត្រូវបានធ្វើពិពិធកម្ម និងបំប្លែង។ នាចុងដំណាក់កាលទី២ កសិ-ឧស្សាហកម្មជាតិនឹងត្រូវឆ្លងកាត់អន្តរកាល និងអាចត្រៀមខ្លួនរួចរាល់សម្រាប់ដំណាក់កាលកាន់តែជឿនលឿនជាងមុន គឺដំណាក់កាលទី៣ (២០២៧-២០៣០)។ នៅក្នុងដំណាក់កាលចុងក្រោយ កសិ-ឧស្សាហកម្មនឹងកាន់តែផ្តោតខ្លាំងលើជំនាញ និងចំណេះដឹង

ដោយទាញយកប្រយោជន៍ពីបដិវត្តន៍ឧស្សាហកម្ម៤.០។ វិស័យនេះនឹងបន្តបង្កើតថ្មី និងច្នៃប្រឌិតខ្លួនឯងដើម្បីអាចឱ្យបន្តស្ថិតក្នុងការប្រកួតប្រជែង។

ហិរញ្ញប្បទានដើម្បីសម្រេចបានផែនការយុទ្ធសាស្ត្រនេះ គឺត្រូវការប្រហែល៣៨,១លានដុល្លារអាមេរិក។ ទំហំថវិកានេះនឹងត្រូវប្រើសម្រាប់គម្រោងចំនួន៥០។ ក្នុងដំណាក់កាលនេះ ក្រៅពីថវិកាដែលមានកម្រិតដែលត្រូវបានចាត់ចែងសម្រាប់កម្មវិធីពីមុនៗ របស់នាយកដ្ឋានកសិ-ឧស្សាហកម្ម ពុំមានប្រភពធនធានណាផ្សេងត្រូវបានកំណត់នោះទេ ដូច្នេះនឹងមានកង្វះខាតថវិកាច្រើនសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ ការអនុវត្តគម្រោងទាំងនេះ នឹងមិនអាចទៅរួចនោះទេ បើពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ហើយប្រការនោះនឹងអាចជះឥទ្ធិពលដល់ការសម្រេចផែនការយុទ្ធសាស្ត្រ។

ផែនការយុទ្ធសាស្ត្រនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ អំពីតម្រូវការសម្រាប់ការចូលរួម និងការវិនិយោគដ៏សកម្ម និងខ្លាំងក្លារបស់វិស័យឯកជន។ ផែនការនេះបានកត់សម្គាល់នូវសារសំខាន់នៃបរិយាកាសអំណោយផលដល់អាជីវកម្មថាជាមូលដ្ឋានគ្រឹះក្នុងការទាក់ទាញចំណាប់អារម្មណ៍ ការចូលរួម និងការវិនិយោគរបស់វិស័យឯកជន និងទទួលស្គាល់នូវការប្តេជ្ញាចិត្តមុតមាំ ក្នុងការបន្តធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលអាជីវកម្ម។ ថ្វីបើដូច្នេះ ផែនការនេះទាមទារអនុវត្តនូវសកម្មភាពមួយចំនួនខាងក្រោម÷

- ✓ ផលិតនិងចែកចាយឱ្យបានទូលំទូលាយនូវសេចក្តីវិភាគ និងសៀវភៅណែនាំពីឱកាសក្នុងវិនិយោគជាក់លាក់លើវិស័យកសិ-ឧស្សាហកម្ម
- ✓ បង្កើតនិងដាក់ដំណើរការនូវគេហទំព័រ និងកម្មវិធីទូរស័ព្ទដែលងាយស្រួលប្រើ ដែលលើកកម្ពស់ការវិនិយោគជាក់លាក់លើវិស័យកសិ-ឧស្សាហកម្ម
- ✓ ចាក់ផ្សាយស្ប៉តពាណិជ្ជកម្មលើប្រព័ន្ធផ្សព្វផ្សាយឯកជនដែលល្បីឈ្មោះទាំងថ្នាក់ជាតិ និងថ្នាក់ពិភពលោក ដែលបង្ហាញនូវឱកាសវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម
- ✓ រៀបចំឱ្យមានទំនាក់ទំនងជាទៀងទាត់ជាមួយដៃគូអភិវឌ្ឍន៍ និងស្ថានទូតបរទេសនៅកម្ពុជា ដើម្បីលើកកម្ពស់ការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម
- ✓ ធ្វើការនិងសម្របសម្រួលជាមួយមន្ត្រីផ្នែកពាណិជ្ជកម្មនៅក្នុងស្ថានទូតកម្ពុជានៅតាមបណ្តាប្រទេសផ្សេងៗដើម្បីលើកកម្ពស់ការវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម
- ✓ រៀបចំវេទិកាស្តីពីការវិនិយោគជាក់លាក់លើវិស័យកសិ-ឧស្សាហកម្ម ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដែលឱកាសវិនិយោគក្នុងវិស័យនេះត្រូវបានបង្ហាញ និងលើកកម្ពស់។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១÷ សាវតារកសិ-ឧស្សាហកម្មជាតិ

### ១. សាវតារ

កសិ-ឧស្សាហកម្មបានក្លាយជាផ្នែកមួយនៃសេដ្ឋកិច្ចកម្ពុជាអស់រយៈពេលជាយូរណាស់មកហើយ។ នៅចុងទសវត្សរ៍ទី៦០ កសិ-ឧស្សាហកម្មមានប្រហែលជា ៧៦% នៃឧស្សាហកម្មចំនួន ៣ ៧២៨ ដែលបានកត់ត្រានៅក្នុងប្រទេស។ ការវិវឌ្ឍនៃកសិ-ឧស្សាហកម្ម ស្រដៀងទៅនឹងឧស្សាហកម្មដទៃទៀតដែរ មានដំណើរការថយក្រោយក្នុងអំឡុងទសវត្សរ៍ទី៧០ និងទសវ្សរត្សរ៍ទី៨០ នៅពេលដែលប្រទេសកំពុងតែមានសង្គ្រាមស៊ីវិល។ ក្នុងអំឡុងពេលនោះ យោងតាមកំណត់ត្រាមួយចំនួន នៅកម្ពុជាមានកសិ-ឧស្សាហកម្មប្រមាណជា ២ ៦៨៦[៦] រួមទាំងអង្ករ ការកែច្នៃស្បៀងអាហារ ការកែច្នៃកៅស៊ូ ឧស្សាហកម្មផ្អែកលើព្រៃឈើ ។ល។ មកដល់ឆ្នាំ២០០៥ របាយការណ៍បង្ហាញថា នៅកម្ពុជាមានកសិធុរកិច្ចចំនួន ៤៥ ៨៩៤ សហគ្រាស ក៏ប៉ុន្តែក្នុងនោះ ៩១% សុទ្ធសឹងជាសហគ្រាសខ្នាតតូច ដែលមាននិយោជិតក្រោម៥នាក់ និងមានដើមទុនតិចជាង ១ ០០០ ដុល្លារអាមេរិក។

ថ្វីបើកសិ-ឧស្សាហកម្ម គឺជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិ ប៉ុន្តែវិស័យនេះនៅតែមិនទាន់អាចបញ្ចេញនូវភាពជោគជ័យ និងសក្តានុពលភាពរបស់ខ្លួនបានពេញលេញនៅឡើយ។ លទ្ធភាពនៃវិស័យនេះ ក្នុងការនាំមុខការអភិវឌ្ឍ សេដ្ឋកិច្ចជាតិនៅមិនទាន់បង្ហាញចេញជារូបរាងពេញលេញនៅឡើយ។

កាលពីសម័យមុន កសិ-ឧស្សាហកម្មជាតិជាទូទៅមានទម្រង់ជាសិប្បកម្មកែច្នៃលក្ខណៈគ្រួសារ។ មុនសង្គ្រាមក្នុងទសវត្សរ៍ទី៧០ និងទសវត្សរ៍ទី៨០ វិស័យនេះមានការអភិវឌ្ឍដ៏គួរឱ្យចាប់អារម្មណ៍មួយចំនួន។ ប៉ុន្តែ ជាអកុសល ការអភិវឌ្ឍបែបនេះត្រូវបានបំផ្លាញដោយសង្គ្រាមត្រជាក់ និងសង្គ្រាមស៊ីវិល ដែលនៅរ៉ាំរ៉ៃអស់រយៈពេលជាង២ទសវត្សរ៍ (រវាងទសវត្សរ៍ទី៧០ ដល់ទសវត្សរ៍ទី៩០)។

គេអាចសង្កេតឃើញនូវសកម្មភាពកសិ-ឧស្សាហកម្ម នៅគ្រប់កន្លែងនៅក្នុងប្រទេស នាសម័យបច្ចុប្បន្ន ប៉ុន្តែភាគច្រើនមានលក្ខណៈមីក្រូ និងទ្រង់ទ្រាយតូច ហើយវិសាលភាពនៃកសិ-ឧស្សាហកម្មក៏ងាយត្រូវបានសាធារណជន ឬក៏អ្នកពាក់ព័ន្ធអាចមានការយល់ច្រឡំផងដែរ។ ជាញឹកញាប់ ពេលដែលនិយាយដល់កសិ-ឧស្សាហកម្ម ប្រជាពលរដ្ឋភាគច្រើនច្រើនតែគិតដល់ការកែច្នៃស្បៀងអាហារ។ ក្នុងន័យទូលាយ កសិ-ឧស្សាហកម្មរួមបញ្ចូលសកម្មភាពជាច្រើនពាក់ព័ន្ធនឹងផលិតផលកសិកម្មក្រោយពេលប្រមូលផល។

[៦] ស្ថិតិនេះ មិនរាប់បញ្ចូលទាំងអ្នកជំនួញផ្នែកកសិកម្មដូចជា អ្នកជួញស្រូវ អ្នកជួញបន្លែ អ្នកនាំចេញស្រូវជាដើម។

## ២. ការងើបឡើងវិញនៃកសិ-ឧស្សាហកម្ម

សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍ផ្តល់ផលប៉ះពាល់ដល់វិស័យកសិ-ឧស្សាហកម្មក្នុងប្រទេស មិនត្រឹមតែលើហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិជ្ជានោះទេ ប៉ុន្តែក៏ប៉ះពាល់ដល់ការរស់រានមានជីវិតរបស់វិស័យនេះផងដែរ។ មកដល់ចុងទសវត្សរ៍ទី៩០ ការអភិវឌ្ឍប្រទេស និងគោលនយោបាយសាធារណៈ ត្រូវបានពន្យារដោយសារតែការអភិវឌ្ឍសង្គមជាមូលដ្ឋាន និងតម្រូវការជាមូលដ្ឋាន។ នៅក្នុងគោលនយោបាយនោះ សន្តិសុខស្បៀងអាហារគឺជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត មានន័យថាកម្ពុជាត្រូវផលិតស្រូវ និងត្រីឱ្យគ្រប់គ្រាន់ ដោយសារតែរបបអាហារក្នុងស្រុកភាគច្រើនគឺបាយនិងត្រី។ ក្នុងន័យនេះ ការគិតគូរពីគោលនយោបាយអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម នៅពុំទាន់បានគិតគូរស៊ីជម្រៅក្នុងដំណើរការបង្កើតគោលនយោបាយសាធារណៈ។

ខណៈដែលកម្ពុជាព្យាយាមដោះស្រាយបញ្ហាតម្រូវការមូលដ្ឋានរបស់ខ្លួន ក្នុងអំឡុងទសវត្សរ៍ទី៨០ និងដើមសតវត្សរ៍ទី២១ កសិ-ឧស្សាហកម្មនៅតែពុំសូវមានការនិយាយដល់ ក្រៅតែពីដំណើរការផលិតអង្ករទ្រង់ទ្រាយតូច និងការផលិតកៅស៊ូ។ ស្ថានភាពនេះចាប់ផ្តើមផ្លាស់ប្តូរ ពេលដែលរាជរដ្ឋាភិបាលអនុម័តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្នុងខែកក្កដា ឆ្នាំ២០១០។ គោលនយោបាយនេះ មានគោលបំណងបង្កើនតម្លៃដល់ការផលិតស្រូវលើសតម្រូវការសម្រាប់ការនាំចេញ និងដើម្បីឱ្យសេដ្ឋកិច្ចមានភាពចម្រុះ។ វិធានការជាច្រើនបានចែងក្នុងគោលនយោបាយនេះ និងបានផ្តោតលើការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មមួយចំនួន។

បន្ទាប់ពីមានការអនុម័តគោលនយោបាយនេះមក វិស័យកែច្នៃស្រូវអង្ករមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់។ យោងតាមការសិក្សាកន្លងមក សមត្ថភាពកិនស្រូវក្នុងស្រុកកើនឡើងពី៩៦តោន/ម៉ោង នៅពាក់កណ្តាលឆ្នាំ២០០៩ ដល់៨២៩តោន/ម៉ោង ក្នុងឆ្នាំ២០១៥។ ស្រដៀងគ្នានេះ សមត្ថភាពកែច្នៃសម្អាតអង្ករកើនឡើងច្រើនជាង៧ដង ពី៧២តោន/ម៉ោង នៅពាក់កណ្តាលឆ្នាំ២០០៩ ទៅ៥២០តោន/ម៉ោង ក្នុងឆ្នាំ២០១៤។ សមត្ថភាពនៃការកិននិងសម្អាតនេះអាចបន្តកើនឡើងនៅឆ្នាំបន្ទាប់ៗទៀតនាពេលខាងមុខ។ រោងម៉ាស៊ីនកិនស្រូវទាំងនេះ ភាគច្រើនមានទំហំតូចនិងមធ្យម ដែលត្រូវបានតម្លើងសម្រាប់អាជីវកម្មនាំចេញអង្ករ។ ចំណុចនេះមានន័យថា វិស័យកសិ-ឧស្សាហកម្ម គឺភាគច្រើនជាអាជីវកម្មរោងម៉ាស៊ីនកិនស្រូវ។

ក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មជាលើកដំបូង ដែលក្នុងនោះក៏មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍកសិ-ឧស្សាហកម្មជាតិផងដែរ ដោយបានចែងយ៉ាងជាក់លាក់ទាំងវិធានការនិងគោលដៅគោលនយោបាយសម្រាប់អភិវឌ្ឍន៍។ គោលដៅដែលបានកំណត់នោះគឺ “បង្កើនចំណែកនាំចេញនៃផលិតផលកសិកម្មកែច្នៃ (រួមទាំងផលិតផលកសិកម្មកែច្នៃថ្មី) ឱ្យបាន១២% នៃចំនួននាំចេញសរុបក្នុងឆ្នាំ២០២៥” ចាប់ផ្តើមពី ៧,៩% ក្នុងឆ្នាំ២០១៣។ គោលដៅប្រចាំឆ្នាំ គឺនៅថេរត្រឹម ៨% ក្នុងឆ្នាំ២០១៨ ១០% ក្នុងឆ្នាំ២០២០ និង១២% ក្នុងឆ្នាំ២០២៥។ អស់រយៈពេលជាងមួយឆ្នាំនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម មានការរាយការណ៍ថាការនាំចេញផលិតផលកសិកម្មកែច្នៃមានត្រឹមតែ៤,៦% នៃបរិមាណនាំចេញសរុបក្នុងឆ្នាំ២០១៦។ ចំណុចនេះគឺតិចជាងគោលដៅដែលរដ្ឋបានកំណត់។

# ៣. ស្ថានភាពបច្ចុប្បន្ននៃវិស័យកសិ-ឧស្សាហកម្ម

## ៣.១. ស្ថិតិវិស័យកសិ-ឧស្សាហកម្ម

នាពេលបច្ចុប្បន្ននេះ ស្ថិតិអំពីវិស័យកសិ-ឧស្សាហកម្មហាក់មានការខ្វះខាត។ ជំរឿនសហគ្រាសឆ្នាំ២០១១ បានបង្ហាញថា មានសហគ្រាសសរុបចំនួន ៥០៥ ១៣៤ នៅទូទាំងប្រទេស រាប់ទាំងសហគ្រាសដែលមានសកម្មភាពទាក់ទងនឹងការកែច្នៃវត្ថុធាតុដើមពីកសិផលផងដែរ។ ៨០% នៃគ្រឹះស្ថាន/សហគ្រាសទាំងនេះ គឺមានទ្រង់ទ្រាយតូចដែលមានត្រឹមតែមនុស្សធ្វើការតែម្នាក់ ឬ ២ នាក់ប៉ុណ្ណោះ។ គ្រឹះស្ថានដែលមានមនុស្សធ្វើការពី ៥ ទៅ ៩ នាក់ មាន ៧,៨% និងគ្រឹះស្ថានដែលមានមនុស្សធ្វើការពី ១០ ទៅ ៩៩ នាក់ មានត្រឹមតែ ២,៦% តែប៉ុណ្ណោះ។ ដូច្នេះ និយាយជារួម ភាគច្រើនលើសលប់ (ប្រហែល ៨៨%) នៃគ្រឹះស្ថាន/សហគ្រាសក្នុងស្រុក គឺមានទំហំមីក្រូនិងតូច។

ផ្អែកតាមព័ត៌មានកសិ-ឧស្សាហកម្មតាមបណ្តាខេត្ត ដែលចងក្រងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដើម្បីគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រនេះ កម្ពុជាមានសហគ្រាសកសិ-ឧស្សាហកម្មយ៉ាងហោចចំនួន ៣ ២៣៤[៧] ដែលកំពុងដំណើរការ ហើយភាគច្រើន (៧៨%)ជារោងម៉ាស៊ីនកិនស្រូវ។ មានតែមួយចំនួនតូចប៉ុណ្ណោះនៃរោងចក្រទាំងនេះ ដែលជាអាជីវកម្មកសិ-ឧស្សាហកម្ម ជាពិសេសរោងម៉ាស៊ីនផលិតចំណីសត្វ ដូចជាក្រុមហ៊ុន CP និង GreenFeed ដែលមានទ្រង់ទ្រាយធំ។ ជារួម ស្ទើរតែទាំងអស់នៃគ្រឹះស្ថាន/សហគ្រាសទាំងនេះ ត្រូវបានចាត់ថ្នាក់ថាជាគ្រឹះស្ថានមីក្រូ/បែបគ្រួសារ តូច និងមធ្យម។

## ៣.២. តួនាទីវិស័យកសិ-ឧស្សាហកម្មក្នុងសេដ្ឋកិច្ចជាតិ

កង្វះការអភិវឌ្ឍកសិ-ឧស្សាហកម្ម អាចជាកត្តារាំងដល់កម្ពុជា ក្នុងការជំរុញកំណើនវិស័យឧស្សាហកម្មឱ្យបានរីកចម្រើនដល់សក្តានុពលជាអតិបរមា នៅត្រង់ថាផលិតផលកសិកម្មត្រូវបាននាំចេញ ក្នុងទម្រង់ជាកសិផលស្រស់ ឬយ៉ាងច្រើនក្នុងទម្រង់ពាក់កណ្តាលសម្រេច (ដូចជា កៅស៊ូក្រេប ចំណិតដំឡូងមីក្រៀម)។ កម្ពុជាផលិតបានស្រូវប្រហែលជា ១០,៥លានតោន ក្នុងឆ្នាំ២០១៨ និងបាននាំចេញជាអង្ករផ្លូវការប្រមាណជាង ០,៦លានតោន។ នេះមានន័យថាកម្ពុជាបាននាំចេញស្រូវប្រហែលជា ៣,៨លានតោន ក្នុងឆ្នាំ២០១៨ បន្ទាប់ពីផាត់ចេញបរិមាណតម្រូវការក្នុងស្រុករួចហើយនោះ។ ក្នុងករណីដំឡូងមីវិញ កម្ពុជាបាននាំចេញគិតជាទឹកប្រាក់ប្រហែលជា ៧២៨លានដុល្លារ ដោយបូករួមទាំងមើមដំឡូងមីស្រស់និងចំណិតដំឡូងមីក្រៀម។ ចំណែកឯស្វាយចន្ទី គេឃើញថាគ្រាប់ស្វាយចន្ទីប្រមាណ ២៣ ៦១៧,៥តោន ដែលបានផលិតក្នុងឆ្នាំ២០១៧/២០១៨ ត្រូវបាននាំចេញដោយសាររោងចក្រកែច្នៃក្នុងប្រទេសពុំមានលទ្ធភាពស្រូបយកអស់។[៨]

---

[៧] *ស្ថិតិនេះត្រូវបានរាយការណ៍ដោយខេត្តចំនួន ១៣ប៉ុណ្ណោះ។ ខេត្តដែលគ្មានរបាយការណ៍រួមបញ្ចូលទាំង ភ្នំពេញ កំពង់ចាម កណ្តាល ស្វាយរៀង កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង ក្រចេះ ស្ទឹងត្រែង បន្ទាយមានជ័យ ព្រះសីហនុ និងកោះកុង។*

[៨] *ក្នុងឆ្នាំ២០១០ អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ(IFC) បានប៉ាន់ប្រមាណថាការកែច្នៃគ្រាប់ស្វាយចន្ទីអាចបន្ថែមតម្លៃ ៣០-៤០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ខណៈដែលគ្រាប់ស្វាយចន្ទីដែលមានសម្បកត្រូវបានគណនាថាមាន ៦០ ០០០តោន។ បច្ចុប្បន្ន មានរោងចក្រកែច្នៃស្វាយចន្ទី ខ្នាតមីក្រូនិងតូចដែលកំពុងដំណើរការចំនួន ៣ នៅក្នុងប្រទេស។ រោងចក្រខ្នាតតូចមួយស្ថិតក្នុងខេត្តត្បូងឃ្មុំ បាននាំចេញ*

ថ្វីបើវិស័យកសិ-ឧស្សាហកម្មរបស់កម្ពុជា ពុំទាន់អាចផ្តល់ផលឱ្យបានពេញទំហំសក្តានុពលរបស់ខ្លួន ក៏ប៉ុន្តែវិស័យនេះបានរួមចំណែកទៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ វិស័យនេះនាំទង់ជាតិកម្ពុជាទៅកាន់វេទិកាពាណិជ្ជកម្មពិភពលោក (ជាពិសេសឧស្សាហកម្មអង្ករក្រអូប) បន្ថែមតម្លៃដល់ទំនិញកសិកម្ម និងធ្វើឱ្យផលិតផលស្បៀងអាហារកាន់តែមានភាពចម្រុះក្នុងទីផ្សារជាតិ បង្កើតការងារ និងទទួលបានរូបិយប័ណ្ណបរទេស។ អំឡុងឆ្នាំ២០១០-២០១៧ តម្លៃនាំចេញនៃផលិតផលកសិកម្មកែច្នៃ បង្ហាញនូវនិន្នាការកំណើន (តារាងទី១៤)។ ចំណែកនៃវិស័យនេះនៅក្នុងផលិតផលក្នុងស្រុកសរុបបានកើនឡើងពី ១,៤% ក្នុងឆ្នាំ២០១០ ដល់ ៣,៦% ក្នុងឆ្នាំ២០១៧។

តម្លៃនាំចេញនៃផលិតផលកសិកម្មកែច្នៃកើនឡើងពី ១៦៤,៩ លានដុល្លារ ក្នុងឆ្នាំ២០១០ ដល់ ៨០៥,៦ លានដុល្លារ ក្នុងឆ្នាំ២០១៧ បើទោះបីជាមានការធ្លាក់ចុះយ៉ាងខ្លាំងក្នុងឆ្នាំ២០១៥ និង២០១៦ ក៏ដោយ។ ចំណែកនៃវិស័យនេះក្នុងតម្លៃនាំចេញសរុប គឺត្រឹមតែ ៧,២% ប៉ុណ្ណោះក្នុងឆ្នាំ២០១៧ ដែលទាបជាងគោលដៅដែលបានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មបន្តិច។ កំណើនប្រចាំឆ្នាំរបស់វិស័យនេះ ត្រូវបានប៉ាន់ស្មានមានចំនួន ២៥% ក្នុងអំឡុងឆ្នាំ២០១០-២០១៧។ ដើម្បីអាចឱ្យសម្រេចបានតាមគោលដៅដែលកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម គួរតែមានកំណើនជាមធ្យម ៣៥% ក្នុងមួយឆ្នាំក្នុងអំឡុងពេលវេលានេះ។ ក្នុងឆ្នាំ២០១៥ គោលដៅដែលកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មគឺ ១២% ដែលមានន័យថាតម្លៃនាំចេញនៃផលិតផលកសិកម្មកែច្នៃ ត្រូវតែកើនឡើងយ៉ាងហោចណាស់ ១៨% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលវេលា ឆ្នាំ២០១៧ ដល់ ២០២៥។

តារាងទី១៤. ការនាំចេញរបស់កម្ពុជាអំឡុងឆ្នាំ២០១០-២០១៨ (លានដុល្លារអាមេរិក)

| ល.រ. | មុខទំនិញកសិ-ឧស្សាហកម្ម | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 |
|---|---|---|---|---|---|---|---|---|---|---|
| 1 | ឈើមូល ឬឈើអារ | 30.78 | 45.81 | 27.66 | 64.55 | 123.29 | 25.41 | 5.22 | 10.24 | 41.77 |
| 2 | ឈើសន្លឹក | 0.52 | 0.34 | 0.27 | 0.63 | 0.06 | 0.83 | 0.24 | 0.15 | 0.52 |
| 3 | ការកងបាកេ | 0.25 | 1.06 | 1.67 | 2.41 | 8.60 | 1.47 | 0.10 | 0.21 | 16.66 |
| 4 | ផលិតផលផ្សេងទៀតពីឈើ | 2.65 | 1.58 | 1.55 | 5.96 | 0.08 | 20.24 | 40.21 | 100.23 | 94.78 |
| 5 | អង្ករ | 34.52 | 106.56 | 135.99 | 262.27 | 248.50 | 315.30 | 300.77 | 329.59 | 413.57 |
| 6 | កៅស៊ូក្រែប | 89.33 | 197.63 | 164.43 | 175.17 | 154.93 | 165.39 | 165.29 | 254.15 | 208.02 |
| 7 | ស្ករ | - | - | - | - | - | - | - | 37.92 | 81.80 |
| 8 | ផលិតផលជលផល | 2.70 | 3.12 | 1.69 | 1.18 | 0.79 | 0.51 | 0.71 | 0.59 | 1.23 |
| 9 | កសិផលផ្សេងទៀត | 4.10 | 5.95 | 13.58 | 42.36 | 89.12 | 21.27 | 20.45 | 72.54 | 105.30 |
| 10 | ទំនិញផ្សេងពីកសិ-ឧស្សាហកម្ម | 3,465.29 | 4,567.44 | 5,226.96 | 6,428.48 | 7,480.58 | 8,707.32 | 9,524.43 | 10,334.81 | 11,734.49 |
| | ទឹកប្រាក់នាំចេញសរុប | 3,630.15 | 4,929.49 | 5,573.81 | 6,983.01 | 8,105.96 | 9,257.74 | 10,057.41 | 11,140.44 | 12,698.15 |
| | ផ.ស.ស | 11,634.02 | 12,965.31 | 14,054.44 | 15,228.94 | 16,733.70 | 18,241.66 | 20,159.27 | 22,180.38 | 24,578.83 |
| | | | | | | | | | | |
| | ទំនិញកសិឧស្សាហកម្ម | 164.9 | 362.0 | 346.9 | 554.5 | 625.4 | 550.4 | 533.0 | 805.6 | 963.7 |
| | %ទឹកប្រាក់នាំចេញ | 4.5% | 7.3% | 6.2% | 7.9% | 7.7% | 5.9% | 5.3% | 7.2% | 7.6% |
| | %ផ.ស.ស | 1.4% | 2.8% | 2.5% | 3.6% | 3.7% | 3.0% | 2.6% | 3.6% | 3.9% |

ប្រភពទិន្នន័យ៖ វិទ្យាស្ថានស្ថិតិជាតិ/ក្រសួងផែនការ ឆ្នាំ២០១៩។

ថ្វីបើកសិ-ឧស្សាហកម្ម ជាទូទៅមិនទាន់ជឿនលឿននៅឡើយ ប្រភេទកសិ-ឧស្សាហកម្មមួយចំនួន ដូចជារោងម៉ាស៊ីនកិនស្រូវ និងការកែច្នៃថ្នាំជក់ គឺមានការអភិវឌ្ឍ មានរចនាសម្ព័ន្ធជាក់លាក់ និងរៀបចំត្រឹមត្រូវ។

---

*គ្រាប់ស្វាយចន្ទីកែច្នៃរួចទៅប្រទេសនៅមជ្ឈិមបូព៌ា។ រោងចក្រខ្នាតមីក្រូមួយនៅខេត្តត្បូងឃ្មុំ និងកន្លែងកែច្នៃខ្នាតមីក្រូមួយទៀតនៅក្នុងខេត្តកំពង់ចាម ទីតាំងទាំងពីរនេះកែច្នៃគ្រាប់ស្វាយចន្ទីសម្រាប់ទីផ្សារក្នុងស្រុក។ សហគមន៍កសិកម្មស្វាយចន្ទីនៅក្នុងខេត្តកំពង់ធំ កំពុងតែព្យាយាមស្តារលទ្ធភាពកែច្នៃរបស់ខ្លួន។ មានការតម្លើងរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីមួយទៀតនៅខេត្តព្រះវិហារ ដែលមានគោលបំណងនាំចេញគ្រាប់ស្វាយចន្ទីកែច្នៃទៅប្រទេសជប៉ុន។*

ខណៈដែលឧស្សាហកម្មផលិតថ្នាំជក់ ស្ទើរតែត្រូវបានផ្ដាច់មុខដោយក្រុមហ៊ុនប្រ៊ីធីស អ៊ីមើរីខិន ថឹប៉ែកខូ (ខេមបូឌា) លីមីតធីត និងរោងម៉ាស៊ីនកិនស្រូវដែលមានភាពប្រកួតប្រជែងខ្ពស់។ បន្ទាប់ពីអង្ករ និងថ្នាំជក់ វិស័យកៅស៊ូក៏មានការរៀបចំបានយ៉ាងត្រឹមត្រូវផងដែរ។ ជាអកុសល វិស័យឧស្សាហកម្មកៅស៊ូនៅមិនទាន់ឆ្លងឱ្យហួសពីដំណាក់កាលផលិត និងកែច្នៃកម្រិតបឋមនៅឡើយ។ ថ្វីបើកម្ពុជាមានចម្ការកៅស៊ូជិត០,៥លានហិកតាក៏ដោយ ប៉ុន្តែកម្ពុជាមិនមានរោងចក្រសម្រាប់ផលិតទំនិញសម្រេចពីវត្ថុធាតុដើមកៅស៊ូ (ដូចជាកាធុនបោកខោអាវ ឧបករណ៍ក្មេងលេង កៅស៊ូកងកង់ឡាន ស្បែកជើង ស្រោមដៃ ស្បែកជើងកវែង ឧបករណ៍វេជ្ជសាស្ត្រជាដើម) នៅឡើយ។ កម្ពុជាផលិតបាននូវផលិតផលពាក់កណ្ដាលកែច្នៃជាចម្បង ដូចជាកៅស៊ូក្រេប និងកៅស៊ូសន្លឹក។

## ៣.៣. បញ្ហាប្រឈមនៃការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម

ក្រោយពីអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរួចមក មានកិច្ចខិតខំប្រឹងប្រែង និងស្វែងរកធនធានជាច្រើនសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធផ្សេងៗ ដើម្បីទាក់ទាញវិនិយោគ និងសម្របសម្រួលការអភិវឌ្ឍនៃវិស័យឧស្សាហកម្ម រួមទាំងកសិ-ឧស្សាហកម្មផងដែរ។ រាជរដ្ឋាភិបាល និងសាមីស្ថាប័នបានធ្វើការយ៉ាងសស្រាក់សស្រាំ និងធ្វើអ្វីគ្រប់យ៉ាងតាមសមត្ថភាពរបស់ខ្លួន ជាមួយនឹងធនធានដែលមានដើម្បីធ្វើឱ្យឡូជីស្ទីករបស់ប្រទេសកាន់តែប្រសើរឡើង និងដើម្បីធ្វើអាជីវកម្មកាន់តែងាយស្រួលជាងមុន។ ថ្វីបើមានដំណើរការគួរជាទីសង្ឃឹម និងការប្ដេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលយ៉ាងណាក្ដី កម្ពុជានៅតែត្រូវប្រឈមនឹងគូប្រជែងដែលជាអ្នកនាំចេញផលិតផលកសិកម្មដ៏សំខាន់ៗក្នុងតំបន់ និងនៅក្នុងពិភពលោក ជាពិសេសវៀតណាមនិងថៃ។

ជាក់ស្ដែង ខណៈដែលកម្ពុជាកំពុងតែធ្វើការដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែង ប្រទេសនៅក្នុងតំបន់ និងនៅពិភពលោក រួមទាំងប្រទេសជិតខាង ដូចជាវៀតណាមនិងថៃ ក៏ធ្វើការយ៉ាងខ្លាំងក្លាដើម្បីបង្កើនលទ្ធភាពប្រកួតប្រជែងរបស់ខ្លួនផងដែរ។ ដូច្នេះ ប្រសិនបើកម្ពុជាចង់ប្រកួតប្រជែងនៅក្នុងទីផ្សារថ្នាក់តំបន់ និងថ្នាក់សកល កម្ពុជាត្រូវមានលទ្ធភាពប្រកួតប្រជែងដូចជាឬលើសបណ្ដាប្រទេសទាំងនោះ។ លើកលែងតែកម្ពុជាខិតខំធ្វើការឱ្យកាន់តែខ្លាំងឡើងៗ បើពុំនោះសោត កម្ពុជានឹងនៅពីក្រោយទាំងវៀតណាមនិងថៃ ក្នុងរយៈពេលដ៏យូរអង្វែងក្នុងពេលអនាគតខាងមុខ។

សូចនាករចំនួនពីរ គឺភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម និងឡូជីស្ទីក ដែលសិក្សាដោយធនាគារពិភពលោកដើម្បីវាស់វែងឧត្ដមភាពប្រកួតប្រជែងរបស់ប្រទេសក្នុងពិភពលោក បង្ហាញថាកម្ពុជានៅពីក្រោយដាច់ឆ្ងាយ ទាំងវៀតណាម និងថៃឡង់ដ៏។ រីឯភាពងាយស្រួលនៃការធ្វើអាជីវកម្ម (តារាងទី១៥) កម្ពុជាមានចំណាត់ថ្នាក់លើសតែប្រទេសឡាវតែមួយទេ។ ក្នុងវង្វង់ឡូជីស្ទីក កម្ពុជាមានចំណាត់ថ្នាក់លើសតែប្រទេសឡាវនិងមីយ៉ាន់ម៉ាប៉ុណ្ណោះ (តារាងទី១៦)។ នេះជាបញ្ហាប្រឈមយ៉ាងខ្លាំងសម្រាប់កម្ពុជា ដើម្បីទាក់ទាញការវិនិយោគសំខាន់ៗ សម្រាប់វិស័យឧស្សាហកម្ម/កសិ-ឧស្សាហកម្ម ដែលប្រើទុននិងបច្ចេកវិជ្ជាច្រើន និងតម្រូវឱ្យមានការប្ដេជ្ញាចិត្តរយៈពេលវែងពីអ្នកវិនិយោគ។ ដូច្នេះ ទោះបីជាចូលចិត្ត ឬមិនចូលចិត្តក៏ដោយ វត្ថុធាតុដើមដែលផលិតដោយវិស័យកសិកម្ម នឹងបន្តហូរចូលទៅកាន់រោងចក្រកែច្នៃកសិ-ឧស្សាហកម្ម ដែលនៅក្នុងបណ្ដាប្រទេសជិតខាងទាំងនេះដោយផ្ទាល់ ដោយសារមានតម្រូវការច្រើន។

**តារាងទី១៥. ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម (ចម្ងាយទៅកាន់ច្រកទ្វារព្រំដែន)**

| ប្រទេស | ២០១៤<br>ពិន្ទុ (លំដាប់) | ២០១៥<br>ពិន្ទុ (លំដាប់) | ២០១៦<br>ពិន្ទុ (លំដាប់) | ២០១៩<br>ពិន្ទុ (លំដាប់) |
|---|---|---|---|---|
| ម៉ាឡេស៊ី | ...(៦) | ៧៨,៨៣ (១៨) | ៧៩,១៣ (១៨) | ៨០,៦០ (១៥) |
| ថៃ | ... (១៨) | ៧៥,២៧ (២៦) | ៧១,៤២ (៤៩) | ៧៨,៤៥ (២៧) |
| វៀតណាម | ... (៩៩) | ៦៤,៤២ (៧៨) | ៦២,១០ (៩០) | ៦៨,៣៦ (៦៩) |
| ឥណ្ឌូណេស៊ី | ... (១២០) | ៥៩,១៥ (១១៤) | ៥៨,១២ (១០៩) | ៦៧,៩៦ (៧៣) |
| **មធ្យមភាគថ្នាក់តំបន់** | **... (៨៨)** | **៦៣,១៩ (៩២)** | **៦១,៤៧ (៩៦)** | **៦៣,៤១ (...)** |
| ហ្វីលីពីន | ... (១០៨) | ៦២,០៨ (៩៥) | ៦០,០៧ (១០៣) | ៥៧,៦៨ (១២៤) |
| កម្ពុជា | ... (១៣៧) | ៥៥,៣៣ (១៣៥) | ៥២,២២ (១២៧) | ៥៤,៨ (១៣៨) |
| ឡាវ | ... (១៥៩) | ៥១,៥៤ (១៤៨) | ៥៣,៧៧ (១៣៤) | ៥១,២៦ (១៥៤) |

ប្រភព៖ របាយការណ៍ភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម របស់ធនាគារពិភពលោក។

លំហូរចូលនៃវត្ថុធាតុដើមក្នុងវិស័យកសិកម្មតាមច្រកទ្វារព្រំដែន មានន័យថាកម្ពុជាបានបាត់បង់ឱកាស និងតម្លៃបន្ថែមទៅក្នុងសេដ្ឋកិច្ចរបស់ខ្លួន។ ចំណុចនេះជាមូលហេតុដែលគោលដៅកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មសម្រាប់កសិ-ឧស្សាហកម្ម ដូចជាមិនអាចសម្រេចបាន ថ្វីបើមានកិច្ចខិតខំប្រឹងប្រែងជាច្រើនបានធ្វើឡើងដើម្បីអនុវត្តតាមគោលដៅនេះយ៉ាងណាក្តី។ ក៏ប៉ុន្តែ ដោយសារតែកម្រិតនៃភាពប្រកួតប្រជែងរបស់កម្ពុជាចាប់ផ្តើមពីដំបូងឡើងនៅមានកម្រិតនោះ លទ្ធភាពប្រកួតប្រជែងរបស់កម្ពុជានឹងបន្តដើរតាមក្រោយគូប្រកួតប្រជែងរបស់ខ្លួន។ និន្នាការនេះនឹងមិនងាយប្រែផ្លាស់មកវិញក្នុងរយៈពេលយ៉ាងយូរតទៅមុខទៀតនោះទេ វៀរលែងតែមានកិច្ចខិតខំប្រឹងប្រែងដ៏សម្បើម និងខុសប្លែកពីមុន។

**តារាងទី១៦. ពិន្ទុភាពងាយស្រួលក្នុងការសម្រួលឡជីស្ទីក សរុប និងតាមលំដាប់**

| ឆ្នាំ | ២០១២ | | ២០១៤ | | ២០១៦ | | ២០១៨ | |
|---|---|---|---|---|---|---|---|---|
| ប្រទេស | ពិន្ទុ | លំដាប់ | ពិន្ទុ | លំដាប់ | ពិន្ទុ | លំដាប់ | ពិន្ទុ | លំដាប់ |
| សិង្ហបុរី | ៤,១៣ | ១ | ៤,០០ | ៥ | ៤,១៤ | ៥ | ៤,០០ | ៧ |
| ម៉ាឡេស៊ី | ៣,៤៩ | ២៩ | ៣,៥៩ | ២៥ | ៣,៤៣ | ៣២ | ៣,២២ | ៤១ |
| ថៃ | ៣,១៨ | ៣៨ | ៣,៤៣ | ៣៥ | ៣,២៦ | ៤៥ | ៣,៤១ | ៣២ |
| ហ្វីលីពីន | ៣,០២ | ៥២ | ៣,០០ | ៥៧ | ២,៨៦ | ៧១ | ២,៩០ | ៦០ |
| វៀតណាម | ៣,០០ | ៥៣ | ៣,១៦ | ៤៨ | ២,៩៨ | ៦៤ | ៣,២៧ | ៣៩ |
| ឥណ្ឌូនេស៊ី | ២,៩៤ | ៥៩ | ៣,០៨ | ៥៣ | ២,៩៨ | ៦៣ | ៣,១៥ | ៤៦ |
| កម្ពុជា | ២,៥៦ | ១០១ | ២,៧៤ | ៨៣ | ២,៨០ | ៧៣ | ២,៥៨ | ៩៨ |
| ឡាវ | ២,៥០ | ១០៩ | ២,៣៩ | ១៣១ | ២,០៧ | ១៥២ | ២,៧០ | ៨២ |
| មីយ៉ាន់ម៉ា | ២,៣៧ | ១២៩ | ២,២៥ | ១៤៥ | ២,៤៦ | ១១៣ | ២,៣០ | ១៣៧ |

ប្រភព៖ ទិន្នន័យ LPI របស់ធនាគារពិភពលោក។

### ៣.៤. ឱកាសសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្ម

ឱកាសមាសសម្រាប់កសិ-ឧស្សាហកម្មនៅតែមាន ថ្វីបើជួបការប្រឈមយ៉ាងណាក្តី។ ការប្តេជ្ញាដោះស្រាយក្នុងលក្ខណៈជាប្រព័ន្ធនូវបញ្ហាប្រឈមនានា ដូចដែលរាជរដ្ឋាភិបាលបានអនុវត្តនាពេលថ្មីៗនេះ ជាកត្តាសត្យានុម័តដើម្បីចាប់យកឱកាសមាសនេះ។ បរិយាកាសអំណោយផលដល់អាជីវកម្មត្រូវបានធ្វើឱ្យប្រសើរឡើង ហើយថ្លៃដើមក្នុងការធ្វើអាជីវកម្មក៏ត្រូវបានកាត់បន្ថយផងដែរ។ ជាក់ស្តែង ការប្តេជ្ញានេះត្រូវបានសឱ្យឃើញតាមរយៈចំណាត់ការសម្រួលបរិយាកាសធុរកិច្ចមួយចំនួន ជាអាទិ៍៖ (១)ការរំសាយកាំកុងត្រូលតាមច្រកទ្វារព្រំដែន (២)ការរំសាយកាំសាបពីច្រកទ្វារកំពង់ផែសមុទ្រ (៣)ការលុបចោលតម្រូវការវិញ្ញាបនបត្រប្រភពដើមទំនិញ ដែលនឹងជួយកាត់បន្ថយថ្លៃដើមពាណិជ្ជកម្មបន្ថែមទៀត ជាពិសេសសម្រាប់ការនាំចេញ។ ការដាក់ចេញនូវអនុក្រឹត្យលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យម កាលពីចុងឆ្នាំមុនក៏បានលើកទឹកចិត្តការអភិវឌ្ឍ និងការវិនិយោគលើកសិ-ឧស្សាហកម្ម និងសហគ្រាសខ្នាតតូចនិងមធ្យមផងដែរ។ ការបង្កើតធនាគារសហគ្រាសធុនតូចនិងមធ្យម ដែលស្ថិតក្នុងដំណាក់កាលរៀបចំឡើងនេះ ក៏នឹងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍនេះផងដែរ។

ការប្តេជ្ញានេះអាចទម្លាយនូវចំណុចកជប ដែលរាំងស្ទះដល់ការបង្កើនឧត្តមភាពសេដ្ឋកិច្ចជាតិ និងបើកផ្លូវឱ្យវិស័យឧស្សាហកម្មអាចចាក់ឫសលូតលាស់ដល់សក្តានុពលជាអតិបរមា។ ដើម្បីអាចធានាបាននូវចំណុចនេះ គឺតម្រូវឱ្យមានផែនការយុទ្ធសាស្ត្រមួយផ្តោតលើបញ្ហា ដើម្បីអាចនាំដំណើរការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដោយគិតពីក្របខ័ណ្ឌស្ថាប័នដែលមានស្រាប់ **និងធ្វើការផ្លាស់ប្តូរឱ្យទៅជាវប្បធម៌** ដើម្បីអាចឱ្យកសិ-ឧស្សាហកម្មកម្ពុជាអាចមានលទ្ធភាពប្រកួតប្រជែងបាន។ ***ផែនការយុទ្ធសាស្ត្រ ត្រូវតែធ្វើឱ្យវិស័យកសិ-ឧស្សាហកម្មកម្ពុជាអាចប្រកួតប្រជែង និងដើរតាមទីផ្សារ ដែលនឹងទប់ស្កាត់លំហូរវត្ថុធាតុដើមកុំឱ្យហូរទៅកាន់ប្រទេសជិតខាង។***

ក្នុងដំណើរការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម កម្ពុជាអាចរៀនសូត្រពីការអភិវឌ្ឍវិស័យអង្ករ (អត្ថបទទី៣)។ មេរៀនសំខាន់បំផុត បានមកពីគោលនយោបាយស្តីពីការផលិតស្រូវ និងការនាំចេញអង្ករឆ្នាំ២០១០ មានដូចជា (១) គោលនយោបាយនោះត្រូវបានចងក្រងឡើងដោយគ្មានកិច្ចពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយនឹងវិស័យឯកជន និងកសិករ (២)ពុំបានផ្តល់ចក្ខុវិស័យច្បាស់លាស់ដែលបញ្ចូលនូវចីរភាពនៃវិស័យនេះ និងគោលដៅសម្រាប់តម្លៃនៃការនាំចេញ តម្លៃបន្ថែម និងចំណូលកសិដ្ឋាន និង (៣) ពុំបានបង្កើតប្រព័ន្ធតាមដាននិងវាយតម្លៃងករាជ្យ និងទៀងទាត់ (ស្រង់ពីឯកសាររបស់លោកហ្វ្រង់សេស្វូ និងលោក ស្រី ចន្ទី ឆ្នាំ២០១៦)។

## ៤. សេចក្តីសន្និដ្ឋាន

យោងតាមប្រវត្តិសាស្ត្រ កសិ-ឧស្សាហកម្មគឺជាផ្នែកមួយនៃសេដ្ឋកិច្ចជាតិ។ វិស័យនេះបានរីកចម្រើនខ្លាំងនិងមានសហគ្រាសយ៉ាងច្រើនអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ គឺមុនសម័យសង្គ្រាម។ មកដល់ឆ្នាំ២០០៥ សហគ្រាសកសិ-ឧស្សាហកម្មចំនួន ៤៥ ៨៩៤ ត្រូវបានកត់ត្រា ដោយក្នុងនោះ ៩១% គឺជាសហគ្រាសខ្នាតតូច។ បច្ចុប្បន្ននេះ មានសហគ្រាសកសិ-ឧស្សាហកម្មចំនួនជាង ៣ ០០០ កន្លែង ដែលត្រូវបានរាយការណ៍មកពីខេត្តចំនួន ១៣ ហើយភាគច្រើនលើសលប់គឺសហគ្រាសខ្នាតមីក្រូ តូច និងមធ្យម។ វិស័យនេះគ្របដណ្តប់ដោយរោងម៉ាស៊ីនកិនស្រូវ។ ទោះបី

បានចូលរួមចំណែកនៅក្នុងសេដ្ឋកិច្ចយ៉ាងណាក្តី កសិ-ឧស្សាហកម្មពុំទាន់អភិវឌ្ឍឱ្យបានពេញសក្តានុពលនោះទេ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៧ ចំណែកនៃការនាំចេញរបស់វិស័យនេះមានត្រឹមតែ ៣,៦% នៃ ផ.ស.សរុបប៉ុណ្ណោះ។

គោលនយោបាយជំរុញផលិតស្រូវ និងការនាំចេញអង្ករ ដែលដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១០ បានត្រួសត្រាយផ្លូវសម្រាប់ការអភិវឌ្ឍ មិនត្រឹមតែវិស័យស្រូវអង្ករទេ ប៉ុន្តែក៏រួមទាំងកសិ-ឧស្សាហកម្មជាទូទៅផងដែរ។ ការអនុម័តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជារបស់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៥ បានផ្តល់មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។ ប៉ុន្តែ វិស័យនេះនៅតែប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងលទ្ធភាពប្រកួតប្រជែងរបស់កម្ពុជា។ ថ្វីបើមានដំណើរការគួរជាទីសង្ឃឹម ព្រមទាំងការប្តេជ្ញាចិត្តនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលយ៉ាងណាក្តី កម្ពុជានៅតែត្រូវប្រឈមនឹងគូប្រជែងដែលជាអ្នកនាំចេញផលិតផលកសិកម្មដ៏សំខាន់ៗក្នុងតំបន់និងពិភពលោក ជាពិសេសប្រទេសវៀតណាមនិងថៃ ដោយសារតែស្ថានភាពឡូជីស្ទីកនិងភាពងាយស្រួលក្នុងការធ្វើអាជីវកម្ម។

ខណៈដែលបញ្ហាប្រឈមនៅតែបន្ត ឱកាសសម្រាប់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មរបស់កម្ពុជាក៏មិនគួរត្រូវបានមើលរំលងនោះទេ។ ថ្វីបើដំណើរការនៃការអនុវត្តវិធានការក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាហាក់មានសន្ទុះយឺតយ៉ាវបន្តិច តែក៏ទទួលបាននូវផលជាវិជ្ជមានមួយចំនួនសម្រាប់វិស័យនេះ ហើយសកម្មភាពថ្មីៗរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងកាំកុងត្រូល កាំសាប និងវិញ្ញាបនបត្រប្រភពដើមទំនិញ ក៏នឹងជួយកាត់បន្ថយថ្លៃប្រតិបត្តិការនាំចេញបន្ថែមដែរ។ ការចេញអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូច និងមធ្យម និងការបង្កើតធនាគារសម្រាប់សហគ្រាសធុនតូចនិងមធ្យម បានលើកទឹកចិត្តឱ្យមានការអភិវឌ្ឍ និងវិនិយោគលើវិស័យកសិ-ឧស្សាហកម្ម និងសហគ្រាសកសិ-ឧស្សាហកម្មធុនតូច និងមធ្យមផងដែរ។ ប៉ុន្តែ ដើម្បីផ្តល់ការគាំទ្របែបនោះដល់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ផែនការយុទ្ធសាស្រ្តជាក់លាក់មួយគួរតែត្រូវបានបង្កើតឡើង ហើយ *ផែនការនោះគួរតែអាចឱ្យកសិ-ឧស្សាហកម្មកម្ពុជាមានលទ្ធភាពប្រកួតប្រជែងបាន និងដើរតាមទីផ្សារដែលនឹងទប់ស្កាត់លំហូរនៃវត្ថុធាតុដើមកុំឱ្យហូរចេញទៅប្រទេសជិតខាង។*

## អត្ថបទទី១÷ និយមន័យនៃវិស័យកសិ-ឧស្សាហកម្ម

ចំណាប់អារម្មណ៍ក្នុងការសិក្សា និងការវិភាគលើកសិ-ឧស្សាហកម្មបានចាប់ផ្តើមមានឡើង នៅទសវត្សរ៍ទី៨០ នៅពេលដែលវិស័យនេះដើរតួសំខាន់សម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍ។ ដូច្នេះ ឯកសារស្រាវជ្រាវលើវិស័យនេះ អាចរកបានយ៉ាងងាយ។ ក្នុងឯកសារស្រាវជ្រាវ អ្នកស្រាវជ្រាវ អ្នកជំនាញ និងអ្នកនិពន្ធក្នុងវិស័យនេះ បានប្រើប្រាស់ពាក្យពេចន៍ខុសៗគ្នា ដើម្បីបង្ហាញពីអ្វីដែលខ្លួនចង់សំដៅដល់ពេលដែលនិយាយដល់កសិ-ឧស្សាហកម្ម។

ចេមស៍ (១៩៨១) បានផ្តល់និយមន័យថា កសិ-ឧស្សាហកម្មគឺសម្គាល់ដល់សហគ្រាសដែលកែច្នៃវត្ថុធាតុដើមកសិកម្ម រួមបញ្ចូលទាំងដំណាំមើម និងដំណាំដើម ក៏ដូចជាបសុសត្វផងដែរ។ គាត់ក៏បានបញ្ជាក់បន្ថែមដែរថា កម្រិតនៃការកែច្នៃអាចខុសប្លែកគ្នាយ៉ាងខ្លាំង ដោយអាចរាប់ចាប់ពីការសម្អាត និងចាត់ចំណាត់ថ្នាក់ផ្លែប៉ោម ទៅដល់ការកិនស្រូវ ការចម្អិន ការលាយ និងការកែច្នៃសារធាតុគីមីដែលអាចបង្កើតជាស្បៀងដែលផលិតដោយបន្លែដែលមានរសជាតិចម្រុះបែប។ ហ្វូ (១៩៩៧) យល់ស្របនឹងនិយមន័យនេះ។ ក្នុងន័យនេះ ពួកគេទាំងពីរយល់ស្របគ្នាថា កសិ-ឧស្សាហកម្មគឺជាឧស្សាហកម្មដែលប្រើប្រាស់ ឬកែច្នៃផលិតផលកសិកម្មជាវត្ថុធាតុដើមក្នុងដំណើរការផលិត។

យោងតាម ចនស៍ និងរូឌី (២០០៨) កសិ-ឧស្សាហកម្មផ្តោតលើសកម្មភាពបន្ទាប់ពីប្រមូលផលបាន ដែលរួមមានទាំងការបំប្លែង ការរក្សាទុក និងការរៀបចំនៃផលិតផលកសិកម្មសម្រាប់ការប្រើប្រាស់ដំណាក់កាលកណ្តាល និងការប្រើប្រាស់ដំណាក់កាលចុងក្រោយ តែដោយផ្តោតលើស្បៀងអាហារជាគោល។ ចំណែកឯ ខារ៉ូលនិងសហការីនៃអង្គការស្បៀងនិងកសិកម្ម (២០០៩) បានលើកឡើងថា កសិ-ឧស្សាហកម្មជាផ្នែកមួយនៃវិស័យកម្មន្តសាលដែលកែច្នៃវត្ថុធាតុដើម និងផលិតផលពាក់កណ្តាលសម្រេចដែលបានមកពីកសិកម្ម នេសាទ និងព្រៃឈើ រួមមានការផលិតចំណីអាហារ ភេសជ្ជៈ និងថ្នាំជក់ វាយនភ័ណ្ឌនិងសម្លៀកបំពាក់ ផលិតផលឈើនិងសង្ហារិម ក្រដាស ផលិតផលពីក្រដាស និងកៅស៊ូនិងផលិតផលពីកៅស៊ូ។

ឯកសាររបស់ក្រុមអ្នកជំនាញការនៃអង្គការFAO-UNIDO ស្តីពីការប៉ាន់ប្រមាណកសិ-ឧស្សាហកម្ម (២០១៩) បានទទួលស្គាល់ពីការប្រើពាក្យពេចន៍ជាច្រើន ក្នុងឯកសារស្រាវជ្រាវកសិ-ឧស្សាហកម្ម ដែលរួមមាន÷ កសិពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម ប្រព័ន្ធកសិស្បៀងអាហារ ឧស្សាហកម្មស្បៀងអាហារ ពីកសិដ្ឋានទៅទីផ្សារ(farm-gate-to-market) ផលិតផលកែច្នៃកសិកម្ម ការកែច្នៃស្បៀងអាហារ ខ្សែច្រវាក់តម្លៃកសិស្បៀងអាហារ ស្បៀង(អាហារ ភេសជ្ជៈ និងថ្នាំជក់) ស្បៀង(អាហារ និងចំណីដែលមានសារជាតិសរសៃច្រើន) និងប្រភេទស្បៀងផលិតពីកសិផលផ្សេងទៀត។

ក្រុមនេះបានចង្អុលថាការគណនាតួលេខ GTAP (គម្រោងវិភាគពាណិជ្ជកម្មសកល) សម្រាប់ឆ្នាំ២០០៤ ២០០៧ និង២០១១ នៅប្រទេសអាស៊ីខាងកើត បានបង្ហាញឱ្យឃើញថា កសិកម្មកែច្នៃ (កសិពាណិជ្ជកម្ម) គ្របដណ្តប់ផ្នែកតូចៗចំនួន ៨ ប្លុក ១ រួមទាំង÷ (១) សាច់ (គោ/ក្របី ចៀម ពពែ សេះ) (២) ផលិតផលចម្រាញ់ពីសាច់ (៣) ខ្លាញ់ និងប្រេងរុក្ខជាតិ (៤) ផលិតផលពីទឹកដោះ (៥) អង្ករ (៦) ស្ករ (៧) ផលិតផលម្ហូបអាហារ និង (៨) ភេសជ្ជៈ និងផលិតផលថ្នាំជក់ ក៏ដូចជា (៩) ប្រភេទផលបសុសត្វដទៃទៀត។ កាលពីអតីតកាល វាយនភណ្ឌ សម្លៀកបំពាក់

ផលិតផលស្បែក និងផលិតផលឈើត្រូវបានរាប់បញ្ចូលក្នុងទិន្នន័យ GTAP ថាជា "កសិកម្មកែច្នៃ" សម្រាប់ការគណនាបញ្ចូលផងដែរ។

នៅកម្ពុជា BLDLink (២០១៧) បានពិចារណាថា ឧស្សាហកម្មកែច្នៃកសិផលជាប្រភេទការកែច្នៃស្បៀង និងនវានុវត្តន៍ ផលិតផលភេសជ្ជៈ (ទឹកផ្លែឈើ និងគ្រឿងស្រវឹង) ថ្នាំជក់ ការកិនស្រូវ និងតម្លៃបន្ថែមលើស្រូវ ការកែច្នៃដំឡូងមី (ម្សៅដំឡូងមី មី គ្រឿងស្រវឹង និងចំណិតដំឡូង) ការកែច្នៃស្ករ និងស្ករអំពៅ ការកែច្នៃពោត (ម្សៅពោត និងផលិតផលធ្វើពីពោត) ការកែច្នៃនិងវេចខ្ចប់គ្រាប់ស្វាយចន្ទី ការកែច្នៃសណ្តែកសៀង ផ្លែឈើ បន្លែ និងសាច់ សាច់គោ និងសាច់ជ្រូកងៀត/ការកែច្នៃសាច់ បង្អែម និងអាហារសម្រន់ សត្វល្អិត ទឹកឃ្មុំ ផលិតផលកៅស៊ូ (គ្រឿងបន្លាស់រថយន្ត ឧបករណ៍ក្មេងលេង ផលិតផលប្រើប្រាស់ក្នុងផ្ទះ ផលិតផលឱសថ ស្រោមអនាម័យ ។ល។) ក្រដាស និងផលិតផលឈើ (ក្រដាសជូតមាត់ ក្រដាសបន្ទប់ទឹក ប្រអប់ ស៊ុមទំហំធំ សង្ហារិម ។ល។) វាយនភណ្ឌ និងផលិតផលស្បែក និងទឹកដោះ និងផលិតផលពីទឹកដោះ (ទឹកដោះគោជូរ ផលិតផលធ្វើពីទឹកដោះ ។ល។)។

ដូច្នេះ និយមន័យនៃកសិ-ឧស្សាហកម្មគឺទូលំទូលាយ និងមានលក្ខណៈគ្របបណ្តប់គ្រប់តួនាទី ការទទួលខុសត្រូវ និងដែនសមត្ថកិច្ចនៃក្រសួងជាច្រើន និងភ្នាក់ងារសាធារណៈនៅកម្ពុជា។ ពុំមានភ្នាក់ងារសាធារណៈណាមួយដែលផ្តល់តួនាទី និងបំពាក់ឧបករណ៍សម្រាប់ធ្វើការតែឯងលើវិស័យនេះនោះទេ។ ការអភិវឌ្ឍនៃវិស័យនេះ តម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងដែលសម្របសម្រួល និងស្រុះស្រួលគ្នាក្នុងចំណោមភ្នាក់ងារពាក់ព័ន្ធទាំងអស់ ពីកសិដ្ឋានទៅលើតុអាហារ ឬពីភូមិដាច់ស្រយាលនៅកម្ពុជាទៅទីផ្សារទំនើបនៅបរទេស។

## អត្ថបទទី២÷ វិធានការដែលមានចែងក្នុងឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ទាក់ទងនឹងការអភិវឌ្ឍកសិ-ឧស្សាហកម្ម

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ត្រូវបានកំណត់ឡើង ដើម្បីលើកកម្ពស់កសិ-ឧស្សាហកម្មនៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍកសិកម្ម។ វិសាលភាពទី៤ នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម រួមមានការលើកកម្ពស់ការអភិវឌ្ឍបណ្តុំកសិ-ឧស្សាហកម្ម។ រាជរដ្ឋាភិបាលបានលើកនូវវិធានការគោលនយោបាយជាក់លាក់ ៥ ក្នុងចំណោមគោលនយោបាយចំនួន ១២៩ ដើម្បីលើកកម្ពស់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម ដែលត្រូវបានចាត់ថ្នាក់ថាជាវិស័យអាទិភាពទី៣។ វិធានការទាំង៥នេះរួមមាន÷

១. ស្វែងរកនូវលទ្ធភាពនៃការបង្កើតតំបន់កែច្នៃទិន្នផលកសិកម្ម តាមរយៈភាពជាដៃគូរដ្ឋ ឯកជន សម្រាប់ការនាំចេញ

២. ផ្តល់នូវការលើកទឹកចិត្តទៅដល់ក្រុមហ៊ុនដើម្បីឱ្យដាក់ទីតាំងអាជីវកម្មរបស់ខ្លួននៅក្នុងតំបន់កែច្នៃផលិតផលកសិកម្ម

៣. បង្កើតមូលនិធិលើកកម្ពស់ និងអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម សម្រាប់នាំចេញទំនិញកសិ-ឧស្សាហកម្មចម្បង

៤. បង្កើតនូវយន្តការសម្របសម្រួលដើម្បីដោះស្រាយបញ្ហាឡូជីស្ទិក កាត់បន្ថយការចំណាយមិនផ្លូវការ និងធ្វើឱ្យការសម្របសម្រួលពាណិជ្ជកម្មប្រសើរឡើង ដែលគាំទ្រដល់ការនាំចេញផលិតផលកសិកម្មកែច្នៃ និង

៥. ធ្វើការសិក្សាដើម្បីកំណត់នូវផលិតផលដែលមានសក្តានុពលក្នុងការកែច្នៃ សម្រាប់នាំចេញ និងរៀបចំឱ្យមានផែនការសកម្មភាពផ្អែកលើខ្សែច្រវាក់តម្លៃដែលគ្រប់ជ្រុងជ្រោយមួយ ដែលអាចឱ្យរាជរដ្ឋាភិបាលផ្តល់ការគាំទ្រជាក់លាក់។

វិធានការជាក់លាក់ទាំង ៥ ខាងលើ មានភាពពាក់ព័ន្ធដោយផ្ទាល់ក្នុងវិស័យកសិ-ឧស្សាហកម្ម។ ថ្វីបើដូច្នេះក៏ដោយវិធានការដែលនៅសល់ចំនួន ១២៤ ទៀត ដែលពាក់ព័ន្ធនឹងការលើកកម្ពស់ការវិនិយោគ ការពង្រីកនិងការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសច្បាប់ និងការសម្របសម្រួលគោលនយោបាយគាំទ្រ ជាកត្តាជំរុញដ៏ខ្លាំងដល់ការលើកកម្ពស់ និងសម្របសម្រួលការអភិវឌ្ឍកសិ-ឧស្សាហកម្មនេះដែរ។

រាល់ស្ថាប័នខ្សែបណ្តោយរបស់រាជរដ្ឋាភិបាល បានប្តេជ្ញាចិត្តអនុវត្តរាល់វិធានការគោលនយោបាយដែលបានចែងទាំងនេះ គាំទ្រការអភិវឌ្ឍនៅក្នុងឧស្សាហកម្មនេះជារួម ហើយវិធានការជាក់លាក់ទាំង៥នោះ លើកកម្ពស់ជាពិសេសទៅលើការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។ ប៉ុន្តែ ការអនុវត្តសកម្មភាពជាក់លាក់មួយចំនួនក្នុងវិធានការជាក់លាក់ទាំង៥នេះ សម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្មហាក់ដូចជានៅមានភាពដាច់ដោយឡែកពីគ្នានៅឡើយ។ បន្ថែមពីលើនេះ ការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ហាក់ដូចជានៅមានកម្រិតនៅឡើយ។

ឧទាហរណ៍ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានសម្របសម្រួល និងគាំទ្របណ្តុំសហគ្រាសធុនតូច និងមធ្យម នៅក្នុងខេត្តកណ្តាលដើម្បីកែច្នៃផ្លែឈើស្រស់សម្រាប់ការនាំចេញ។ ក្នុងខេត្តកំពង់ឆ្នាំង ក្រសួងនេះបានសម្របសម្រួល និងគាំទ្រដល់បណ្តុំសហគ្រាសធុនតូចនិងមធ្យម ដើម្បីកែច្នៃត្រីទឹកសាបសម្រាប់ការនាំចេញ។ ស្របពេលជាមួយគ្នា ក្រសួងពាណិជ្ជកម្មបានធ្វើការជាមួយ UNIDO ដើម្បីធ្វើឱ្យទីតាំងក្នុងខេត្តកំពតប្រសើរឡើង និងប្រែក្លាយទីតាំងនេះឱ្យក្លាយជាផ្សារមួយ ដែលសមាជិកនៃសមាគមវារីវប្បកម្មសមុទ្រទឹកប្រៃអាចដាក់បង្ហាញ និងលក់ផលិតផលត្រីទឹកប្រៃរបស់ខ្លួនបាន។

វិធីសាស្ត្រដាច់ដោយឡែកបែបនេះ ពុំបានជួយឱ្យវិស័យកសិ-ឧស្សាហកម្មបញ្ចេញសក្តានុពលខ្លួនឱ្យបានពេញទំហឹងនោះទេ។ វិធីសាស្ត្របែបនេះ ពុំអាចឱ្យវិស័យនេះសម្រេចបាននូវសេដ្ឋកិច្ចមាត្រដ្ឋានទាំងខាងក្នុង និងខាងក្រៅបាននោះទេ។ ដូច្នេះ ទោះបីជាចូលចិត្តឬក៏មិនចូលចិត្តក៏ដោយ គោលដៅគោលនយោបាយសម្រាប់កសិ-ឧស្សាហកម្មគឺពិបាកនឹងសម្រេចបានណាស់។

# អត្ថបទទី៣÷ ស្ថានភាពវិស័យកសិ-ឧស្សាហកម្មខេត្តប៉ៃលិន

កំណត់ចំណាំ÷ ព័ត៌មាននៅក្នុងអត្ថបទនេះ គឺផ្អែកលើទិន្នន័យនិងឯកសារដែលទទួលបានពីកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋ និងមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។

## ១. សេចក្តីផ្តើម

### ១.១. ភូមិសាស្ត្រ

ខេត្តប៉ៃលិនមានចម្ងាយ ៣៧២គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ខេត្តប៉ៃលិនស្ថិតនៅលើតំបន់ខ្ពង់រាប ដែលគ្របដណ្តប់លើផ្ទៃដីទំហំ ១ ០៦២គីឡូម៉ែត្រ$^{២}$ ហើយតំបន់ភ្នំមានយ៉ាងហោចណាស់ ៤២% នៃផ្ទៃដីខេត្ត។ ខេត្តប៉ៃលិនមានព្រំប្រទល់ ខាងលិចជាប់នឹងប្រទេសថៃ ខាងជើងជាប់នឹងស្រុកកំរៀងខេត្តបាត់ដំបង ខាងកើតនិងខាងត្បូងជាប់នឹងស្រុករតនមណ្ឌល។ ខេត្តនេះមានចម្ងាយប្រហែល ៨៣,៥គីឡូម៉ែត្រ ពីទីរួមខេត្តបាត់ដំបង។

ខេត្តប៉ៃលិនមានចម្ងាយប្រហែល ២៦៦គីឡូម៉ែត្រ ពីកំពង់ផែសមុទ្រឡែមឆាបាង និងប្រហែល ២៦៤ គីឡូម៉ែត្រពីកំពង់ផែទឹកជ្រៅស៊ីរ៉ាឆារបស់ប្រទេសថៃ។ ដូច្នេះ ខេត្តនេះស្ថិតនៅជិតកំពង់ផែទាំងពីរនេះជាងរាជធានី ភ្នំពេញ។ ខេត្តប៉ៃលិនមានចម្ងាយ ៥៦៦គីឡូម៉ែត្រពីក្រុងព្រះសីហនុ ដែលជាខេត្តដែលមានកំពង់ផែសមុទ្រដ៏សំខាន់មួយរបស់ប្រទេសកម្ពុជា ហើយមានចម្ងាយលើសពី ៣០០គីឡូម៉ែត្រពីខេត្តកោះកុងដែលជាខេត្តឆ្នេរសមុទ្រមួយ។

### ១.២. អាកាសធាតុ

ខេត្តប៉ៃលិនរងឥទ្ធិពលអាកាសធាតុត្រូពិកដែលមានរដូវសំខាន់ៗពីរគឺ រដូវវស្សា (ពីខែឧសភាដល់ខែតុលា) និងរដូវប្រាំង (ពីខែវិច្ឆិកាដល់ខែមេសា)។ បរិមាណទឹកភ្លៀងមធ្យមមានការប្រែប្រួលខុសគ្នាពីមួយឆ្នាំទៅមួយឆ្នាំ។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមចាប់ពី ៧៩០ ទៅ ១ ៩០០ មីលីម៉ែត្រ អំឡុងឆ្នាំ ២០០៨-២០១៥។ ដោយផ្អែកលើកំណត់ត្រាក្នុងឆ្នាំ២០១៤ មធ្យមភាគទាបបំផុតនៃបរិមាណទឹកភ្លៀងគឺ ៧៩០ មីលីម៉ែត្រប៉ុណ្ណោះ។ ឆ្នាំនោះជាឆ្នាំដែលស្ងួតខ្លាំងណាស់សម្រាប់កសិករ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ភ្លៀងធ្លាក់ខុសពីធម្មតា និងមិនទៀងទាត់។ ភ្លៀងធ្លាក់ក្នុងខេត្តទាំងមូលគឺមិនដូចគ្នាទេ។ កន្លែងមួយចំនួនទទួលបានទឹកភ្លៀងច្រើនពេក ខណៈដែលកន្លែងផ្សេងទៀតគ្មានភ្លៀងសោះ។ នេះអាចបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ស្ថានភាពនេះមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើផលិតកម្មកសិកម្ម។ ឧទាហរណ៍ នៅក្នុងឆ្នាំ ២០១៨ ឃុំសង្កាត់ចំនួនបួន ក្នុងចំណោមឃុំសង្កាត់ចំនួនប្រាំបីពុំមានភ្លៀងធ្លាក់ទាល់តែសោះ។

### ១.៣. ចំនួនប្រជាជន និងមុខរបរ

ខេត្តប៉ៃលិនមានចំនួនប្រជាជនសរុប ៦៦ ២៨៩នាក់ ដែលមកពីគ្រួសារចំនួន ១៤ ៥៣៦។ របាយប្រជាជនគឺ ៦២,៤នាក់/គីឡូម៉ែត្រ$^{២}$។ ស្ត្រីមាន ៥២% នៃចំនួនប្រជាជនសរុប។ អត្រាកំណើនប្រជាជនមានការថយចុះ ១,៣៨% អំឡុងឆ្នាំ២០០៨-២០១១។ ដូចគ្នាទៅនឹងខេត្តជាច្រើនទៀតដែរ ប្រជាជនភាគច្រើនពឹងផ្អែកលើវិស័យកសិកម្ម ដែលគ្របដណ្តប់ដោយការដាំដុះដំណាំឧស្សាហកម្ម ដំណាំរួមផ្សំ និងចម្ការ។

## ២. ផលិតកម្មកសិកម្ម

### ២.១. ផលិតផលដែលមានសក្តានុពលសម្រាប់កសិ-ឧស្សាហកម្ម

ផលិតផលកសិកម្មសំខាន់ៗ រាប់តាមលំដាប់លំដោយនៃសារសំខាន់ មានដូចជា ដំឡូងមី ពោតចំណីសត្វ មៀនប៉ៃលិន គ្រាប់ធញ្ញជាតិ និងស្វាយ។ ស្រូវក៏ត្រូវបានផលិតដែរ ប៉ុន្តែជាទូទៅសម្រាប់ហូបប៉ុណ្ណោះ។ ផ្ទៃដីដាំដុះស្រូវសរុបនៅឆ្នាំ២០១៧ មានចំនួន ៦ ០៦០ ហិកតា ក្នុងនោះស្ទើរតែទាំងស្រុងជាស្រូវវស្សា។ ដំឡូងមី ពោតចំណីសត្វ និងមៀនប៉ៃលិន ក៏ដូចជាផ្លែស្វាយ សុទ្ធសឹងជាផលិតផលកសិកម្មសំខាន់ដែលខេត្តនេះនាំចេញទៅប្រទេសថៃ និងប្រទេសចិនតាមរយៈប្រទេសថៃ។ ភាគច្រើននៃផលិតផលទាំងនេះត្រូវបាននាំចេញជាផលិតផលវត្ថុធាតុដើម ឬជាផលិតផលពាក់កណ្តាលសម្រេច ជាអាទិ៍ ចំណិតដំឡូងមីស្ងួត ផ្លែមានប៉ៃលិនស្រស់ដែលរើសរួច និងផ្លែស្វាយស្រស់ដែលរើសរួច។ ពោតចំណីសត្វត្រូវបាននាំចេញជាទម្រង់វត្ថុធាតុដើម។

នៅឆ្នាំ២០១៧ ផ្ទៃដីដាំដុះដំឡូងមីមាន ២៤ ១៤២ ហិកតា ពោតចំណីសត្វ ៣០ ៤២៧ ហិកតា មៀនប៉ៃលិន ៣ ២៤៨ ហិកតា និងស្វាយ ៣ ៥១៩ ហិកតា។ តាមរាយការណ៍បង្ហាញថា "កម្រិតស្ងួត" (DSC) របស់ដំឡូងមីគឺស្ថិតនៅចន្លោះ ២០-២៥% ហើយភាពមិនសុទ្ធរបស់ពោតចំណីសត្វគឺប្រមាណ ២០% ឬតិចជាងនេះ។ ផ្លែមៀន មានពី ៧០-៨០% ដែលស្ថិតក្នុងចំណាត់ថ្នាក់លេខមួយដល់លេខបួន ពោលគឺល្អ និងស្របតាមតម្រូវការទីផ្សារអន្តរជាតិ។ ប្រមាណតែ ២០-៣០% ដែលនៅសល់ដែលស្ថិតនៅចំណាត់ថ្នាក់លេខប្រាំ ឬគ្មានចំណាត់ថ្នាក់ សម្រាប់កែច្នៃទៅអាហារ ឬភេសជ្ជៈផ្សេងៗ ឧទាហរណ៍ដូចជា មៀនកំប៉ុង ដំណាប់មៀន ស្រាមៀន ទឹកផ្លែមៀន ។ល។

### ២.២. ការវិភាគភាពប្រកួតប្រជែង

ទិន្នផលស្រូវជាមធ្យមគឺ ២,៧ តោន/ហិកតា(រដូវវស្សា) និង ៣ តោន/ហិកតា(រដូវប្រាំង)។ ទិន្នផលដំឡូងមីជាមធ្យម ២៥ តោន/ហិកតា និងបរិមាណផលពោតមាន ៥,៨ តោន/ហិកតា។ ពូជស្រូវដែលដាំដុះទោះបីជាសម្រាប់ហូបក្តី ក៏ភាគច្រើនជាប្រភេទស្រូវក្រអូបនោះដែរ។ គុណភាពដំឡូងមី ពោតចំណីសត្វ ផ្លែមៀន និងផ្លែស្វាយមានគុណភាពល្អ។ គ្មានទិន្នន័យពីចំណាយផលិតកម្មនោះទេ។

### ២.៣. លក្ខណៈនៃកសិករខ្នាតតូច

កសិករនៅខេត្តប៉ៃលិន មានទាំងកសិករខ្នាតតូច និងខ្នាតធំ នេះបើកំណត់តាមទំហំដីកសិកម្ម។ ជិត ៦៥% នៃកសិករជាកសិករខ្នាតតូចដែលមានដីស្រែតិចជាង ៤ ហិកតា/គ្រួសារ។ កសិករភាគច្រើនចូលរួមក្នុងការដាំដុះដំណាំ ឬដំណាំឧស្សាហកម្ម ដូចជាដំឡូងមី ពោត មៀន ស្វាយ កៅស៊ូ និងដំណាំផ្សេងទៀត។ កសិករតិចតួចណាស់ដែលមានដីស្រែហើយធ្វើស្រូវ។ វាលស្រែទាំងអស់ប្រមូលផ្តុំតែនៅស្រុកសាលាក្រៅ។

### ២.៤. កត្តារាំងស្ទះ

កសិករដាំដុះដំឡូងមី និងដាំពោត មិនត្រូវបានលើកទឹកចិត្តនោះទេដោយអ្នកទិញ (ឧទាហរណ៍ សាយឡូ និងម្ចាស់ឡូសម្ងួត) ជាអ្នកគ្រប់គ្រងថ្លៃនៅពេលប្រមូលផល។ អ្នកទិញដែលមានលទ្ធភាពបង់ប្រាក់បន្ថែមទៅឱ្យអ្នកផ្តល់សេវាប្រមូលផលផ្ទុបនឹងដឹកជញ្ជូន អាចរកជួលសេវានេះបានយ៉ាងងាយស្រួល។ អ្នកទិញប្រភេទនេះជាអ្នកគ្រប់គ្រង

ថ្លៃកសិផលនៅចម្ការ។ ជាញឹកញយ កសិករពុំមានលទ្ធភាពជួលសេវាផ្ទួបបែបនេះឡើយ។ កសិករណាដែលមានលទ្ធភាពជួលសេវាផ្ទួបបែបនេះ ច្រើនលក់កសិផលរបស់ខ្លួនទៅឱ្យអ្នកទិញមួយប្រភេទទៀត ដែលពុំមានលទ្ធភាពជួលសេវាប្រមូលផលផ្ទួបនឹងដឹកជញ្ជូននេះ ដោយហេតុថា ពួកគាត់អាចបានថ្លៃខ្ពស់ជាង។ ការថ្លឹងទម្ងន់និងថ្លៃឥន្ធនៈក៏ជាបញ្ហាដែរ។ ប្រសិនបើអាចធ្វើបាន អ្នកទិញនឹងបន្លំកសិករនៅពេលថ្លឹងកសិផល។

ឥន្ធនៈប្រើសម្រាប់ការរៀបចំដី ផលិតកម្ម និងការដឹកជញ្ជូន មានតម្លៃខ្ពស់ ដែលប៉ះពាល់ដល់ចំណូលរបស់កសិករ។ ចំពោះដំឡូងមីវិញ មានបញ្ហាជាមួយជំងឺដែលកើតលើដើមនិងស្លឹក និងបញ្ហាសត្វល្អិត។ ការចំណាយលើកម្លាំងពលកម្មសម្រាប់ការងារផលិតកម្ម (ដាំដុះ ថែទាំ និងប្រមូលផល) ក៏មានខ្ពស់ផងដែរ ពីព្រោះថាកម្លាំងពលកម្មបានថយចុះ។ ការកើនឡើងនៃប្រាក់ឈ្នួលគឺល្អសម្រាប់ពលករ ប៉ុន្តែប៉ះពាល់ដល់អ្នកផលិត។ ដើម្បីសម្រួលស្ថានភាពនេះ គេអាចជំនួសដោយការប្រើគ្រឿងចក្រ ឬស្វ័យប្រវត្តិកម្ម ដែលមានតម្លៃសមរម្យ និងចំណាយតិច។ ក៏ប៉ុន្តែ ការសម្រួលស្ថានភាពនេះ ទាមទារនូវកិច្ចខិតខំប្រឹងប្រែងនិងផែនការរយៈពេលវែង។

ការដាំដុះដំឡូងមីតែមួយមុខអស់រយៈពេលជាងមួយទសវត្សរ៍នៅតាមតំបន់ជាច្រើននៃខេត្តប៉ៃលិន បានធ្វើឱ្យដីបាត់បង់ជីជាតិ។ បម្រែបម្រួលអាកាសធាតុធ្វើឱ្យធាតុអាកាសកាន់តែស្ងួត និងក្ដៅជាងមុន។ កង្វះទឹកភ្លៀងបូករួមទាំងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រផ្ដល់ផលប៉ះពាល់ជាអវិជ្ជមានទៅលើផលិតកម្មកសិកម្ម។

ការប្រកួតប្រជែងរវាងអ្នកទិញនៅមានកម្រិតទាប ខណៈពេលទីផ្សារមានការខ្វះខាត។ ស្ទើរតែគ្មានអ្នកកែច្នៃផលិតផលកសិកម្មឬវត្ថុធាតុដើម ឱ្យទៅជាផលិតផលសម្រេច និងផលិតផលពាក់កណ្ដាលសម្រេច។ យន្តការផ្សារភ្ជាប់ទំនាក់ទំនងទីផ្សារ ដូចជាការសម្របសម្រួលកសិកម្មតាមកិច្ចសន្យា និងសេវាកម្មប្រឹក្សាអាជ្ញាកណ្ដាល សម្រាប់ដោះស្រាយជម្លោះក្នុងកសិកម្មតាមកិច្ចសន្យានៅមិនទាន់មាននៅឡើយ។ ព័ត៌មានទីផ្សារមិនមានគ្រប់គ្រាន់សម្រាប់ឱ្យកសិករ និងអ្នកទិញធ្វើសេចក្ដីសម្រេចចិត្តនោះទេ។ ឥណទាននៅតែមានតម្លៃថ្លៃ។ ការចំណាយលើធាតុចូលនៅតែខ្ពស់ផងដែរ ពីព្រោះធាតុចូលទាំងនោះដែលកសិករប្រើប្រាស់សុទ្ធតែត្រូវបាននាំចូល។

ទោះបីជាកសិករ និងអ្នកទិញ/រោងចក្រ ចង់បានការរៀបចំឱ្យមានកសិកម្មតាមកិច្ចសន្យាផ្លូវការមួយក៏ដោយ ក៏ពួកគេនៅមានការព្រួយបារម្ភពីកង្វះខាតយន្តការ ដែលអាចជួយពួកគេដោះស្រាយជម្លោះក្នុងករណីមានជម្លោះកើតឡើង។ ការដោះស្រាយជម្លោះតាមប្រព័ន្ធតុលាការគឺមិនសមរម្យសម្រាប់កសិកម្មតាមកិច្ចសន្យានោះទេ ស្របពេលដែលការទុកចិត្តនៅមានកម្រិត។

## ៣. កសិ-ឧស្សាហកម្មដែលមានស្រាប់និងសក្ដានុពល

### ៣.១. កសិ-ឧស្សាហកម្មដែលមានស្រាប់

បច្ចុប្បន្ននៅក្នុងខេត្តប៉ៃលិនមានសហគ្រាសចំនួន ២០៧ ដែលស្ថិតក្នុងវិស័យកសិធុរកិច្ច សហគ្រាសកសិ-ឧស្សាហកម្ម និងសហគ្រាសកែច្នៃម្ហូបអាហារ (រួមទាំងរោងកិនស្រូវផងដែរ)។ ស្ទើរតែទាំងអស់ជាសហគ្រាសខ្នាតតូច ហើយភាគច្រើនជាលក្ខណៈគ្រួសារ។ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មកសិ-ឧស្សាហផលសម្រេច ដូចជាស្រាអង្គរ ស្រាមៀន កិនស្រូវ ឬចំណីសត្វ។ បច្ចុប្បន្ននេះ កសិ-ឧស្សាកម្មនៅខេត្តប៉ៃលិន

ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនដែលទាក់ទងនឹងសាយឡូ ឡូសម្ងួត កន្លែងទិញលក់ដំឡូងមី និងពោត (៣៦%) បន្ទាប់មកគឺរោងម៉ាស៊ីនកិនស្រូវ (១៦%) និងការផលិតស្រាអង្ករ (១៦%)។ មានចំនួនតិចដែលកំពុងកែច្នៃកសិផល ឱ្យទៅជាកសិ-ឧស្សាហផលសម្រេច ជាអាទិ៍ ផលិតផលគ្រឿងសម្អាងដែលកែច្នៃពីដំឡូងមី ថង់ឬដបដែលផលិតពីដំឡូងមី មៀនកំប៉ុង ដំណាប់ផ្លែមៀន ទឹកផ្លែស្វាយ ប្រេងចម្អិនអាហារ នំអង្ករ នំស្រួយ ស្រាដំឡូងមី ។ល។

## ៣.២. កសិ-ឧស្សាហកម្មដែលមានសក្តានុពល

កសិផលចំនួនពីរ ដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅក្នុងខេត្តប៉ៃលិន គឺដំឡូងមី និងផ្លែមៀនប៉ៃលិន។ ចំណែកឯពោតចំណីសត្វក៏អាចមានសក្តានុពលដែរ។ បច្ចុប្បន្ន កសិផលទាំងនេះត្រូវបាននាំចេញភាគច្រើនក្នុងទម្រង់ជាវត្ថុធាតុដើម ឬខ្ពស់បំផុតត្រឹមទម្រង់ជាផលិតផលពាក់កណ្តាលសម្រេច។ ឥឡូវនេះ មានក្រុមហ៊ុនចិនមួយកំពុងសាងសង់កន្លែងរើសចាត់ចំណាត់ថ្នាក់ និងវេចខ្ចប់ផ្លែមៀនប៉ៃលិនសម្រាប់នាំចេញទៅចិន។ ក្រុមហ៊ុននេះទិញតែផ្លែមៀនស្រស់លេខល្អប៉ុណ្ណោះ។ នេះមានន័យថា ផ្លែដែលមានលេខអន់អាចចូលទីផ្សារក្នុងស្រុក ប្រសិនបើមានតម្រូវការ ឬត្រូវបានបោះចោលតែម្តង។

មានពលរដ្ឋកម្ពុជាម្នាក់រូបដែលជាសមាជិកនៃសមាគមមៀនប៉ៃលិន កំពុងធ្វើការជាមួយសមាជិកដទៃទៀត ដើម្បីនាំចេញផ្លែមៀនស្រស់ទៅប្រទេសចិនឆ្លងកាត់តាមប្រទេសថៃ។ គេទិញតែមៀនប្រភេទលេខ១-៤ប៉ុណ្ណោះ (នេះស្មើនឹង ៧០%-៨០% នៃទិន្នផលទាំងអស់ ហើយដែលនៅសល់គឺជាផ្លែដែលមានចំណាត់ថ្នាក់ទាប ឬគ្មានចំណាត់ថ្នាក់)។ កសិផលដែលគ្មានចំណាត់ថ្នាក់នឹងត្រូវបែងចែកទៅទីផ្សារក្នុងស្រុក ប្រសិនបើមាន ឬបោះចោលតែម្តង។ ទាំងក្រុមហ៊ុនចិននិងសមាគម ប្រហែលមិនអាចទទួលទិញផលផ្លែមៀនឱ្យអស់ទាំងអស់នោះទេ។ គេត្រូវការអ្នកនាំចេញបន្ថែមទៀត រួមទាំងវិនិយោគិនលើក្រុមហ៊ុនកែច្នៃផ្លែមៀនលេខអន់ ឬគ្មានចំណាត់ថ្នាក់ឱ្យទៅជា ស្រាមៀន ទឹកផ្លែមៀន មៀនកំប៉ុង និងដំណាប់ផ្លែមៀន។

ក្រុមហ៊ុនកូរ៉េមួយក៏កំពុងស្វែងរកលទ្ធភាព ដើម្បីបង្កើតរោងចក្រផលិតស្រាពីដំឡូងមីផងដែរ។ ក្រុមហ៊ុនបានទទួលស្គាល់ថា ផលិតផលដំឡូងមីខេត្តប៉ៃលិនមានគុណភាពល្អ ហើយមានកម្រិតស្ងួត (DSC) ចំនួន ២០-៣០% (កម្រិតស្ងួតរបស់ម្សៅ)។ ក្រុមហ៊ុន CP យល់ឃើញថា ៨០% នៃដំឡូងមីខេត្តប៉ៃលិន មានគុណភាពល្អសម្រាប់រោងចក្រផលិតចំណីសត្វរបស់ខ្លួន ហើយក៏ទទួលស្គាល់ថា ដំឡូងមីខេត្តនេះល្អជាងនៅខេត្តជិតខាងផ្សេងទៀត។ ទោះជាយ៉ាងនេះក្តី ក្រុមហ៊ុនកូរ៉េខាងត្បូងប្រហែលជាមិនវិនិយោគទៅលើរោងចក្រផលិតស្រាពីដំឡូងមីទេ។ កត្តារាំងស្ទះចម្បងមួយនោះ គឺចំណាយលើការដឹកជញ្ជូនខ្ពស់។

# ៤. តម្រូវការនិងការផ្គត់ផ្គង់ផលិតផលកសិ-ឧស្សាហកម្ម

## ៤.១. តម្រូវការ

ជាង ៩០% នៃផលិតផលកសិ-ឧស្សាហកម្មដែលកែច្នៃ ដែលមានតម្រូវការ និងលក់នៅក្នុងខេត្តប៉ៃលិន មានប្រភពពីប្រទេសថៃ។ ទាំងចំនួនមុខផលិតផល និងបរិមាណកសិឧស្សាហផល ដែលត្រូវបានផលិតក្នុងស្រុកហើយ

កំពុងដាក់លក់នៅលើទីផ្សារនៅមានតិចតួចនៅឡើយ ដូចជាអង្ករ ស្រាអង្ករ ចេកឆាប ឬវត្ថុធាតុដើមនានា (ឧទាហរណ៍ ចំណីសត្វ ជីវភា)។

### ៤.២. ការផ្គត់ផ្គង់

ការផ្គត់ផ្គង់ និងការប្រើប្រាស់កសិផល ដែលបានកែច្នៃផ្ទាល់នៅក្នុងខេត្តប៉ៃលិនមានតិចតួចណាស់ ទាំងជាចំនួនមុខទំនិញ និងបរិមាណ។ កសិផលមិនទាន់កែច្នៃ និងផលិតផលម្ហូបអាហារកែច្នៃស្ទើរតែទាំងអស់ត្រូវបាននាំចូលពីផ្សារកំពត ប្រទេសវៀតណាម និងប្រទេសថៃ។

## ៥. ធនធានមនុស្ស

### ៥.១. ជំនាញគ្រប់គ្រង

មានការខ្វះខាតធនធានមនុស្ស ដែលមានជំនាញខាងគ្រប់គ្រងធនធានមនុស្សនៅក្នុងកសិ-ឧស្សាហកម្ម។

### ៥.២. ពលកម្មមានជំនាញ និងមិនមានជំនាញ

មានតែកម្មករដែលគ្មានជំនាញប៉ុណ្ណោះ។

## ៦. ស្ថានភាពនៃកត្តាគាំទ្រ

### ៦.១. កម្មសិទ្ធិអចលនទ្រព្យ

គ្រួសារយ៉ាងហោចណាស់ ៦០% នៅខេត្តប៉ៃលិនមានប័ណ្ណកម្មសិទ្ធិដីធ្លី។ មិនមានវិវាទដីធ្លី ឬមានករណីតិចតួចប៉ុណ្ណោះដែលបានកើតឡើង ឬត្រូវបានរាយការណ៍។ មិនមានដីសាធារណៈសម្រាប់ធ្វើសម្បទានឡើយ។ ទោះយ៉ាងណាក៏ដោយ គេបានរាយការណ៍ថាមានផ្ទៃដីប្រមាណ ២០០ហិកតា ដែលជាប្រភេទដីសល់ពីការកាប់ព្រៃឈើ អាចមានសក្តានុពលសម្រាប់អភិវឌ្ឍន៍ "បណ្តុំកសិ-ឧស្សាហកម្ម"។ ខេត្តប៉ៃលិនពុំទាន់មានតំបន់សេដ្ឋកិច្ចពិសេសទេ។ ទោះបីជាដីសាធារណៈមិនមានសម្រាប់ផ្តល់សម្បទានសេដ្ឋកិច្ច វិនិយោគិន អ្នកកែច្នៃ ឬក្រុមហ៊ុន អាចទិញដីប្រសិនបើត្រូវការសម្រាប់ការវិនិយោគ និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិ។ សម្រាប់គ្រួសារក្នុងខេត្ត ប័ណ្ណកម្មសិទ្ធិដីធ្លីមានប្រយោជន៍ជាវត្ថុបញ្ចាំសម្រាប់ការទទួលបានប្រាក់កម្ចីពីធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

### ៦.២. ហេដ្ឋារចនាសម្ព័ន្ធ

ផ្លូវថ្នល់ ៧០-៨០% នៅខេត្តប៉ៃលិនមានស្ថានភាពល្អ។ ផ្លូវថ្នល់ភាគច្រើនជាថ្នល់កៅស៊ូ។ មានផ្លូវតិចតួចប៉ុណ្ណោះជាផ្លូវដី។ នាពេលអនាគត ភាគច្រើននៃផ្លូវទាំងនេះនឹងត្រូវបានសាងសង់ដោយបេតុង។ ផ្លូវជាតិ និងផ្លូវភ្ជាប់ស្រុកនឹងស្រុកសុទ្ធសឹងជាថ្នល់កៅស៊ូ។ ផ្លូវមួយចំនួនដែលជាផ្លូវភ្ជាប់ឃុំនឹងឃុំក៏ត្រូវបានក្រាលកៅស៊ូផងដែរ។ ផ្លូវទាំងអស់ត្រូវបានថែទាំយ៉ាងល្អ។ បើយោងតាមកសិករ ផ្លូវទៅកាន់ចម្ការស្ទើរតែទាំងអស់សុទ្ធសឹងស្ថិតនៅក្នុងស្ថានភាពល្អ។

ប្រជាជនប្រមាណ ៦០% នៅខេត្តប៉ៃលិនមានប្រព័ន្ធទឹកម៉ាស៊ីនប្រើប្រាស់។ អ្នកផ្សេងទៀត ប្រើប្រាស់ទឹកអណ្តូង និងទឹកភ្លៀង។ ចំពោះគ្រឹះស្ថានអាជីវកម្មជាច្រើន ដូចជា CP ដែលស្ថិតនៅខាងក្រៅទីប្រជុំជនក៏ប្រើទឹកអណ្តូងដែរ។ ការដាំដុះជាទូទៅពឹងផ្អែកលើទឹកភ្លៀង។ ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតសម្រាប់ផលិតកម្មស្រូវ។

ដំណាំមួយចំនួនដូចជា មៀន ស្វាយ ដំឡូងមី ឬពោត អាចពឹងផ្អែកលើប្រភពទឹកក្រោមដីផងដែរ។ គម្រោងផ្គត់ផ្គង់ទឹកចំនួនពីរត្រូវបានគេគ្រោងនឹងសាងសង់។ គម្រោងទាំងនេះមានគោលបំណងច្រើន រួមមានផ្តល់ទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារសម្រាប់ស្រោចស្រព និងបង្កើតវារីអគ្គិសនីមួយចំនួនផងដែរ។ នៅទីក្រុង និងតំបន់លំនៅដ្ឋានមានសេវាអនាម័យ ប៉ុន្តែមិនមានភាពទៀងទាត់ទេ។

អគ្គិសនីសម្រាប់ខេត្តប៉ៃលិនមានប្រភពមកពីប្រទេសថៃ និងបណ្តាញអគ្គីសនីជាតិពីខេត្តបាត់ដំបង។ យ៉ាងហោចណាស់ ៦០-៧០% នៃគ្រួសារនៅក្នុងខេត្តនេះមានភ្ជាប់បណ្តាញអគ្គិសនី។ អត្រាថ្លៃអគ្គិសនីគឺ ៨០០-១ ០០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ការផ្គត់ផ្គង់អគ្គិសនីមិនសូវមានស្ថិរភាពទេ ជាពិសេសនៅពេលមានភ្លៀងធ្លាក់ខ្លាំង និងព្យុះកើតឡើង។

## ៦.៣. គោលនយោបាយថ្នាក់ក្រោមជាតិ/គោលការណ៍គ្រប់គ្រងស្ថាប័ន

គោលនយោបាយជាតិ និងរចនាសម្ព័ន្ធស្ថាប័នត្រូវបានអនុវត្ត ហើយតែងតែត្រូវបានផ្តល់អាទិភាព។

## ៦.៤. ការស្រាវជ្រាវ និងអភិវឌ្ឍន៍

មិនមានការស្រាវជ្រាវណាត្រូវបានធ្វើឡើយ។ សេវាផ្សព្វផ្សាយត្រូវបានផ្តល់ជូនជាចម្បងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ពិសេសក្នុងវិស័យជលផល កសិកម្មតាមកិច្ចសន្យា ការកែច្នៃចេកឆាប និងការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ និងគុណភាព។ មានការផ្សព្វផ្សាយទាក់ទងនឹងដំឡូងមី និងពោតតិចតួចនៅឡើយ។ មន្ទីរបានអនុវត្តសកម្មភាពត្រួតពិនិត្យមួយចំនួនទៅលើរោងម៉ាស៊ីនកិនស្រូវ ដើម្បីធានាគុណភាព និងសុវត្ថិភាពរបស់រោងម៉ាស៊ីនកិនស្រូវ។ ការស្រាវជ្រាវអំពីផលិតកម្មកសិកម្ម និងសកម្មភាពកសិ-ឧស្សាហកម្មជាតម្រូវការចាំបាច់។

## ៦.៥. សេវាកម្មហិរញ្ញវត្ថុសម្រាប់កសិ-ឧស្សាហកម្ម

ធនាគារធំៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជា អេស៊ីលីដា ប្រាសាក់ និងអម្រឹត មានវត្តមាននៅខេត្តប៉ៃលិន។ អាជីវករ និងកសិករអាចខ្ចីពីស្ថាប័ទាំងនោះ ក៏ប៉ុន្តែត្រូវមានវត្ថុបញ្ចាំប្រសិនបើកម្ចីមានទំហំធំ។ ដោយសារតែអ្នកខ្ចីខ្វះវត្ថុបញ្ចាំ គេអាចខ្ចីប្រាក់តិចតួចប៉ុណ្ណោះ ដែលមិនគ្រប់គ្រាន់សម្រាប់ការវិនិយោគរយៈពេលវែង។

## ៦.៦. ភាពងាយស្រួលនៃការធ្វើជំនួញ

ការធ្វើអាជីវកម្មនៅខេត្តប៉ៃលិនមិនមែនជារឿងលំបាក ឬជាការប្រកួតប្រជែងទេ ហើយភាគច្រើនអាជីវកម្មជាពិសេសអ្នកជំនួញធំៗអាចចាប់ផ្តើមអាជីវកម្មរបស់ខ្លួនបានដោយមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ខេត្ត ឬក្រសួងពាក់ព័ន្ធ និងភ្នាក់ងារពាក់ព័ន្ធនៅមូលដ្ឋានដែលផ្តល់ការគាំទ្រ។ ការចុះបញ្ជីអាជីវកម្ម ឬសហគ្រាសត្រូវបានធ្វើវិមជ្ឈការ។ ពុំទាន់មានសេវាគាំទ្រការបើកមុខជំនួញសម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មនៅឡើយទេ។

### ៦.៧. បច្ចេកវិជ្ជា និងសេវាគាំទ្រការបើកមុខជំនួញ និងការផ្សារភ្ជាប់ទំនាក់ទំនងមុខជំនួញ

ទំនាក់ទំនងពាណិជ្ជកម្មរវាងអ្នកផលិត និងអ្នកទិញ និង/ឬអ្នកកែច្នៃ និងទីផ្សារក្នុងស្រុកនិងក្នុងតំបន់ក៏ដូចជាទីផ្សារនៅក្រៅប្រទេសនៅមានកម្រិតខ្លាំងណាស់។ មិនមានកសិកម្មតាមកិច្ចសន្យានោះទេ។ កសិករ និងអ្នកទិញមិនទាន់យល់ដឹងអំពីការរៀបចំ និងការអនុវត្តកសិកម្មតាមកិច្ចសន្យា។ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបានផ្សព្វផ្សាយព័ត៌មាន សម្របសម្រួល និងលើកកម្ពស់កសិកម្មតាមកិច្ចសន្យា ប៉ុន្តែពុំទទួលបានការចាប់អារម្មណ៍ទេ ប្រហែលដោយសារការរៀបចំជាលក្ខណៈមិនផ្លូវការ។

កសិករនិងអ្នកទិញមានភាពស្ទាក់ស្ទើរ ក្នុងការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា ពីព្រោះពុំទាន់បានឃើញផលប្រយោជន៍នៅឡើយ។ លើសពីនេះទៀត ប្រសិនបើមានជម្លោះ ឬការរំលោភបំពានលើការអនុវត្តកិច្ចសន្យា នោះគ្មានយន្តការអនុវត្តន៍ច្បាប់ដែលអាចទទួលយកបាន ឬគួរទុកចិត្តនោះទេ។ ពួកគេមិនចង់ដោះស្រាយតាមរយៈតុលាការទេ ប្រសិនបើមានជម្លោះ។ ការឆ្លងកាត់តុលាការត្រូវការពេលវេលាច្រើនណាស់ ដែលមិនសមស្របសម្រាប់កសិផល ដែលអាចខូចរលួយ និងមានតម្លៃថ្លៃដើម្បីថែរក្សា និងស្តុកទុក។ បច្ចេកវិជ្ជាសម្រាប់វិស័យកសិ-ឧស្សាហកម្មនៅមានកម្រិត ឬស្ទើរតែគ្មាន។

## ៧. សរុបសេចក្តី និងអនុសាសន៍

### ៧.១. កសិ-ឧស្សាហកម្មអាទិភាព

មានកសិផលសក្តានុពលចំនួនពីរសម្រាប់សាកល្បង និងអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនៅខេត្តប៉ៃលិន រួមមានដំឡូងមី និងមៀនប៉ៃលិន។ បច្ចុប្បន្ននេះ មានតែក្រុមហ៊ុន CP ប៉ុណ្ណោះ ដែលទិញដំឡូងមី និងគ្រាប់ពោតសម្រាប់ផលិតចំណីមាន់ និងជ្រូក។ ក៏ប៉ុន្តែ ក្រុមហ៊ុននេះពុំអាចទាញយកកសិផលទាំងអស់បាននោះទេ។ ដូច្នេះ ផលិតផលវត្ថុធាតុដើមជាច្រើនហួសប្រមាណកំពុងត្រូវបាននាំចេញទៅប្រទេសថៃ និង/ឬប្រទេសចិនឆ្លងកាត់តាមប្រទេសថៃ។ គម្រោងសាកល្បងដែលមានសក្តានុពលក្នុងកសិ-ឧស្សាហកម្ម រួមមាន ការកែច្នៃដំឡូងមីទៅជាម្សៅ សរសៃមី អេតាណុលស្រា ផលិតផលគ្រឿងសម្អាង សម្ភារៈវេចខ្ចប់ដែលអាចរលាយ (ថង់ ដប ។ល។)។ ពោតក៏អាចកែច្នៃទៅជាអេតាណុលផងដែរ។ ចំពោះមៀនប៉ៃលិន ទីផ្សារនាំចេញសំខាន់គឺប្រទេសចិន ហើយការនាំចេញគឺឆ្លងកាត់ប្រទេសថៃ។ កន្លងមក ការនាំចេញផ្តោតលើតែផ្លែឈើស្រស់ ដែលត្រូវបានរើស និងវេចខ្ចប់តែនៅក្នុងប្រទេសថៃប៉ុណ្ណោះ។ សកម្មភាពពាក់ព័ន្ធនឹងការនាំចេញទាំងអស់នោះគួរធ្វើឡើងនៅក្នុងខេត្តតែម្តង ដើម្បីបង្កើនតម្លៃបន្ថែម។ កសិផលអាចនឹងមានបរិមាណច្រើន ឈានដល់អតិរេកនៅបណ្តាឆ្នាំខាងមុខ ហើយផ្លែឈើដែលមានចំណាត់ថ្នាក់ទាបទាមទារឱ្យមានការកែច្នៃដើម្បីបំពេញតម្រូវការទីផ្សារ និងទទួលបានតម្លៃបន្ថែម។ គម្រោងសាកល្បងអាចផ្តោតលើផ្នែកកសិ-ឧស្សាហកម្មនេះ។ ទាំងដំឡូងមី និងមៀន ហើយប្រហែលជាពោតផងដែរ អាចធ្វើឱ្យខេត្តប៉ៃលិនក្លាយទៅជាបណ្តុំកសិ-ឧស្សាកម្មបាន នេះបើពិចារណាទៅលើកត្តាជាច្រើនដូចខាងក្រោម÷

- ខេត្តប៉ៃលិនស្ថិតនៅជិតកំពង់ផែទឹកជ្រៅប្រទេសថៃ ដែលធ្វើការនាំចេញទៅកាន់ទីផ្សារលើសពីទីផ្សារប្រទេសថៃ (សន្មត់ថារាជរដ្ឋាភិបាលកម្ពុជាអាចរៀបចំជាមួយភាគីថៃបាន)។

- ខេត្តប៉ៃលិនស្ថិតនៅជិតប្រទេសថៃ អនុញ្ញាតឱ្យមានការនាំចូលបច្ចេកទេស បច្ចេកវិជ្ជា និងជំនាញពីប្រទេសថៃយ៉ាងងាយស្រួល ហើយអាចយកគំរូពីភាពជោគជ័យលើវិស័យកសិ-ឧស្សាហកម្មរបស់ថៃ។
- សហគ្រាសកសិ-ឧស្សាហកម្មជាច្រើន និងសកម្មភាពផ្សេងៗទៀត ឧទាហរណ៍ សាយឡូ ឡសម្ងួត និងឃ្លាំងសម្រាប់ស្តុកដំឡូងមី និងពោត ទាំងជាវត្ថុធាតុដើម ឬផលិតផលពាក់កណ្តាលសម្រេចមានចំនួនច្រើននៅក្នុងខេត្តនេះ។
- បណ្តុំសហគ្រាសកសិ-ឧស្សាហកម្មនៅខេត្តប៉ៃលិន អាចជាតំបន់ទាញយកកសិផលពីខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ដែលកំពុងផលិតកសិផលស្រដៀងគ្នា (ឧទាហរណ៍ ដំឡូងមី ពោត មៀន និងស្វាយ)។
- ហេដ្ឋារចនាសម្ព័ន្ធមានសភាពល្អ ឬល្អជាងខេត្តពីរទៀតដែលនៅជិតខាង។

បណ្តុំសហគ្រាសកសិ-ឧស្សាហកម្មនឹងអនុញ្ញាតឱ្យវិស័យកសិ-ឧស្សាហកម្មរបស់ខេត្តប៉ៃលិនចាប់យកទីផ្សារនាំចេញ។ ករណីនេះអាចជាគំរូសម្រាប់ខេត្តផ្សេងទៀតផងដែរ។

## ៧.២. កត្តារាំងស្ទះចម្បងៗ

កត្តារាំងស្ទះដល់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅខេត្តប៉ៃលិន គឺការខ្វះខាតលទ្ធភាពប្រើប្រាស់បច្ចេកវិជ្ជាដែលពាក់ព័ន្ធ (រួមមាន ឧបករណ៍ សម្ភារៈ និងម៉ាស៊ីនបច្ចេកទេស) និងធនធានមនុស្សដែលមានជំនាញ។ គុណភាព និងការទុកចិត្តលើកសិផលដែលកែច្នៃក្នុងស្រុកក៏ជាបញ្ហាផងដែរ។ អ្នកប្រើប្រាស់មិនទាន់ប្រាកដចិត្តលើសុវត្ថិភាពម្ហូបអាហារ ឬភេសជ្ជៈដែលបានកែច្នៃនៅក្នុងស្រុក ឧទាហរណ៍ដូចជាការដាក់ស្លាកសម្គាល់ និងលិខិតបញ្ជាក់ដែលជឿទុកចិត្ត។ ឥណទានមានតម្លៃថ្លៃ ហើយតម្រូវឱ្យមានវត្ថុបញ្ចាំ។ តម្លៃដឹកជញ្ជូននៅតែខ្ពស់។ ទាំងនេះអាចជាបញ្ហាប្រឈមមួយសម្រាប់អ្នកកែច្នៃ និងអ្នកនាំចេញ ព្រោះវាប៉ះពាល់ដល់ការប្រកួតប្រជែងរបស់ផលិតផលចុងក្រោយ។

## ៧.៣. ថវិកាវិនិយោគ និងតួនាទីរបស់វិស័យឯកជន

មានតម្រូវការជាបន្ទាន់ និងចាំបាច់សម្រាប់ការងារស្រាវជ្រាវលើផលិតកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម ពិសេសការស្រាវជ្រាវដែលទាក់ទងទៅនឹងដំឡូងមី និងពោត។ ពុំទាន់អាចប៉ាន់ស្មានខ្ទង់ថវិកាវិនិយោគបាននៅឡើយ។

តួនាទីសំខាន់របស់វិស័យឯកជនមានដូចជា ការធ្វើទីផ្សារ ការផ្តល់សេវាជួសជុលគ្រឿងយន្តកសិកម្ម និងម៉ាស៊ីនរោងចក្រ ការចែកចាយធាតុចូលដោយមានឥណទាន និង/ឬតម្លៃទាប។

## អត្ថបទទី៤÷ ស្ថានភាពវិស័យកសិ-ឧស្សាហកម្មខេត្តត្បូងឃ្មុំ

កំណត់ចំណាំ÷ ព័ត៌មាននៅក្នុងអត្ថបទនេះ គឺផ្អែកលើទិន្នន័យ និងឯកសារទទួលបានពីកិច្ចសម្ភាសន៍ជាមួយប្រជាពលរដ្ឋ និងមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត។

### ១. សេចក្តីផ្តើម

### ១.១. ភូមិសាស្ត្រ

ខេត្តត្បូងឃ្មុំមានទីតាំងស្ថិតនៅចម្ងាយ ១៥៣គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ខេត្តត្បូងឃ្មុំមានផ្ទៃដីសរុបចំនួន ៥ ២៥០,៥១គីឡូម៉ែត្រ២។ ខេត្តត្បូងឃ្មុំមានព្រំប្រទល់ ខាងលិចជាប់នឹងខេត្តកំពង់ចាម ខាងជើងជាប់នឹងខេត្តក្រចេះ ខាងកើតជាប់នឹងខេត្តតៃនិញនិងខេត្តប៊ិញភឿកនៃប្រទេសវៀតណាម ហើយខាងត្បូងជាប់នឹងខេត្តព្រៃវែង។ ខេត្តនេះមានស្ថានភាពដីជាតំបន់ខ្ពង់រាប គ្របដណ្តប់ដោយដីក្រហម តំបន់ទំនាបដែលតែងតែទទួលរបបជំនន់ទឹកភ្លៀងទន្លេមេគង្គនៅរដូវវស្សា និងតំបន់ទំនាបទឹកភ្លៀង។ ស្ថានភាពដីបែបនេះ មានសក្តានុពលខាងវិស័យកសិកម្ម ជាពិសេសដំណាំកសិ-ឧស្សាហកម្ម ដូចជា កៅស៊ូ ដំឡូងមី ស្វាយចន្ទី ពោត សណ្តែក អំពៅជាដើម ដែលគ្របដណ្តប់២/៣នៃផ្ទៃដីដាំដុះក្នុងខេត្តទាំងមូល និងផ្ទៃដីស្រូវមានប្រមាណ ១/៣។

### ១.២. អាកាសធាតុ

ខេត្តត្បូងឃ្មុំក៏ដូចជាខេត្តដទៃទៀតរងឥទ្ធិពលអាកាសធាតុត្រូពិច ដែលមានរដូវសំខាន់ៗពីរ គឺរដូវវស្សា (ពីខែឧសភាដល់ខែតុលា) និងរដូវប្រាំង (ពីខែវិច្ឆិកាដល់ខែមេសា)។ បរិមាណទឹកភ្លៀងមធ្យមមានការប្រែប្រួលខុសគ្នាពីមួយឆ្នាំទៅមួយឆ្នាំ។ បរិមាណទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមចាប់ពី ១ ៥៦៩,២ មីលីម៉ែត្រ ក្នុងឆ្នាំ២០១៨។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ភ្លៀងធ្លាក់ខុសពីធម្មតា និងមិនទៀងទាត់។ ភ្លៀងធ្លាក់ក្នុងខេត្តទាំងមូលគឺមិនដូចគ្នាទេ។ កន្លែងមួយចំនួនទទួលបានទឹកភ្លៀងច្រើនពេក ខណៈដែលកន្លែងផ្សេងទៀតគ្មានភ្លៀងសោះ។ នេះអាចបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ស្ថានភាពនេះប៉ះពាល់យ៉ាងខ្លាំងទៅលើផលិតកម្មកសិកម្ម។

### ១.៣. ចំនួនប្រជាជន និងមុខរបរ

ខេត្តត្បូងឃ្មុំមានប្រជាជន ៨៤៣ ៣១០ នាក់ ដែលមកពីគ្រួសារចំនួន ១៨៩ ៨០៣ គ្រួសារ ក្នុងនោះស្ត្រីមាន ៥១,៦១%។ របាយប្រជាជនគឺ៦១នាក់/គីឡូម៉ែត្រ២។ អត្រាកំណើនប្រជាជនមានការកើនឡើង ១,១៦% អំឡុងឆ្នាំ២០១៧-២០១៨។ ដូចគ្នាទៅនឹងខេត្តជាច្រើនទៀតដែរ ប្រជាជនភាគច្រើនពឹងផ្អែកលើវិស័យកសិកម្ម ដែលគ្របដណ្តប់ដោយការដាំដុះដំណាំឧស្សាហកម្ម និងដំណាំរួមផ្សំ និងចម្ការនានា ដូចជាកៅស៊ូ ម្រេច ដំឡូងមី ពោតចំណីសត្វ ស្វាយ បន្លែ និងគ្រាប់ធញ្ញជាតិ។

### ២. ផលិតកម្មកសិកម្ម

### ២.១. ផលិតផលដែលមានសក្តានុពលសម្រាប់កសិ-ឧស្សាហកម្ម

ផលិតផលកសិកម្មសំខាន់ៗរាប់តាមលំដាប់លំដោយនៃសារសំខាន់ មានដូចជា កៅស៊ូ ដំឡូងមី ម្រេច ស្រូវ គ្រាប់ធញ្ញជាតិ និងស្វាយចន្ទី ដែលសុទ្ធសឹងជាផលិតផលកសិកម្ម ដែលខេត្តនេះនាំចេញទៅប្រទេសវៀតណាម

ភាគច្រើនក្រោមទម្រង់ជាវត្ថុធាតុដើម ឬជាផលិតផលពាក់កណ្តាលសម្រេច ជាអាទិ៍ កៅស៊ូក្រែប ម្រេច ចំណិតដំឡូងមីស្ងួត និងគ្រាប់ស្វាយចន្ទី។ នៅឆ្នាំ២០១៨ ផ្ទៃដីដាំដុះកៅស៊ូមាន ៧៩ ៦៩៦ ហិកតា ដំឡូងមីមានជាង ៥៣ ៩៦០ ហិកតា ម្រេចមាន ២ ៦៤៥ ហិកតា ស្រូវមាន ៦២ ៨៧៥ ហិកតា និងស្វាយចន្ទីមាន ៧ ៦៣៧ ហិកតា។ កម្រិតស្ងួតរបស់ដំឡូងមីគឺស្ថិតនៅចន្លោះពី២០ទៅ២៥%។

## ២.២. ការវិភាគភាពប្រកួតប្រជែង

ទិន្នផលស្រូវជាមធ្យមគឺ ៣,៥តោន។ ទិន្នផលកៅស៊ូជាមធ្យមគឺ ១,៥តោន/ហិកតា ទិន្នផលម្រេច ៥,៣០ តោន/ហិកតា ទិន្នផលដំឡូងមី ២៥ តោន/ហិកតា ទិន្នផលស្វាយ ១៥តោន/ហិកតា។ ពូជស្រូវដែលដាំដុះ ទោះបីជាសម្រាប់ហូបក្តី ក៏ភាគច្រើនជាប្រភេទស្រូវក្រអូប។ គុណភាពដំឡូងមី ស្រូវ កៅស៊ូ ម្រេច ស្វាយចន្ទី ពោតចំណីសត្វសុទ្ធសឹងតែមានគុណភាពល្អអាចនាំចេញបាន។ មិនមានទិន្នន័យពីចំណាយផលិតកម្មទាំងនោះទេ។

## ២.៣. លក្ខណៈនៃកសិករខ្នាតតូច

កសិករនៅខេត្តត្បូងឃ្មុំមានទាំងកសិករខ្នាតតូចនិងមធ្យម នេះបើកំណត់តាមទំហំដីកសិកម្ម។ ជិត ៦៥% នៃកសិករជាកសិករខ្នាតតូចដែលមានដីស្រែតិច និងចម្ការតិចជាង ៤ ហិកតា/គ្រួសារ។ កសិករភាគច្រើនចូលចិត្តដាំដំណាំឧស្សាហកម្មនិងដំណាំរួមផ្សំ ដូចជា កៅស៊ូ ម្រេច ដំឡូងមី ស្វាយចន្ទី និងដំណាំផ្សេងទៀត។ មានកសិករខ្នាតតូចក្នុងតំបន់មួយចំនួនក៏ដាំដុះបន្លែផងដែរ។

## ២.៤. កត្តារាំងស្ទះ

រយៈពេលពីរឆ្នាំចុងក្រោយនេះ កសិករដែលដាំដុះកៅស៊ូ ម្រេច ស្វាយចន្ទីជួបបញ្ហាតម្លៃឡើងចុះមិនទៀងទាត់ លើកលែងតម្លៃដំឡូងមីដែលមានភាពល្អប្រសើរ ប៉ុន្តែបែរជាជួបបញ្ហាពេលលួតលាស់ទៅវិញដោយសារកត្តាជំងឺលើដើម និងស្លឹកដែលប៉ះពាល់ដល់ទិន្នផល។ ការថ្លឹងទម្ងន់ និងថ្លៃឥន្ធនៈក៏ជាបញ្ហាដែរ ប្រសិនបើអាចធ្វើបានអ្នកទិញនឹងបន្លំកសិករនៅពេលថ្លឹងកសិផល។ ឥន្ធនៈប្រើសម្រាប់ការរៀបចំដី ផលិតកម្ម និងការដឹកជញ្ជូនមានថ្លៃខ្ពស់ដែលប៉ះពាល់ដល់ការចំណាយថ្លៃដើមខ្ពស់។ ការដាំដុះដំឡូងមីតែមួយមុខអស់រយៈពេលជាច្រើនឆ្នាំលើដីដដែលៗនៅតាមតំបន់ជាច្រើននៃខេត្តត្បូងឃ្មុំ បានធ្វើឱ្យដីបាត់បង់ជីជាតិ។ ការបម្រែបម្រួលអាកាសធាតុធ្វើឱ្យធាតុអាកាសកាន់តែស្ងួត និងក្តៅជាងមុន។ កង្វះទឹកភ្លៀងរួមទាំងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើផលិតកម្មកសិកម្ម។

ការប្រកួតប្រជែងរវាងអ្នកទិញនៅមានកម្រិត ខណៈពេលទីផ្សារមានការខ្វះខាត។ អ្នកកែច្នៃផលិតផលកសិកម្ម ឬវត្ថុធាតុដើមឱ្យទៅជាផលិតផលសម្រេច និងពាក់កណ្តាលសម្រេចនៅមានចំនួនតិច។ យន្តការផ្សារភ្ជាប់ទំនាក់ទំនងទីផ្សារ ដូចជាការសម្របសម្រួលផលិតកម្មកសិកម្មតាមកិច្ចសន្យា និងសេវាកម្មប្រឹក្សាអាជ្ញាកណ្តាលសម្រាប់ដោះស្រាយជម្លោះនៅមិនទាន់មាននៅឡើយ។ ព័ត៌មានទីផ្សារមិនមានគ្រប់គ្រាន់សម្រាប់ឱ្យកសិករ និងអ្នកទិញធ្វើការសម្រេចចិត្តនោះទេ។ ឥណទាននៅតែមានតម្លៃថ្លៃ។ ការចំណាយលើធាតុចូលនៅតែខ្ពស់ផងដែរ ពីព្រោះធាតុចូលទាំងនោះសុទ្ធតែត្រូវបាននាំចូល។ ទោះបីជាកសិករ និងអ្នកទិញ/រោងចក្រ ចង់បានការរៀបចំឱ្យមានកសិកម្មតាមកិច្ចសន្យាផ្លូវការមួយក៏ដោយ ក៏ពួកគេនៅមានការព្រួយបារម្ភពីកង្វះខាតយន្តការដែលអាចជួយពួកគេ

ដោះស្រាយជម្លោះក្នុងករណីមានជម្លោះកើតឡើង។ ការដោះស្រាយជម្លោះតាមប្រព័ន្ធតុលាការគឺមិនសមរម្យសម្រាប់កសិកម្មតាមកិច្ចសន្យានោះទេ ស្របពេលដែលការទុកចិត្តនៅមានកម្រិត។

ទន្ទឹមនឹងឥន្ធនៈមានតម្លៃថ្លៃ ការចំណាយលើកម្លាំងពលកម្មសម្រាប់ការងារផលិតកម្មក៏មានកម្រិតខ្ពស់ផងដែរ ពីព្រោះថាកម្លាំងពលកម្មបានថយចុះ។ ការកើនឡើងនៃប្រាក់ឈ្នួលពលកម្មគឺល្អសម្រាប់ពលករ ប៉ុន្តែប៉ះពាល់ដល់អ្នកផលិត។ ដើម្បីសម្រួលស្ថានភាពនេះ គេអាចជំនួសដោយការប្រើគ្រឿងចក្រ ឬស្វ័យប្រវត្តិកម្ម ដែលមានតម្លៃសមរម្យ និងចំណាយតិច។ ក៏ប៉ុន្តែ ការសម្រួលស្ថានភាពនេះ ទាមទារនូវកិច្ចខិតខំប្រឹងប្រែង និងផែនការរយៈពេលវែង។

## ៣. កសិ-ឧស្សាហកម្មដែលមានស្រាប់ និងមានសក្តានុពល

### ៣.១. កសិ-ឧស្សាហកម្មដែលមានស្រាប់

នាពេលបច្ចុប្បន្ននេះ នៅក្នុងខេត្តត្បូងឃ្មុំមានសហគ្រាសចំនួន ០៨ ដែលស្ថិតក្នុងវិស័យកសិធុរកិច្ច ស្ទើរតែទាំងអស់ជាសហគ្រាសខ្នាតតូច ហើយភាគច្រើនលក្ខណៈគ្រួសារ។ មានតែមួយចំនួនតូចប៉ុណ្ណោះ ដែលចូលរួមក្នុងខ្សែច្រវាក់ផលិតកម្មកសិផលសម្រេច ដូចជា សហគ្រាសកែច្នៃដំណាប់ស្វាយ សហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទី កែច្នៃដំឡូងមី កែច្នៃសណ្តែកដី រោងម៉ាស៊ីនកិនស្រូវ និងសហគ្រាសចំណីសត្វ។

### ៣.២. កសិ-ឧស្សាហកម្មដែលមានសក្តានុពល

កសិផលចំនួនពីរដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅខេត្តត្បូងឃ្មុំ គឺកៅស៊ូ និងដំឡូងមី។ ចំណែកឯដំណាំម្រេច និងស្វាយចន្ទីក៏អាចមានសក្តានុពលផងដែរ។ បច្ចុប្បន្ន កសិផលទាំងនេះត្រូវបាននាំចេញ ភាគច្រើនក្នុងទម្រង់ជាវត្ថុធាតុដើម ឬជាផលិតផលពាក់កណ្តាលសម្រេច ហើយក៏មានក្រុមហ៊ុន សហគ្រាសកសិ-ឧស្សាហកម្ម និងវិស័យកសិធុរកិច្ចផងដែរដែលបានកែច្នៃផលិតផលសម្រេចមានជាអាទិ៍ រោងចក្រកែច្នៃសណ្តែកដីនៅស្រុកត្បូងឃ្មុំ រោងចក្រកែច្នៃដំណាប់ស្វាយ រោងចក្រកែច្នៃគ្រាប់ស្វាយចន្ទីនៅស្រុកមេមត់ រោងចក្រកែច្នៃដំឡូងមីនៅក្រុងសួង ដែលរោងចក្រទាំងនោះផលិតជាផលិតផលសម្រេចនាំចេញទៅក្រៅប្រទេស និងរោងចក្រកែច្នៃចំណីសត្វនៅក្នុងស្រុកត្បូងឃ្មុំ ដែលផលិតសម្រាប់ធ្វើការចែកចាយក្នុងស្រុក។

កៅស៊ូត្រូវបានចាត់ទុកថាជាដំណាំកសិ-ឧស្សាហកម្មមានសក្តានុពលបំផុតនៅក្នុងខេត្ត។ ផ្ទៃដីដាំដុះកៅស៊ូជាលក្ខណៈក្រុមហ៊ុន និងវិទ្យាស្ថានមានចំនួន ៣១ ៨១១ ហិកតា ក្នុងនោះផ្ទៃដីជាជ័រមាន ២០ ២៨៣ ហិកតា ផ្ទៃដីកំពុងថែទាំមាន ១១ ៥២៨ ហិកតា។ ផ្ទៃដីដាំដុះកៅស៊ូជាលក្ខណៈគ្រួសារមាន ៤៧ ៨៨៤ ហិកតា ក្នុងនោះមានផ្ទៃដីចៀរជ័រ ២៩ ៨៤១ ហិកតា ផ្ទៃដីកំពុងថែទាំ ១៨ ៤៤៣ ហិកតា។ មានក្រុមហ៊ុនចំនួន ២១ កែច្នៃជាកៅស៊ូក្រេប ក្រុមហ៊ុន៣៣ កែច្នៃជាកៅស៊ូសន្លឹក ដែលកំពុងដំណើរការកែច្នៃនាំចេញទៅប្រទេសវៀតណាម ម៉ាឡេស៊ី សិង្ហបុរី ថៃ។ល។

ដំឡូងមីមានផ្ទៃដីដាំដុះប្រមាណជា ៥៣៤ ហិកតា ដែលទិន្នផលស្រស់ជាមធ្យមពី ១៨-២៥ តោន/ហិកតា ដែលកសិករភាគច្រើនលក់ស្រស់ទៅតាមសាយឡូ និងដឹកជញ្ជូនដោយខ្លួនឯងទៅលក់នៅប្រទេសវៀតណាម ចំពោះសាយឡូប្រមូលលក់ជាដំឡូងមីស្រស់ និងដំឡូងក្រៀមទៅលក់ក្នុងប្រទេសវៀតណាមដូចគ្នា។ ម្រេចក៏ជាដំណាំ និងមានសក្តានុពលផងដែរ ផ្ទៃដីដាំម្រេចមានប្រមាណ ២ ៦៤៥ ហិកតា ដែលក្នុងនោះផ្ទៃដីប្រមូលផល ២ ០៩១ ហិកតា

ដែលភាគច្រើនលក់ចេញទៅប្រទេសវៀតណាម។ ផ្ទៃដីដាំដុះស្វាយចន្ទីមាន ៧ ៦៣៧ ហិកតា។ រីឯផ្ទៃដីប្រមូលមាន ៦ ២៣១ ហិកតា ដែលភាគច្រើនលក់ចេញទៅប្រទេសវៀតណាមជាទំរង់វត្ថុធាតុដើម។

## ៤. តម្រូវការនិងការផ្គត់ផ្គង់ផលិតផលកសិ-ឧស្សាហកម្ម

### ៤.១. តម្រូវការ

ផលិតផលកសិ-ឧស្សាហកម្មកែច្នៃដែលមានតម្រូវការនិងលក់នៅក្នុងខេត្តត្បូងឃ្មុំ មានប្រភពពីប្រទេសជិតខាង។ ទាំងចំនួនមុខផលិតផល និងបរិមាណកសិ-ឧស្សាហផលដែលត្រូវបានផលិតក្នុងស្រុក ហើយកំពុងដាក់លក់នៅលើទីផ្សារនៅមានតិចតួចនៅឡើយ ដូចជាអង្ករ ឬវត្ថុធាតុដើមនានា (ឧទាហរណ៍ ចំណីសត្វ ជី)។

### ៤.២. ការផ្គត់ផ្គង់

ការផ្គត់ផ្គង់ និងការប្រើប្រាស់កសិផល ដែលបានកែច្នៃផ្ទាល់នៅក្នុងខេត្តត្បូងឃ្មុំពុំមានច្រើននោះទេ ទាំងជាចំនួនមុខទំនិញ និងបរិមាណ។ ផលិតផលម្ហូបអាហារកែច្នៃស្ទើរតែទាំងស្រុង ត្រូវបាននាំចូលពីប្រទេសជិតខាង និងក្រៅខេត្ត។

## ៥. ធនធានមនុស្ស

### ៥.១. ជំនាញគ្រប់គ្រង

មានការខ្វះខាតធនធានមនុស្ស ដែលមានជំនាញខាងគ្រប់គ្រងធនធានមនុស្ស នៅក្នុងកសិ-ឧស្សាហកម្ម។

### ៥.២. ពលកម្មមានជំនាញ និងមិនមានជំនាញ

មានតែកម្មករដែលគ្មានជំនាញប៉ុណ្ណោះ។

## ៦. ស្ថានភាពនៃកត្តាគាំទ្រ

### ៦.១. កម្មសិទ្ធិអចលនទ្រព្យ

គ្រួសារយ៉ាងហោចណាស់៥០% នៅខេត្តត្បូងឃ្មុំមានប័ណ្ណកម្មសិទ្ធិដីធ្លី។ ស្ទើរតែមិនមានវិវាទដីធ្លី ឬមានករណីតិចតួចប៉ុណ្ណោះដែលបានកើតឡើង ឬរាយការណ៍។ មានដីរដ្ឋមួយចំនួនសម្រាប់ធ្វើជាសម្បទានដីសេដ្ឋកិច្ច។ រដ្ឋបានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់វិនិយោគិន អ្នកកែច្នៃ ឬក្រុមហ៊ុន ប្រសិនបើត្រូវការសម្រាប់ការវិនិយោគ និងការដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិក្នុងកាវិនិយោគ។ សម្រាប់គ្រួសារក្នុងខេត្ត ប័ណ្ណកម្មសិទ្ធិដីធ្លីមានប្រយោជន៍ជាវត្ថុបញ្ចាំដើម្បីបានប្រាក់កម្ចីពីធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

### ៦.២. ហេដ្ឋារចនាសម្ព័ន្ធ

ផ្លូវថ្នល់ភាគច្រើន (៧០-៨០%) នៅខេត្តត្បូងឃ្មុំមានស្ថានភាពល្អ។ ផ្លូវថ្នល់ជាងពាក់កណ្តាលជាថ្នល់កៅស៊ូ។ នៅសល់មួយចំនួនទៀតជាផ្លូវដី។ នាពេលអនាគត ភាគច្រើននៃផ្លូវទាំងនេះនឹងត្រូវបានសាងសង់ដោយបេតុង។ ផ្លូវជាតិនិងផ្លូវភ្ជាប់ស្រុកនិងស្រុកសុទ្ធសឹងជាថ្នល់កៅស៊ូ។ ផ្លូវមួយចំនួនដែលជាផ្លូវភ្ជាប់ឃុំនិងឃុំក៏ត្រូវបានក្រាលកៅស៊ូផងដែរ។ ផ្លូវទាំងអស់ត្រូវបានថែទាំយ៉ាងល្អ។ ផ្លូវទៅកាន់ចម្ការស្ទើរតែទាំងអស់សុទ្ធសឹងស្ថិតនៅក្នុងស្ថានភាពល្អ។

ប្រជាជនប្រមាណពាក់កណ្ដាលនៅខេត្តត្បូងឃ្មុំមានប្រព័ន្ធទឹកម៉ាស៊ីនប្រើប្រាស់។ អ្នកផ្សេងទៀត ប្រើប្រាស់ទឹកអណ្ដូង និងទឹកភ្លៀង។ ការដាំដុះជាទូទៅពឹងផ្អែកលើទឹកភ្លៀង ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតសម្រាប់ផលិតកម្មស្រូវ។ ដំណាំមួយចំនួនដូចជាកៅស៊ូ ម្រេច ស្វាយចន្ទី បន្លែ ដំឡូងមី ឬពោត អាចពឹងផ្អែកលើប្រភពទឹកក្រោមដីផងដែរ។ គម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទត្រូវបានគេគ្រោងនឹងសាងសង់។ គម្រោងនេះជាគម្រោងដែលមានគោលបំណងផ្ដល់ទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារឱ្យមានអនាម័យ។ នៅក្នុងទីក្រុង និងតំបន់លំនៅដ្ឋានមានសេវាអនាម័យ ប៉ុន្តែមិនមានភាពទៀងទាត់ទេ។

អគ្គិសនីសម្រាប់ត្បូងឃ្មុំមានប្រភពមកពីវារីអគ្គិសនីខេត្តស្ទឹងត្រែង និងបណ្ដាញអគ្គិសនីពីប្រទេសវៀតណាម។ យ៉ាងហោចណាស់ ៧០-៨០% នៃគ្រួសារនៅក្នុងខេត្តនេះមានភ្ជាប់បណ្ដាញអគ្គិសនី។ អត្រាថ្លៃអគ្គិសនីគឺ ៤៨០-៧២០ រៀល/គីឡូវ៉ាត់ម៉ោង។ ការផ្គត់ផ្គង់មិនមានស្ថេរភាពទេ (ដាច់រន្តអគ្គិសនី) ជាពិសេសនៅពេលមានភ្លៀងធ្លាក់ខ្លាំង និងព្យុះកើតឡើង។

## ៦.៣. គោលនយោបាយថ្នាក់ក្រោមជាតិ/គោលការណ៍គ្រប់គ្រងស្ថាប័ន

គោលនយោបាយជាតិ និងរចនាសម្ព័ន្ធស្ថាប័ន ត្រូវបានអនុវត្តហើយតែងតែផ្ដល់អាទិភាព។

## ៦.៤. ការស្រាវជ្រាវ និងអភិវឌ្ឍន៍

មិនមានការស្រាវជ្រាវណាត្រូវបានធ្វើឡើយ។ សេវាផ្សព្វផ្សាយត្រូវបានផ្ដល់ជូនជាចម្បងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្នុងវិស័យចិញ្ចឹមសត្វ កសិកម្មតាមកិច្ចសន្យា និងការគ្រប់គ្រងសុវត្ថិភាពចំណីអាហារ និងគុណភាព។ មានការផ្សព្វផ្សាយតិចតួចទាក់ទងនឹងដំឡូងមី និងពោត។ មន្ទីរអនុវត្តសកម្មភាពត្រួតពិនិត្យមួយចំនួនទៅលើរោងម៉ាស៊ីនកិនស្រូវដើម្បីធានាគុណភាព និងសុវត្ថិភាពរបស់រោងម៉ាស៊ីនកិនស្រូវ។ ការស្រាវជ្រាវអំពីផលិតកម្មកសិកម្ម និងសកម្មភាពកសិ-ឧស្សាហកម្មជាតម្រូវការចាំបាច់។

## ៦.៥. សេវាកម្មហិរញ្ញវត្ថុសម្រាប់កសិ-ឧស្សាហកម្ម

ធនាគារធំៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជា អេស៊ីលីដា ប្រាសាក់ និងអម្រឹត មានវត្តមាននៅក្នុងខេត្តត្បូងឃ្មុំ។ អាជីវករ និងកសិករអាចខ្ចីពីស្ថាប័នទាំងនោះ ប៉ុន្តែពួកគេត្រូវមានវត្ថុបញ្ចាំប្រសិនបើកម្ចីមានទំហំធំ។ ដោយសារតែអ្នកខ្ចីខ្វះវត្ថុបញ្ចាំ គេអាចខ្ចីប្រាក់បានតិចតួចប៉ុណ្ណោះដែលមិនគ្រប់គ្រាន់សម្រាប់ការវិនិយោគរយៈពេលវែងឡើយ។

## ៦.៦. ភាពងាយស្រួលនៃការធ្វើជំនួញ

ជាទូទៅការធ្វើអាជីវកម្មនៅខេត្ត អាជីវករ ជាពិសេសអ្នកជំនួញធំៗ អាចចាប់ផ្ដើមអាជីវកម្មរបស់ខ្លួនបានដោយមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ខេត្ត ក្រសួងពាណិជ្ជកម្ម និងភ្នាក់ងារពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។ ការចុះបញ្ជីអាជីវកម្ម ឬសហគ្រាសត្រូវបានធ្វើវិមជ្ឈការ។ ពុំទាន់មានសេវាគាំទ្រការបើកមុខជំនួញ សម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្មនៅឡើយទេ។

### ៦.៧. បច្ចេកវិជ្ជា និងសេវាគាំទ្រការបើកមុខជំនួញ និងការផ្សារភ្ជាប់ទំនាក់ទំនងមុខជំនួញ

ទំនាក់ទំនងពាណិជ្ជកម្មរវាងអ្នកផលិត និងអ្នកទិញ និង/ ឬអ្នកកែច្នៃ និងទីផ្សារក្នុងស្រុកនិងក្នុងតំបន់ ក៏ដូចជាទីផ្សារនៅក្រៅប្រទេសនៅមានកម្រិតទាបខ្លាំងនៅឡើយ។ ឧទាហរណ៍ កសិករនិងអ្នកទិញមិនទាន់យល់ដឹងអំពីការរៀបចំ និងការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា។ មន្ទីកសិកម្មខេត្តបានផ្សព្វផ្សាយព័ត៌មាន និងលើកកម្ពស់កសិកម្មតាមកិច្ចសន្យា។ ពិព័រណ៍ផលិតផល និងវេទិកាដើម្បីផ្សព្វផ្សាយនេះត្រូវបានរៀបចំ និងសម្របសម្រួលដោយមន្ទីរ ប៉ុន្តែពុំទទួលបានការចាប់អារម្មណ៍ទេ ប្រហែលដោយសារអ្នកទិញ និងកសិករមិនទុកចិត្តគ្នា ម្យ៉ាងពួកគេហាក់ដូចមិនឱ្យតំលៃលើអ្នកសម្របសម្រួលមន្ទីរនៅឡើយ។ កសិករ និងអ្នកទិញមានភាពស្ទាក់ស្ទើរក្នុងការធ្វើកសិកម្មតាមកិច្ចសន្យា ពីព្រោះពុំទាន់បានឃើញផលប្រយោជន៍ណាមួយឡើយ។ លើសពីនេះទៀត ប្រសិនបើមានជម្លោះ ឬការរំលោភបំពានទាក់ទងនឹងការអនុវត្តកិច្ចសន្យានោះ គ្មានយន្តការអនុវត្តច្បាប់ដែលអាចទទួលយកបាន ឬគួរទុកចិត្តនោះទេ។ ពួកគេមិនចង់ដោះស្រាយតាមរយៈតុលាការទេ ប្រសិនបើមានជម្លោះ។ ការឆ្លងកាត់តុលាការត្រូវការពេលវេលាច្រើនណាស់ ដែលមិនសមស្របសម្រាប់កសិផលដែលអាចខូចរលួយ និងមានតម្លៃថ្លៃដើម្បីថែរក្សា និងស្តុកទុក។ បច្ចេកវិជ្ជាសម្រាប់វិស័យកសិ-ឧស្សាហកម្មនៅមានកម្រិត ឬស្ទើរតែគ្មាន។

## ៧. សរុបសេចក្តី និងអនុសាសន៍

### ៧.១. អាទិភាពកសិ-ឧស្សាហកម្ម

មានកសិផលសក្តានុពលចំនួនប្រាំសម្រាប់សាកល្បង និងអភិវឌ្ឍន៍កសិ-ឧស្សាហកម្មនៅខេត្តត្បូងឃ្មុំ រួមមាន កៅស៊ូ ស្រូវ ម្រេច ដំឡូងមី និងស្វាយចន្ទី។ បច្ចុប្បន្ននេះ មានរោងចក្រកែច្នៃផលិតផលកៅស៊ូចំនួន៦០ក្រុមហ៊ុន និងរោងម៉ាស៊ីនកិនស្រូវ ១២ សហគ្រាសកែច្នៃស្វាយកែវរមៀត ០១ សហគ្រាសកែច្នៃគ្រាប់ស្វាយចន្ទី០១ រោងចក្រកែច្នៃសណ្តែកដី ០១ រោងចក្រកែច្នៃដំឡូងមី ០២ និងក្រុមហ៊ុនគ្រីនហ្វីតដែលទិញដំឡូងមី និងគ្រាប់ពោតសម្រាប់ផលិតចំណីមាន់ និងចំណីជ្រូក។ ក៏ប៉ុន្តែ ក្រុមហ៊ុនអស់នេះពុំអាចទាញយកកសិផលទាំងអស់បាននោះទេ។ ដូច្នេះ ផលិតផលវត្ថុធាតុដើមជាច្រើនហួសប្រមាណកំពុងត្រូវបាននាំចេញទៅប្រទេសវៀតណាម។ គម្រោងសាកល្បង ដែលមានសក្តានុពលអាចរួមបញ្ចូលក្នុងវិស័យកសិ-ឧស្សាហកម្ម រួមមាន ការកែច្នៃដំឡូងមីទៅជាម្សៅ សរសៃមី អេតាណុល ស្រាផលិតផលគ្រឿងសម្អាង សម្ភារវេចខ្ចប់។

ចំពោះកៅស៊ូ ទីផ្សារនាំចេញសំខាន់គឺប្រទេសវៀតណាម ថៃ ម៉ាឡេ សិង្ហបុរី ហើយការនាំចេញគឺមានលក្ខណៈធំជាងគេនៅទូទាំងប្រទេស។ ឥឡូវនេះ មានក្រុមហ៊ុនចិនមួយនឹងធ្វើសកម្មភាពមួយចំនួនក្នុងចំណោមសកម្មភាពទាំងអស់នោះនៅក្នុងប្រទេស។ សកម្មភាពពាក់ព័ន្ធនឹងការនាំចេញគួរធ្វើឡើងនៅក្នុងខេត្តតែម្តង ដើម្បីបង្កើនតម្លៃបន្ថែម។ កសិផលអាចនឹងមានបរិមាណច្រើនឈានដល់អតិរេក ហើយផ្លែឈើដែលមានចំណាត់ថ្នាក់ទាប ទាមទារឱ្យមានការកែច្នៃដើម្បីបំពេញតម្រូវការទីផ្សារ និងទទួលបានតម្លៃបន្ថែម។ គម្រោងសាកល្បងអាចផ្តោតលើផ្នែកកសិ-ឧស្សាហកម្មនេះ។

## ៧.២. កត្តារាំងស្ទះចម្បងៗ

កត្តារាំងស្ទះដល់ការអភិវឌ្ឍកសិ-ឧស្សាហកម្មនៅខេត្តត្បូងឃ្មុំ គឺការខ្វះខាតលទ្ធភាពប្រើប្រាស់បច្ចេកវិជ្ជាដែលពាក់ព័ន្ធ (រួមមាន ឧបករណ៍ សម្ភារ និងម៉ាស៊ីនបច្ចេកទេស) និងធនធានមនុស្សដែលមានជំនាញ។ គុណភាព និងការទុកចិត្តលើកសិផលដែលកែច្នៃក្នុងស្រុកក៏ជាបញ្ហាផងដែរ។ អ្នកប្រើប្រាស់មិនទាន់ប្រាកដចិត្តលើសុវត្ថិភាពម្ហូបអាហារ ឬភេសជ្ជៈដែលបានកែច្នៃនៅក្នុងស្រុក ឧទាហរណ៍ដូចជាការដាក់ស្លាកសម្គាល់ និងលិខិតបញ្ជាក់ដែលជឿទុកចិត្ត។ ឥណទានមានតម្លៃថ្លៃ ហើយតម្រូវឱ្យមានវត្ថុបញ្ចាំ។ តម្លៃដឹកជញ្ជូននៅតែខ្ពស់។ នេះអាចជាបញ្ហាប្រឈមមួយសម្រាប់អ្នកកែច្នៃនិងអ្នកនាំចេញ ព្រោះវាប៉ះពាល់ដល់ការប្រកួតប្រជែងរបស់ផលិតផលចុងក្រោយទំរាំដល់អ្នកប្រើប្រាស់។

## ៧.៣. ឱកាសវិនិយោគ និងតួនាទីរបស់វិស័យឯកជន

មានតម្រូវការជាបន្ទាន់ និងចាំបាច់សម្រាប់ការងារស្រាវជ្រាវលើផលិតកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម ជាពិសេសការស្រាវជ្រាវដែលទាក់ទងទៅនឹងដំឡូងមី ម្រេច ស្វាយចន្ទី និងពោត។ ពុំទាន់អាចប៉ាន់ស្មានខ្ទង់ឱកាសវិនិយោគបាននៅឡើយ។

តួនាទីសំខាន់របស់វិស័យឯកជនមានដូចជា ការធ្វើទីផ្សារ ការផ្តល់សេវាជួសជុលគ្រឿងយន្តកសិកម្ម និងម៉ាស៊ីនរោងចក្រ ការចែកចាយធាតុចូលដោយមានឥណទានតម្លៃទាប។

## អត្ថបទទី៥÷ បទពិសោធន៍ពីវិស័យអង្ករ[៥]

រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងនាំចេញអង្ករក្នុងឆ្នាំ២០១០។ ការអនុវត្តគោលនយោបាយនេះបានបង្ហាញនូវភាពប្រសើរឡើងនៅក្នុងប្រព័ន្ធឡូជីស្ទិកកម្ពុជាក្នុងអំឡុងឆ្នាំ២០០៩ និង២០១៥។ ដំណើរការនាំចេញត្រូវបានធ្វើឱ្យមានប្រសិទ្ធភាពជាងមុន ហើយថ្លៃដើមឡូជីស្ទិកក៏ត្រូវបានកាត់បន្ថយផងដែរ។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន រួមទាំងផ្លូវរថភ្លើងពីប៉ោយប៉ែតទៅភ្នំពេញ និងភ្នំពេញទៅខេត្តព្រះសីហនុ និងកំពង់ផែខេត្តព្រះសីហនុត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង។ បទប្បញ្ញត្តិស្តីពីអនាម័យ និងភូតគាមអនាម័យ និងសមត្ថភាពភូតគាមអនាម័យត្រូវបានធ្វើឱ្យប្រសើរឡើង។ ប៉ុន្តែកម្ពុជានៅតែស្ថិតពីក្រោយប្រទេសជិតខាងរបស់ខ្លួនទាំងផ្នែកឡូជីស្ទិក និងការអនុលោមតាមភូតគាមអនាម័យ។

គោលនយោបាយនេះបានរៀបចំផ្លូវសម្រាប់អភិវឌ្ឍវិស័យរោងម៉ាស៊ីនកិនស្រូវ និងផ្តល់ប្រយោជន៍សម្រាប់វិស័យកសិ-ឧស្សាហកម្មជារួម។ គោលដៅអង្ករ ១,០ លានតោន សម្រាប់នាំចេញឱ្យបានក្នុងឆ្នាំ២០១៥ ពុំបានសម្រេចនោះទេ ប៉ុន្តែគោលនយោបាយនេះបានជួយសម្របសម្រួល (១) ការកើនឡើងយ៉ាងគំហុកនៃការវិនិយោគរបស់វិស័យឯកជនក្នុងការកិន និងប៉ូលៀរអង្ករ (២) កំណើនការនាំចេញអង្ករ និង(៣) ការកកើតនៃសហព័ន្ធស្រូវអង្ករកម្ពុជាដែលជាតួអង្គសំខាន់ក្នុងវិស័យអង្ករ។

ថ្វីបើមានការកើនឡើងនៃការវិនិយោគ និងវត្តមានក្រុមហ៊ុនកិនស្រូវជាច្រើន កិច្ចការនេះ (១) ពុំបានបង្កើតប្រព័ន្ធគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់ឱ្យបានរឹងមាំនោះទេ និង (២) មានបញ្ហាប្រឈមក្នុងការទទួលបានហិរញ្ញប្បទាន។ ទោះបីជារាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្ត ហើយរោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញហាក់ដូចជាធ្វើការជាមួយគ្នាក្រោមស្ថាប័នកំពូលតែមួយ គឺសហព័ន្ធស្រូវអង្ករកម្ពុជាក៏ដោយ ប៉ុន្តែមានករណីច្រើនណាស់ដែលស្រូវអង្ករត្រូវបានធ្វើពាណិជ្ជកម្មដោយគ្មានតម្លៃបន្ថែមរហូតដល់ឆ្នាំ២០១៨ ខណៈដែលអង្ករក្រអូបរបស់កម្ពុជាទទួលបានរង្វាន់ថាជាអង្ករល្អបំផុតនៅលើពិភពលោកជាច្រើនដងមកហើយ។

ការវិនិយោគ ទាំងតាមរយៈវិស័យសាធារណៈនិងឯកជន ក្នុងការស្រាវជ្រាវ និងវិបុលកម្មនៅមានកម្រិតទាបក្នុងអំឡុងរយៈពេលគោលនយោបាយ។ ចំណុចនេះ បង្កឱ្យមានការរាំងស្ទះនៃផលិតភាពក្នុងការផលិតស្រូវ ដែលជាលទ្ធផលប៉ះពាល់ដល់ភាពដែលអាចរកបាន និងការប្រើប្រាស់បច្ចេកវិជ្ជាដែលមាននវានុវត្តន៍គឺចាំបាច់ ដើម្បីបង្កើនផលិតភាព។ ផលិតភាពនៅក្នុងកម្រិតកសិដ្ឋាន និងចំណូលសម្រាប់កសិករនៅមានទាប ថ្វីបើមានការប្រើប្រាស់ជី និងឧបករណ៍កសិដ្ឋានជាច្រើន មានការបង្កើនការវិនិយោគក្នុងប្រព័ន្ធធារាសាស្ត្រ បង្កើនលទ្ធភាពរបស់កសិករក្នុងការទទួលបានប្រាក់កម្ចី បង្កើនវិនិយោគក្នុងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទនិងអគ្គិសនី។

---

[៥] *ដកស្រង់ចេញពីបទពិសោធន៍នៃគោលនយោបាយជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករឆ្នាំ២០១០ ដែលតាក់តែងឡើងដោយលោកស្រី ចន្នី និងលោក ហ្វ្រង់សេសស្កូ ឆ្នាំ២០១៦។*

## ឧបសម្ព័ន្ធទី២÷ ផលិតកម្មកសិកម្មតាមកិច្ចសន្យា

ផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺជាវិធីសាស្ត្រផ្អែកលើប្រតិបត្តិការដើម្បីសម្របសម្រួលក្នុងខ្សែច្រវាក់តម្លៃកសិចំណីអាហារ។ ថ្វីបើផលិតកម្មកសិកម្មតាមកិច្ចសន្យាត្រូវបានប្រើប្រាស់ជាច្រើនសតវត្សរ៍កន្លងមក និងទទួលបានលទ្ធផលផ្សេងៗគ្នាយ៉ាងណាក្តី ក៏វិធីសាស្ត្រនេះទទួលបានចំណាប់អារម្មណ៍កាន់តែខ្លាំង សម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងទីផ្សារនិងផលិតកម្មចំណីអាហារ។ បញ្ហាទាំងនោះរួមមាន÷ ការកើនឡើងនៃតម្រូវការគុណភាព បរិស្ថានភាពដែលអាចតាមដានដល់ប្រភពដើមនិងការបញ្ជាក់នានា ការកើនឡើងនៃតម្រូវការកម្លាំងពលកម្ម និងដីកសិកម្ម (យោងតាម Will/GIZ ឆ្នាំ២០១៣)។

ក្នុងកម្រិតមូលដ្ឋានបំផុត ផលិតកម្មកសិកម្មតាមកិច្ចសន្យាផ្តល់នូវមធ្យោបាយដ៏មានសក្តានុពលភាព ក្នុងការកាត់បន្ថយថ្លៃដើមប្រតិបត្តិការ ទាក់ទងនឹងការផ្តល់ប្រភពនៃកសិផល ហើយត្រលប់មកវិញ ការនាំកសិផលទាំងនេះទៅកាន់ទីផ្សារ។ ថ្វីបើពុំមានគំរូផលិតកម្មកសិកម្មតាមកិច្ចសន្យាណាមួយសោះក៏ដោយ ជាទូទៅ ការធ្វើបែបនេះគឺពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងជាផ្លូវការ ជាញឹកញយរវាងអ្នកផលិតជាច្រើន និងយ៉ាងហោចណាស់ជាមួយនឹងអ្នកទិញម្នាក់ ដូចជាអ្នកកែច្នៃ ឬឈ្មួញ ដើម្បីទិញ/លក់ កសិផលផ្អែកទៅលើលក្ខខណ្ឌដែលបានព្រមព្រៀងគ្នាទុកជាមុន។ បន្ថែមពីលើនោះ ជាទូទៅកិច្ចព្រមព្រៀងផលិតកម្មកសិកម្មតាមកិច្ចសន្យា នឹងជួយដោះស្រាយបញ្ហាយន្តការទីផ្សារ ទាក់ទងនឹងការផ្គត់ផ្គង់ធាតុចូលកសិកម្ម បច្ចេកវិជ្ជា និងសេវាកម្មកសិកម្មនានា(ដូចជា សេវាកម្មហិរញ្ញវត្ថុ ការផ្សព្វផ្សាយកសិកម្ម បណ្តុះបណ្តាល ការដឹកជញ្ជូន និងឡូជីស្ទិក) ដោយឱ្យអ្នកទិញឬភាគីទីបីផ្តល់សេវាទាំងអស់នេះទៅកសិករ។

ផលិតកម្មកសិកម្មតាមកិច្ចសន្យា ក៏បានក្លាយជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់ក្រុមហ៊ុនកែច្នៃ និងជំនួញមួយចំនួន ដែលកំពុងមានបញ្ហាពាក់ព័ន្ធនឹងកង្វះដី កម្លាំងពលកម្ម ឬក៏ធនធានដទៃទៀត ក៏ដូចជាការកើនឡើងនៃសម្ពាធដើម្បីអាចទទួលបាននូវបទដ្ឋានដែលអាចបន្សល់ដាន បទដ្ឋានគុណភាព បទដ្ឋានសុវត្ថិភាពចំណីអាហារ បទដ្ឋានការប្រើប្រាស់ដី បទដ្ឋានសង្គម បទដ្ឋានកម្លាំងពលកម្ម និងបទដ្ឋានបរិស្ថានដ៏តឹងរឹង។ ក្នុងបរិបទខ្លះទៀត ម្ចាស់កសិដ្ឋានខ្នាតតូចមួយចំនួន អាចក្លាយជាប្រភពនៃឧត្តមភាពប្រកួតប្រជែង តាមរយៈការផ្តល់នូវលទ្ធភាពទទួលបានធនធានកម្លាំងពលកម្មនិងដីក្នុងបរិមាណតិចជាងមុន ព្រមទាំងចំណេះដឹងគ្រឹះកសិកម្ម (Will/GIZ ឆ្នាំ២០១៣)។ ហើយការរៀបចំដែលមើលឆ្ពោះទៅអនាគត និងគ្រប់ជ្រុងជ្រោយជាមួយនឹងអ្នកផលិតបែបនោះនឹងអាចកាត់បន្ថយថ្លៃដើម និងបង្កើនលទ្ធភាពក្នុងការអនុលោមតាមបទដ្ឋានដែលបានកំណត់។ អ្នកបញ្ជាទិញអាចចូលរួមពាក់ព័ន្ធនឹងសកម្មភាព រាប់ចាប់តាំងពីការផ្តល់ឬការកំណត់គ្រាប់ពូជឱ្យប្រើប្រាស់ រហូតដល់ការគ្រប់គ្រងផ្ទាល់ឬវិនិយោគ លើផ្នែកផ្សេងៗនៃការងារផលិតកម្ម ដែលរួមមានចាប់តាំងពីការរៀបចំដីរហូតដល់ប្រមូលផល។ ការរៀបចំការអនុវត្តការងារបែបនេះកើតឡើង ពិសេសនៅពេលដែលគេតម្រូវឱ្យកសិផលដែលប្រមូលផលបាន មានគុណភាពល្អដូចៗគ្នាឬមានលក្ខណៈជាឯកសណ្ឋាន ដើម្បីអនុកូលដល់ការកែច្នៃ(ឧ. អំពៅ កប្បាស កាហ្វេ តែ ផលិតផលទឹកដោះ បសុសត្វ ជាដើម) (Will/GIZ ឆ្នាំ២០១៣)។

នៅពេលដែលការធ្វើបែបនេះដំណើរការបានល្អ ផលិតកម្មកសិកម្មតាមកិច្ចសន្យាអាចផ្តល់ឱ្យអ្នកទិញនូវភាពស៊ីសង្វាក់គ្នាយ៉ាងល្អប្រសើរបើនិយាយពីផលិតផលដែលមានគុណភាព និងបរិមាណដែលមានភាពស៊ីសង្វាក់គ្នាយ៉ាងល្អ តម្រូវការអតិថិជននិងការផ្គត់ផ្គង់ក៏កាន់តែមានសង្គតិភាព និងកាត់បន្ថយថ្លៃដើមនិងហានិភ័យប្រតិបត្តិការ។ សម្រាប់ម្ចាស់កសិដ្ឋានខ្នាតតូច អត្ថប្រយោជន៍រួមនៃផលិតកម្មកសិកម្មតាមកិច្ចសន្យា គឺការចូលទៅរកទីផ្សារបានកាន់តែប្រសើរជាងមុន ប្ញកររួមនឹងប្រាក់ចំណូលដែលច្រើនជាង និងមានស្ថិរភាពជាង។ រួមជាមួយនឹងការរៀបចំមួយចំនួនអ្នកផលិតចរចាអត្ថប្រយោជន៍ស្មើភាព (ឧ. ក្លាយជាសហកម្មសិទ្ធិ) នៃទ្រព្យផលិត ដូចជា ដី និងសម្ភារកែច្នៃជាដើម។

ទោះបីវិស័យឯកជនជាអ្នកអនុវត្តន៍ផលិតកម្មកសិកម្មតាមកិច្ចសន្យាយ៉ាងណាក្តី ក៏ទាមទារនូវការគាំទ្រពីរដ្ឋាភិបាលផងដែរ ដើម្បីសម្រួលដល់ដំណើការរៀបចំការអនុវត្ត ពីព្រោះថាផលិតកម្មកសិកម្មតាមកិច្ចសន្យានេះនឹងជួយឱ្យសម្រេចបានគោលដៅគោលនយោបាយចម្បងៗ ដូចជា ការអភិវឌ្ឍដោយបរិយាប័ន្ន សន្តិសុខស្បៀង ឬការការពារធនធានធម្មជាតិ។ បន្ថែមលើការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលដល់ធុរកិច្ច (ឧ. នីតិរដ្ឋ គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធ សុខភាព និងការអប់រំ ស្ថិរភាពនយោបាយ ទីផ្សារហិរញ្ញវត្ថុ ។ល។) រាជរដ្ឋាភិបាលអាចជំរុញការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យា តាមរយៈកិច្ចសម្របសម្រួលទំនាក់ទំនងរវាងដៃគូភាគី ការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យា ការរៀបចំឱ្យមានការលើកទឹកចិត្តបែបសេដ្ឋកិច្ច ការកសាងសមត្ថភាពស្ថាប័ន និងការអប់រំភាគីពាក់ព័ន្ធអំពីអត្ថប្រយោជន៍ និងហានិភ័យដែលអាចកើតមាន។ ប្រទេសឥណ្ឌា វៀតណាម ម៉ារ៉ុក ថៃ និងប្រទេសផ្សេងទៀត បានបង្កើតគោលនយោបាយ ក្នុងគោលបំណងលើកកម្ពស់ផលិតកម្មកសិកម្មតាមកិច្ចសន្យា (Will/GIZ ឆ្នាំ២០១៣)។ ប្រអប់ទី១ផ្តល់ឧទាហរណ៍អំពីវិធីសាស្ត្រដែលវិស័យសាធារណៈដឹកនាំធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យានៅក្នុងប្រទេសចិន។ ដូចដែលបានលើកឡើង វិស័យសាធារណៈត្រូវធ្វើដោយប្រុងប្រយ័ត្ន។ ការរៀបចំឱ្យមានផលិតកម្មកសិកម្មតាមកិច្ចសន្យាមួយចំនួន បានបរាជ័យដោយសារតែការសម្របសម្រួលក្នុងវិស័យសាធារណៈ ឬវិស័យមិនរកប្រាក់ចំណេញ ដែលដើរមុនតួអង្គខ្សែច្រវាក់តម្លៃ និងរុញឱ្យមានការរៀបចំដែលមិនស្របនឹងសមត្ថភាព មហិច្ឆតា ឥរិយាបទទទួលយក ហានិភ័យ ឬកម្រិតនៃការទុកចិត្តដែលមានស្រាប់ ឬក៏ការដាក់គោលដៅអភិវឌ្ឍន៍មុនការផ្តល់ផលចំណេញរបស់អាជីវកម្ម។

(ប្រភព÷ ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៦)

### ប្រអប់ទី១. សហគ្រាសក្បាលនាគ៖ របៀបដែលអាស៊ីខាងជើងចាប់យកផលិតកម្មកសិកម្មតាមកិច្ចសន្យា

ដោយដើរតួសំខាន់ក្នុងការជំរុញផលិតកម្មកសិកម្មតាមកិច្ចសន្យា គំរូអនុវត្តន៍តាមបែប "សហគ្រាសក្បាលនាគ" របស់ប្រទេសចិន បានក្លាយទៅជាចំណុចស្នូលនៃយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលចិន ក្នុងការលើកកម្ពស់ការសម្របសម្រួលតាមខ្សែបណ្ដោយនៃខ្សែច្រវាក់តម្លៃកសិកម្ម និងជួយដល់កសិករដើម្បីអាចរកទីផ្សារដែលមានតម្លៃខ្ពស់ជាង តាមរយៈការភ្ជាប់ទំនាក់ទំនងជាមួយសហគ្រាសកសិ-ឧស្សាហកម្មឈានមុខ។ រដ្ឋាភិបាលចិនអាចធ្វើបែបនេះទៅបានដោយផ្ដល់ការឧបត្ថម្ភធនដូចជាការលើកទឹកចិត្តសារពើពន្ធ ទៅឱ្យក្រុមហ៊ុនឈានមុខដែលមានគុណសម្បត្តិទទួលបានស្លាកសញ្ញាក្បាលនាគ។ ដើម្បីអាចទទួលបានស្លាកសញ្ញានេះ ក្រុមហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌមួយចំនួន ក្នុងនោះមានលក្ខខណ្ឌមួយដែលតម្រូវឱ្យក្រុមហ៊ុនទិញវត្ថុធាតុដើមពីកសិករខ្នាតតូច ឱ្យបានយ៉ាងហោចណាស់ ៧០% នៃវត្ថុធាតុដើមសរុបសម្រាប់ប្រើក្នុងដំណើរការកែច្នៃឬចែកចាយរបស់ក្រុមហ៊ុន។ ចំណែកឯកសិករវិញត្រូវចូលរួមក្នុងសហគមន៍កសិកម្ម ដើម្បីផ្គត់ផ្គង់ផលិតផលរបស់ខ្លួនដល់ក្រុមហ៊ុនទាំងនោះ។ ស្របពេលជាមួយគ្នាដែរ រដ្ឋាភិបាលក៏គាំទ្រយ៉ាងសកម្មដល់សហគមន៍កសិកម្ម ដែលគេឃើញថាជាការបង្កើនសមត្ថភាពអ្នកផលិតខ្នាតតូចដើម្បីអាចបំពេញតាមតម្រូវការគុណភាព និងសុវត្ថិភាពចំណីអាហារ។ ការគាំទ្រនេះមិនមែនមានតែផ្នែកហិរញ្ញវត្ថុនោះទេ (ដែលរួមមានការផ្ដល់កម្ចី ការអនុគ្រោះពន្ធ និងការគាំទ្រផ្ទាល់) គឺថែមទាំងមានជាការរៀបចំកិច្ចប្រជុំគៀងគរ ការផ្ដល់ដីនិងទីតាំងការិយាល័យ និងការប្រគល់រង្វាន់ទៀតផង (យោងតាម Verhofstadt និងសហការី ឆ្នាំ២០១៨)។ គំរូសហគ្រាសក្បាលនាគ មានសណ្ឋានស្រដៀងទៅនឹងគំរូបណ្ដុំកសិកម្ម និងទំនាក់ទំនងមិនផ្លូវការដើម្បីភ្ជាប់តួអង្គផ្សេងៗក្នុងខ្សែច្រវាក់តម្លៃ។ ក៏ប៉ុន្តែ លក្ខណៈខុសប្លែកពីគំរូបណ្ដុំកសិកម្ម គឺនៅត្រង់ថា គំរូក្បាលនាគផ្ដោតលើក្រុមហ៊ុនតែមួយឬមួយចំនួនតិច ជាជាងពហុក្រុមហ៊ុនក្នុងការរៀបចំឱ្យមានសកម្មភាពសហគមន៍កសិកម្ម។ ក្នុងន័យនេះ ការធ្វើបែបនេះហាក់ដូចជាភ្ជាប់ទំនាក់ទំនងខ្លាំងទៅនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យា។ ទីតាំងកណ្ដាលនៃខ្សែច្រវាក់តម្លៃនេះកើតមានក្នុងវិធីសាស្ត្រទាំងនេះ ដែលហាក់ដូចជាភ្ជាប់ទំនាក់ទំនង និងលើកកម្ពស់កិច្ចសហការណ៍ និងការប្រកួតប្រជែងយ៉ាងសកម្មក្នុងចំណោមតួអង្គនៃខ្សែច្រវាក់តម្លៃ ហាក់នៅថ្មីនៅឡើយសម្រាប់ប្រទេសចិន។ រហូតដល់ពេលថ្មីៗនេះ ផ្នែកផ្សេងៗនៃខ្សែច្រវាក់តម្លៃត្រូវបានដាក់ក្នុងបទប្បញ្ញត្តិនៃច្បាប់នៃភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា ហើយត្រូវបានធ្វើការដោយឡែកៗពីគ្នា។ ឥឡូវនេះក្រសួងកសិកម្មត្រូវបានពង្រឹងអំណាចដើម្បីអាចគាំទ្រច្រវាក់តម្លៃទាំងមូល ដោយរដ្ឋាភិបាលបានកាត់បន្ថយឬដកហូតតួនាទីចេញពីក្រសួងផ្សេងទៀត (Galvez-Nogales/FAO ឆ្នាំ២០១០)។

## ឧបសម្ព័ន្ធទី៣៖ អភិបាលកិច្ចសុវត្ថិភាពចំណីអាហារ

## *(សុវត្ថិភាពចំណីអាហារ និងការធានាគុណភាព)*

រដ្ឋាភិបាលនៅតាមប្រទេសជាច្រើន បានរឹតបន្តឹងការត្រួតពិនិត្យនិងបទបញ្ញត្តិ ទាក់ទងនឹងសុវត្ថិភាពចំណីអាហារ។ ទន្ទឹមគ្នានេះ ក្រុមហ៊ុនឯកជនក៏បានពង្រឹងយន្តការផ្ទៃក្នុងរបស់ខ្លួនផងដែរ ហើយបានបង្កើតយន្តការផ្ទាល់ខ្លួនសម្រាប់គ្រប់គ្រងសុវត្ថិភាពចំណីអាហារ ដែលរួមបញ្ចូលទាំងបែបបទដែលក្រុមហ៊ុនបង្កើតឡើង ដោយស្ម័គ្រចិត្តខ្លួនឯង ត្រូវបានតម្រូវដោយច្បាប់ ឬតាមកិច្ចព្រមព្រៀងនានា។ វិស័យសាធារណៈនៅក្នុងប្រទេសនិងតំបន់មួយចំនួនរួមមាន ប្រទេសកាណាដា ណូវែលហ្សេឡង់ និងអឺរ៉ុប បានជំរុញកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងរដ្ឋាភិបាលនិងក្រុមហ៊ុនឯកជន។ នេះជាអភិក្រមមួយដែលគេស្គាល់ជាទូទៅថា “សហនិយ័តកម្ម” ឬការកំណត់លក្ខខណ្ឌត្រួតពិនិត្យនិងគ្រប់គ្រងរួមគ្នា។

ដោយឃើញថាប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ ដែលពឹងផ្អែកលើយន្តការទីផ្សារទាំងស្រុង ពុំអាចផ្តល់លទ្ធផលគាប់ប្រសើរសម្រាប់សង្គម ម៉ាទីណេស៍និងសហការី(ឆ្នាំ២០០៧) បានគូសបញ្ជាក់អំពីសារៈប្រយោជន៍នៃសហនិយ័តកម្មលើប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ ដោយបានប្រៀបធៀប ទៅនឹងជម្រើសអភិក្រមផ្សេងមួយទៀតដែលមានលក្ខណៈបង្ខំឱ្យអនុវត្តឬដាក់កំហិតទាំងស្រុង ដែល “អាចពង្រឹងការអនុលោមតាមបទដ្ឋានសុវត្ថិភាពដែលបានកំណត់ ក៏ប៉ុន្តែពុំអាចផ្តល់លទ្ធផលគាប់ប្រសើរចំពោះការរក្សាសុខភាពសាធារណៈ ហើយម្យ៉ាងទៀតត្រូវចំណាយធនធានច្រើន សម្រាប់ការងារតាមដាននិងត្រួតពិនិត្យ”។ កិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលឱ្យបានល្អប្រសើរ រវាងវិស័យឯកជននិងសាធារណៈ អាចនឹងមានប្រយោជន៍(ទាំងប្រសិទ្ធភាពនិងប្រសិទ្ធផល) ជាពិសេសនៅពេលប្រើទាក់ទងនឹងការកំណត់បទដ្ឋានសុវត្ថិភាពចំណីអាហារ រួមទាំងការអនុវត្ត ការតាមដាន និងការពង្រឹងការអនុវត្តផងដែរ។

សហនិយ័តកម្ម ជាទូទៅពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជននិងសាធារណៈ ដើម្បីបង្កើតវិធានថ្មីៗ ក្នុងទម្រង់ជាកិច្ចព្រមព្រៀងឬបទដ្ឋានសុវត្ថិភាពចំណីអាហារ ដែលតម្រូវដោយច្បាប់ ជាកាតព្វកិច្ច ឬដោយស្ម័គ្រចិត្តសុទ្ធសាធ។ វិស័យសាធារណៈនៅប្រទេសមួយចំនួន មាននិន្នាការប្រើប្រាស់កាន់តែច្រើនឡើង នូវបទដ្ឋានវិធីសាស្ត្ររួមមួយសម្រាប់វាយតម្លៃបែបសត្យានុម័ត ដោយថ្លឹងថ្លែងអំពីអត្ថប្រយោជន៍និងហានិភ័យ នៃការធ្វើនិយ័តកម្មណាមួយ មុនពេលសម្រេចដាក់ឱ្យអនុវត្ត។ ការវាយតម្លៃបែបនេះជារឿយៗ អាចអនុញ្ញាតឱ្យវិស័យឯកជនចូលរួមបានតិចតួចពេក ឬក៏យឺតពេលពេក។ ក្នុងបរិបទនេះ សហនិយ័តកម្មគឺជាមធ្យោបាយមួយ ដែលអាចកែលម្អស្ថានភាពនេះបាន។

ក្នុងករណីខ្លះ រដ្ឋាភិបាលបានជំរុញវិស័យឯកជន ឱ្យអភិវឌ្ឍនិងអនុវត្តបទដ្ឋានផ្ទៃក្នុងរបស់ខ្លួន។ ឧទាហរណ៍ នៅប្រទេសកាណាដា ការជំរុញឱ្យអភិវឌ្ឍកម្មវិធីចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់ (HACCP)[១០] នៅតាមកសិដ្ឋានផ្ទាល់ កើតចេញមកពីអង្គភាពគ្រឿងបរិភោគមួយចំនួន (ជាពិសេស សាច់ជ្រូក សាច់មាន់ និងស៊ុត) ដែលអង្គភាពទាំងនេះចាប់ផ្តើមបង្កើតនូវវិធានបែបស្ម័គ្រចិត្តសម្រាប់ការអនុវត្តដោយសុវត្ថិភាព។ ដោយបានឃើញនូវកិច្ចប្រឹងប្រែងទាំងនេះ រដ្ឋាភិបាលបានឈានជើងចូលក្នុងនាមជាអ្នកសម្របសម្រួល ហើយជាចុងក្រោយក៏នាំឱ្យមានការទទួលស្គាល់ជាផ្លូវការនូវកម្មវិធីសម្រាប់គ្រឿងបរិភោគនីមួយៗ នៃភ្នាក់ងារអធិការកិច្ចចំណីអាហារកាណាដា។ ផ្ទុយមកវិញ ការអភិវឌ្ឍបទដ្ឋានសរីរាង្គដោយស្ម័គ្រចិត្តជាតិរបស់មន្ទីរកសិកម្មអាមេរិកក្នុងដើមឆ្នាំ២០០០ បានបង្ហាញថាអវត្តមាននៃការគ្រប់គ្រងរួម អាចបង្កឱ្យមានកិច្ចប្រឹងប្រែងជាន់គ្នា និងដំណើរការយឺតយ៉ាវ។ ក្នុងករណីនេះ ថ្វីបើមានអ្នកទទួលបានវិញ្ញាបនបត្រសរីរាង្គចំនួន ៥០ បានធ្វើប្រតិបត្តិការមុនពេលការដាក់ចេញនូវបទដ្ឋាននេះ (ចេញដោយមន្ទីរកសិកម្មអាមេរិក) ក៏ដោយ ក៏បទដ្ឋានជាតិពុំមានបំណងបន្តសកម្មភាពទាំងនេះនោះទេ ហើយកម្មវិធីកំណត់ផ្លាកសញ្ញាចំណាយពេលអស់១០ឆ្នាំ ដើម្បីបង្កើត (ម៉ាទីនស៍ និងអ្នកផ្សេងទៀត ឆ្នាំ២០០៧)។

(ប្រភព÷ ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៦)

---

[១០] *យោងតាមអាជ្ញាធរគ្រប់គ្រងចំណីអាហារនិងឱសថរបស់សហរដ្ឋអាមេរិក(FDA) ចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) គឺជា៖ ប្រព័ន្ធគ្រប់គ្រងដែលបញ្ហាសុវត្ថិភាពចំណីអាហារត្រូវបានដោះស្រាយ តាមរយៈការវិភាគ និងត្រួតពិនិត្យជីវសាស្ត្រ គីមីសាស្ត្រ និងគ្រោះថ្នាក់រូបវន្ត ដែលកើតចេញពីការផលិត ការទិញ និងការគ្រប់គ្រងវត្ថុធាតុដើមសម្រាប់ការផលិត ការចែកចាយ និងការប្រើប្រាស់ផលិតផលសម្រេច។*

http://www.fda.gov/Food/GuidanceRegulation/HACCP/

## ឧបសម្ព័ន្ធទី៤៖ បណ្តុំកសិ-ឧស្សាហកម្ម

បណ្តុំកសិ-ឧស្សាហកម្ម[១១] ជំរុញអន្តរកម្មរវាងតួអង្គទាំងអស់នៃខ្សែច្រវាក់តម្លៃ រួមទាំងស្ថាប័នសាធារណៈ ដើម្បីជួយដល់នវានុវត្តន៍ និងការប្រកួតប្រជែង។ ការលើកកម្ពស់បណ្តុំកសិ-ឧស្សាហកម្មពីសំណាក់វិស័យសាធារណៈបានលេចឡើងជាការឆ្លើយតបមួយ ទៅកាន់សម្ពាធផលិតភាពនិងទីផ្សារ មកលើកសិ-ឧស្សាហកម្មដែលរងឥទ្ធិពលពីសកលភាវូបនីយកម្ម បទដ្ឋាននីយកម្ម ការផលិតតម្លៃខ្ពស់ កំណើនតម្រូវការដ៏ច្រើន នវានុវត្តន៍នៃការវេចខ្ចប់ និងលក់រាយ និងការបង្កើនប្រសិទ្ធភាព (ហ្កាលវេស-ណូហ្កាលស៍/FAO ឆ្នាំ២០១០)។ ការធ្វើបែបនេះអាចជួយបាន ជាពិសេស ដល់ការនាំចេញកសិកម្ម តាមរយៈការបង្កើនផលិតភាព បន្ថែមតម្លៃ និងការចូលទៅកាន់ទីផ្សារដែលមានតម្លៃថ្លៃ។ ម្យ៉ាងវិញទៀត ការធ្វើបែបនេះក៏មានប្រយោជន៍សម្រាប់អ្នកផលិតខ្នាតតូចផងដែរ ដោយអាចឱ្យគេចូលរួមក្នុងសេដ្ឋកិច្ចមាត្រដ្ឋាន និងចែករំលែកថ្លៃដើមទាក់ទងនឹងវគ្គបណ្តុះបណ្តាល ការគ្រប់គ្រងគុណភាព ព័ត៌មានទីផ្សារ និងទ្រព្យសម្បត្តិដែលប្រើប្រាស់ដើមទុនច្រើន។ ផលប្រយោជន៍មួយទៀតនៃបណ្តុំ ក្នុងករណីខ្លះ គឺការរួមចំណែកនៃសកម្មភាពបែបនេះដើម្បីបង្កើតនូវអត្តសញ្ញាណតំបន់ ឬក៏ស្លាកសញ្ញា ដែលជាញឹកញាប់ទាក់ទងនឹងតំបន់ដទៃទៀតដូចជាទេសចរណ៍ជាដើម (ហ្កាលវេស-ណូហ្កាលស៍ /FAO ឆ្នាំ២០១០)។

វិស័យសាធារណៈអាចគាំទ្របណ្តុំទាំងនេះ ក្នុងវិធីជាច្រើនដែលរួមមានទាំងការវិនិយោគលើធនធានមនុស្សតាមរយៈការអប់រំ និងបណ្តុះបណ្តាល លើកកម្ពស់កិច្ចសហការក្នុងចំណោមក្រុមហ៊ុន ពង្រឹងវិទ្យាស្ថានស្រាវជ្រាវដែលអាចអនុវត្តជាក់ស្តែងបាន និងអនុម័យគោលនយោបាយដែលអំណោយផលដល់ឧស្សាហកម្ម។ ប្រអប់ទី២បានបង្ហាញឧទាហរណ៍នៃការធ្វើបែបនេះ ដោយលើកយកករណីនៃបណ្តុំកសិ-ឧស្សាហកម្មនៅអាមេរិកឡាទីន។

(ប្រភព៖ ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៦)

---

[១១] *បណ្តុំកសិ-ឧស្សាហកម្ម ជាការប្រមូលផ្តុំនៃអ្នកផលិតឬកសិករ កសិ-ឧស្សាហកម្ម អ្នកជំនួញ និងតួអង្គវិស័យសាធារណៈ និងឯកជនផ្សេងទៀត ដែលស្ថិតក្នុងឧស្សាហកម្មដូចគ្នា មកភ្ជាប់ទំនាក់ទំនងនឹងគ្នា និងកសាងបណ្តាញច្រវាក់តម្លៃ ទោះជាលក្ខណៈផ្លូវការឬក្រៅផ្លូវការក៏ដោយ ដើម្បីដោះស្រាយបញ្ហាប្រឈមរួមគ្នា និងស្វែងរកឱកាសដូចគ្នា* (FAO ឆ្នាំ២០១០)។

### ប្រអប់ទី២. ការគាំទ្ររបស់វិស័យសាធារណៈលើបណ្តុំ៖ ឧទាហរណ៍ពីអាមេរិកឡាទីន

បណ្តុំជាធម្មតាមិនមែនលេចឡើងដោយឯកឯងនោះទេ ប៉ុន្តែលេចរូបរាងឡើងតាមរយៈកិច្ចប្រឹងប្រែងរបស់អង្គភាពមួយចំនួន ដូចជា រដ្ឋាភិបាល ក្រុមហ៊ុនក្នុងស្រុកខ្នាតធំ ការវិនិយោគផ្ទាល់ពីបរទេស និងសកលវិទ្យាល័យ ដែលជារឿយៗធ្វើការចុះសម្រុងគ្នា។ ក្នុងករណីភាគច្រើនបំផុត បណ្តុំរងឥទ្ធិពលពីកិច្ចសហការរវាងសាធារណៈ-ឯកជន។ ឧទាហរណ៍ បណ្តុំផ្កានៅអេក្វាទ័រ បណ្តុំចេកនៅសាន់តា ខាតារីណា ប្រេហ្ស៊ីល ជាលទ្ធផលនៃការសហការរវាងក្រុមការងារសាធារណៈជាមួយនឹងក្រុមហ៊ុនឈានមុខផ្សេងៗ។ ក្នុងករណីខ្លះ វិស័យឯកជនបានដើរតួនាទីជាអ្នកចាប់ផ្តើម ហើយរដ្ឋាភិបាលគ្រាន់តែចូលមកក្នុងដំណាក់កាលក្រោយមកទៀតប៉ុណ្ណោះ ដូចក្នុងករណីរបស់បណ្តុំត្រសក់ស្រូវ Rio Grande do Norte នៅប្រេហ្ស៊ីល (ហ្គាលវេស-ណូហ្គាលស៍/FAO ឆ្នាំ២០១០)។ បណ្តុំត្រីសាល់ម៉ុនក្លាស្សេ ក៏បង្ហាញនូវឧទាហរណ៍ដែលរដ្ឋាភិបាលដើរតួគាំទ្រដ៏ល្អផងដែរ។ បណ្តុំទាំងនោះ ត្រូវបានគេដឹងថាបានកែប្រែឈីលី ដែលពីមុនគឺជាអ្នកដើរតួតូចតាចមួយក្នុងឧស្សាហកម្មត្រីសាល់ម៉ុន ក្លាយទៅជាអ្នកផលិតធំជាងគេលំដាប់ទី២នៅលើពិភពលោក។ ក្នុងករណីនេះ រដ្ឋាភិបាលបានផ្តល់ជំនួយតាមរយៈការកសាងទំនុកចិត្ត និងសម្របសម្រួលសកម្មភាពរួមក្នុងចំណោមតួអង្គផ្សេងៗក្នុងឧស្សាហកម្មនេះ។ រដ្ឋាភិបាលក៏បានផ្តល់មូលនិធិ និងកិច្ចសហការក្នុងកិច្ចប្រឹងប្រែងរចនាកម្មវិធី និងការស្រាវជ្រាវ ដើម្បីយកឈ្នះនូវបញ្ហាប្រឈមផ្សេងៗជាច្រើនទាក់ទងនឹងការធ្វើឱ្យល្អប្រសើរឡើង។ ក្នុងករណីខ្លះ ដូចជាបណ្តុំស្រាក្រហមឈីលី និងអាហ្សង់ទីន ការគាំទ្ររបស់រដ្ឋាភិបាលមិនមានការរារែកនោះទេ។ ក្នុងករណីទាំងពីរ រដ្ឋាភិបាលដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យផលិតផល និងការនាំចេញទំពាំងបាយជូរ និងស្រាក្រហមមានភាពប្រសើរឡើង និងបង្កើតឱ្យមានទីផ្សារសហគមន៍កសិកម្ម និងកិច្ចប្រឹងប្រែងលើកកម្ពស់ការនាំចេញ។ វិស័យសាធារណៈនៅឈីលី ក៏បានគាំទ្រដល់ការស្រូបយកបច្ចេកវិជ្ជា ជាពិសេសពីក្រុមអ្នកផលិតតូចៗ ខណៈដែលនៅអាហ្សង់ទីន រដ្ឋាភិបាលលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន និងអភិបាលកិច្ចបែបចូលរួម ដែលឱ្យវិស័យឯកជនចូលរួមក្នុងការតាមដានទៅវិញទៅមក។ ប៉ុន្តែ ឧទាហរណ៍ដែលរដ្ឋាភិបាលបង្កើតបណ្តុំតែម្នាក់ឯងដោយគ្មានអ្វីសោះ គឺកម្រឃើញណាស់ បណ្តុំស្វាយ Brazilian Petrolina-Juazeiro និងទំពាំងបាយជូរ គឺជាបណ្តុំពិសេសជាងគេក្នុងលក្ខខណ្ឌបែបនេះ។ នេះដោយសារតែបណ្តុំត្រូវតែផ្អែកលើការជាម្ចាស់ទីតាំងរួមគ្នារវាងតួអង្គ និងទំនាក់ទំនងទាំងផ្លូវការនិងមិនផ្លូវការរវាងពួកគេ ដែលជាធាតុផ្សំដែលកើតឡើងដោយឯកឯង បើទោះបីជាក្រោយមកមានការជំរុញក៏ដោយ។

## ឧបសម្ព័ន្ធទី៥÷ ថ្នាលបណ្តុះកសិធុរកិច្ច

ថ្នាលបណ្តុះកសិធុរកិច្ចឬកម្មវិធីកាតាលិកម្មកសិធុរកិច្ច ត្រូវបានបង្កើតឡើងអំឡុង១៥ទៅ២០ឆ្នាំកន្លងមកនេះ ដើម្បីជំរុញការធ្វើពាណិជ្ជូបនីយកម្មកសិកម្ម និងប្រែក្លាយឧត្តមភាពប្រៀបធៀបនៅក្នុងទីផ្សារវត្ថុធាតុដើម ឱ្យទៅជាឧត្តមភាពប្រកួតប្រជែងនៅក្នុងទីផ្សារផលិតផលប្លែកៗពីគ្នា (ហ្វូលេទី/ធនាគារពិភពលោក ឆ្នាំ២០១១)។ គេអាចកត់សម្គាល់ក្រុមហ៊ុនកាតាលិករកសិធុរកិច្ចបាន នៅត្រង់ថាវាជួយជ្រោមជ្រែងដោយផ្ទាល់ដល់សហគ្រាសបើកថ្មី ឱ្យមានការរីកចម្រើនល្អគលាស់ តាមរយៈការផ្តល់ប្រឹក្សានិងសេវាកម្មអភិវឌ្ឍន៍ធុរកិច្ច ដែលអនុញ្ញាតឱ្យសហគ្រាសទាំងនោះបង្កើនឧត្តមភាពសេដ្ឋកិច្ចនិងពង្រីកទីផ្សាររបស់ខ្លួនបាន។ ប្រអប់ទី៣នឹងពិពណ៌នានិងផ្តល់ឧទាហរណ៍ អំពីប្រភេទនិងតួនាទីរបស់ក្រុមហ៊ុនកាតាលិករកសិធុរកិច្ច។

មានជម្រើសច្រើនយ៉ាងសម្រាប់រដ្ឋាភិបាល ក្នុងការចូលរួមអភិវឌ្ឍថ្នាលកសិធុរកិច្ច ដែលអាចអនុញ្ញាតឱ្យក្រុមហ៊ុនកាតាលិករមានស្វ័យភាពខាងហិរញ្ញវត្ថុនិងនយោបាយក្នុងកម្រិតផ្សេងៗគ្នា។ កាតាលិករធុរកិច្ចជាច្រើន គឺជាស្ថាប័នមិនរកប្រាក់ចំណេញ ហើយកើតឡើងដោយការជ្រោមជ្រែងពីវិស័យសាធារណៈ និងពីប្រភពមូលនិធិខាងក្រៅផ្សេងទៀតដែលក្រុមហ៊ុនទាំងនោះពឹងអាស្រ័យអំឡុងរយៈពេលណាមួយ។ ជាទូទៅ ចំណូលរបស់ក្រុមហ៊ុនកាតាលិករមានប្រភពពីការផ្តល់សេវាកម្មនិងទីតាំងការិយាល័យ ជាអាទិ៍ ថ្លៃសេវាកម្មប្រឹក្សា អភិវឌ្ឍន៍ធុរកិច្ច កិច្ចទីផ្សារ ការសុំប្រើពាណិជ្ជនាមឬប្រៀនឆាយស៍ ឈ្នួលទីតាំង និងថ្លៃសេវាឯទៀត។ ចំណូលនេះអាចគ្រាន់តែទប់ទល់សម្រាប់ចំណាយប្រតិបត្តិការរបស់ក្រុមហ៊ុនកាតាលិករប៉ុណ្ណោះ។ នៅពេលខ្លះ ក្រុមហ៊ុនកាតាលិករមួយចំនួនក៏បានចូលរួមវិនិយោគផងដែរ ទៅលើសហគ្រាសដែលខ្លួនជួយជ្រោមជ្រែង ឬទៅលើកម្មសិទ្ធិបញ្ញារបស់ខ្លួន ដើម្បីកៀងគរចំណូលនិងកម្រៃសួយសារ។

(ប្រភព÷ ធនាគារពិភពលោក ខែមេសា ឆ្នាំ២០១៦)

## ប្រអប់ទី៣. ប្រភេទ និងឧទាហរណ៍នៃក្រុមហ៊ុនកាតាលិករកសិធុរកិច្ច (agribusiness incubators)

ក្រុមហ៊ុនកាតាលិករខ្លះបានផ្តោតលើការពន្លឿនការធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជា ឬការផ្ទេរបច្ចេកវិជ្ជា។ បណ្តាក្រុមហ៊ុនដែលធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជា ជាធម្មតាតីមានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័នស្រាវជ្រាវកសិកម្ម ហើយភាគច្រើនត្រូវបានបង្កើតឡើងដោយស្ថាប័នទាំងនោះតែម្តង។ ជាឧទាហរណ៍ គេឃើញមានដូចជា÷ ក្រុមហ៊ុនកាតាលិករកសិពាណិជ្ជកម្មធំជាងគេនៅឥណ្ឌា (ICRISAT-affiliated Agribusiness Incubator) ក្រុមហ៊ុន IAA-IPB ដែលចងសម្ព័ន្ធជាមួយសាកលវិទ្យាល័យកសិកម្មបូហ្គោ (Bogor Agriculture University) នៃប្រទេសឥណ្ឌូនេស៊ី និងក្រុមហ៊ុនកាតាលិករធុរកិច្ចខាងបច្ចេកវិជ្ជា (CENTEV) ដែលចងសម្ព័ន្ធជាមួយសាកលវិទ្យាល័យសហព័ន្ធនៃវីកូសា (Federal University of Viscosa) ជាដើម។ ថ្វីបើទំនាក់ទំនងរបស់គេទៅនឹងការស្រាវជ្រាវ គឺមួយផ្នែកគឺជាភាពខ្លាំងរបស់ក្រុមហ៊ុនបណ្តុះបណ្តាលទាំងនេះ ដោយសារតែពួកគេមានលទ្ធភាពពិសេសក្នុងការទទួលបាន និងស្វែងយល់ពីការស្រាវជ្រាវថ្មីៗបំផុត ប៉ុន្តែក៏មានហានិភ័យជាក់លាក់ផងដែរ។ ឧទាហរណ៍នៃក្រុមហ៊ុនបណ្តុះបណ្តាលដែលផ្តោតលើការផ្ទេរបច្ចេកវិជ្ជា ក្នុងកម្រិតមូលដ្ឋាន គឺ Villgro នៅប្រទេសឥណ្ឌា និងក្នុងកម្រិតបច្ចេកវិជ្ជាខ្ពស់គឺ មូលនិធិមូលធនវិទ្យាសាស្ត្រជីវិតម៉ាឡេស៊ី (Malaysia Life Sciences Capital Fund)។ Villgro ពន្លឿនការស្រូបយកបច្ចេកវិជ្ជាជនជាតិដើម ដោយសកម្មភាពដែលទាក់ទងនឹងការបង្កើត និងការចែករំលែកចំណេះដឹង ការប្រកួតប្រជែង និងផ្តល់រង្វាន់ អន្តរការីរវាងអ្នកច្នៃប្រឌិត និងសហគ្រិន និងលក់រាយជាពិសេស ក្នុងកម្រិតភូមិ។ សកម្មភាពទាំងនេះ មានគោលបំណងកសាងភាពជឿជាក់ និងបណ្តាញនៅក្នុងទីជនបទ។ MLSCF ដែលជាមូលនិធិគាំទ្រការផ្សងព្រេងសាធារណៈ និងឯកជន គឺផ្តោតលើការនាំចូលបច្ចេកវិជ្ជាដែលអាចយកមកច្នៃតម្រូវសម្រាប់ឧស្សាហកម្មដូងប្រេងក្នុងប្រទេស។ ក្រុមហ៊ុនបណ្តុះបណ្តាល ទាក់ទងនឹងការផ្ទេរបច្ចេកវិជ្ជាឆ្លងកាត់ព្រំដែន និងឆ្លងសាជីវកម្មក្នុងវិធីជាច្រើន រួមទាំងទីផ្សារកម្មសិទ្ធិបញ្ញា កិច្ចសន្យាផលិតកម្ម និងក្រុមហ៊ុនចម្រុះ។ ក្រុមហ៊ុនបណ្តុះបណ្តាលខ្លះ មិនមែនធ្វើលើតែជំនួញបច្ចេកវិជ្ជានោះទេ តែក៏ផ្តល់នូវសេវាកម្មគាំទ្រផ្សេងៗទៀតផងដែរ។ Timbali Industrial Incubator នៅអាហ្វ្រិកខាងត្បូង ផ្តោតលើការប្រមូលផលផ្កា និង Fundacion Jalisco នៅម៉ិកស៊ិក ផ្តោលលើការវេចខ្ចប់ផ្លែប៊ីរីស្រស់ គឺជាឧទាហរណ៍នៃក្រុមហ៊ុនបណ្តុះបណ្តាលដែលមានជំនាញក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃ ក៏ដូចជាធ្វើឱ្យកសិករខ្នាតតូចអាចចូលទៅកាន់ទីផ្សារផងដែរ។ ក្រុមហ៊ុនទាំងពីរនេះ បានអភិវឌ្ឍគំរូអាជីវកម្មក្នុងកម្រិតកសិដ្ឋានដែលអ្នកផលិតខ្នាតតូចជាច្រើនអាចប្រើប្រាស់បាន រួមជាមួយនឹងសេវាកម្មគាំទ្រកម្រិតកសិដ្ឋាន និងខ្សែច្រវាក់ផ្គត់ផ្គង់ (ជាក់ស្តែងដូចជា ការកំណត់គ្រាប់ពូជថ្មី វិធីសាស្ត្រកាត់ និងបច្ចេកវិជ្ជាមើលថែ ទីផ្សារ វេចខ្ចប់ ការបំពេញតាមការបញ្ជាទិញ ឡូជីស្ទិក ការគ្រប់គ្រងទុន)។ ក្រុមហ៊ុនទាំងនេះជួយឱ្យអ្នកផលិតដែលមិនសូវហ៊ានប្រថុយ សមត្ថភាពតិចតួច និងទ្រព្យសម្បត្តិតិចតួច អាចចូលទៅទីផ្សារតម្លៃខ្ពស់ ប្រភេទទីផ្សារដែលអ្នកផលិតទាំងនេះមិនអាចចូលទៅបានដោយខ្លួនឯង ឬក៏សូម្បី តែតាមរយៈអង្គការកសិករ។ Timbali ជាពិសេស ជ្រើសរើស និងបណ្តុះបណ្តាលសហគ្រិនជាស្ត្រីស្បែកខ្មៅ ដើម្បីទទួលហ្វ្រេនឆាយស៍ពីពួកគេ។ អង្គភាពទាំងពីរបានបង្កើនសមត្ថភាព និងទំនាក់ទំនងផ្ទៃក្នុងដើម្បីធ្វើការ ឬក៏រកក្រុមហ៊ុនខាងក្រៅដើម្បី ស្រាវជ្រាវ និងតេស្តផលិតផលមុនពេលសម្ពោធ។

### ប្រអប់ទី៣. ប្រភេទ និងឧទាហរណ៍នៃក្រុមហ៊ុនកាតាលិករកសិធុរកិច្ច (agribusiness incubators)

ក្រុមហ៊ុនកាតាលិករខ្លះបានផ្តោតលើការពន្លឿនការធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជា ឬការផ្ទេរបច្ចេកវិជ្ជា។ បណ្តាក្រុមហ៊ុនដែលធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជា ជាធម្មតាគឺមានទំនាក់ទំនងជិតស្និទ្ធជាមួយស្ថាប័នស្រាវជ្រាវកសិកម្ម ហើយភាគច្រើនត្រូវបានបង្កើតឡើងដោយស្ថាប័នទាំងនោះតែម្តង។ ជាឧទាហរណ៍ គេឃើញមានដូចជា៖ ក្រុមហ៊ុនកាតាលិករកសិពាណិជ្ជកម្មធំជាងគេនៅឥណ្ឌា (ICRISAT-affiliated Agribusiness Incubator) ក្រុមហ៊ុន IAA-IPB ដែលចងសម្ព័ន្ធជាមួយសាកលវិទ្យាល័យកសិកម្មបូហ្គោ (Bogor Agriculture University) នៃប្រទេសឥណ្ឌូនេស៊ី និងក្រុមហ៊ុនកាតាលិករធុរកិច្ចខាងបច្ចេកវិជ្ជា (CENTEV) ដែលចងសម្ព័ន្ធជាមួយសាកលវិទ្យាល័យសហព័ន្ធនៃវីកូសា (Federal University of Viscosa) ជាដើម។ ថ្វីបើទំនាក់ទំនងរបស់គេទៅនឹងការស្រាវជ្រាវ គឺមួយផ្នែកគឺជាភាពខ្លាំងរបស់ក្រុមហ៊ុនបណ្តុះបណ្តាលទាំងនេះ ដោយសារតែពួកគេមានលទ្ធភាពពិសេសក្នុងការទទួលបាន និងស្វែងយល់ពីការស្រាវជ្រាវថ្មីៗបំផុត ប៉ុន្តែក៏មានហានិភ័យជាក់លាក់ផងដែរ។ ឧទាហរណ៍នៃក្រុមហ៊ុនបណ្តុះបណ្តាលដែលផ្តោតលើការផ្ទេរបច្ចេកវិជ្ជា ក្នុងកម្រិតមូលដ្ឋាន គឺ Villgro នៅប្រទេសឥណ្ឌា និងក្នុងកម្រិតបច្ចេកវិជ្ជាខ្ពស់គឺ មូលនិធិមូលធនវិទ្យាសាស្ត្រជីវិតម៉ាឡេស៊ី (Malaysia Life Sciences Capital Fund)។ Villgro ពន្លឿនការស្រូបយកបច្ចេកវិជ្ជាជនជាតិដើម ដោយសកម្មភាពដែលទាក់ទងនឹងការបង្កើត និងការចែករំលែកចំណេះដឹង ការប្រកួតប្រជែង និងផ្តល់រង្វាន់ អន្តរការីរវាងអ្នកច្នៃប្រឌិត និងសហគ្រិន និងលក់រាយជាពិសេស ក្នុងកម្រិតភូមិ។ សកម្មភាពទាំងនេះ មានគោលបំណងកសាងភាពជឿជាក់ និងបណ្តាញនៅក្នុងទីជនបទ។ MLSCF ដែលជាមូលនិធិគាំទ្រការផ្សងព្រេងសាធារណៈ និងឯកជន គឺផ្តោតលើការនាំចូលបច្ចេកវិជ្ជាដែលអាចយកមកច្នៃតម្រូវសម្រាប់ឧស្សាហកម្មដូងប្រេងក្នុងប្រទេស។ ក្រុមហ៊ុនបណ្តុះបណ្តាល ទាក់ទងនឹងការផ្ទេរបច្ចេកវិជ្ជាឆ្លងកាត់ព្រំដែន និងឆ្លងសាជីវកម្មក្នុងវិធីជាច្រើន រួមទាំងទីផ្សារកម្មសិទ្ធិបញ្ញា កិច្ចសន្យាផលិតកម្ម និងក្រុមហ៊ុនចម្រុះ។ ក្រុមហ៊ុនបណ្តុះបណ្តាលខ្លះ មិនមែនធ្វើលើតែជំនួញបច្ចេកវិជ្ជានោះទេ តែក៏ផ្តល់នូវសេវាកម្មគាំទ្រផ្សេងៗទៀតផងដែរ។ Timbali Industrial Incubator នៅអាហ្វ្រិកខាងត្បូង ផ្តោតលើការប្រមូលផលផ្កា និង Fundacion Jalisco នៅម៉ិកស៊ិក ផ្តោលលើការវេចខ្ចប់ផ្លែប៊ឺរីស្រស់ គឺជាឧទាហរណ៍នៃក្រុមហ៊ុនបណ្តុះបណ្តាលដែលមានជំនាញក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃ ក៏ដូចជាធ្វើឱ្យកសិករខ្នាតតូចអាចចូលទៅកាន់ទីផ្សារផងដែរ។ ក្រុមហ៊ុនទាំងពីរនេះ បានអភិវឌ្ឍគំរូអាជីវកម្មក្នុងកម្រិតកសិដ្ឋានដែលអ្នកផលិតខ្នាតតូចជាច្រើនអាចប្រើប្រាស់បាន រួមជាមួយនឹងសេវាកម្មគាំទ្រកម្រិតកសិដ្ឋាន និងខ្សែច្រវាក់ផ្គត់ផ្គង់ (ជាក់ស្តែងដូចជា ការកំណត់គ្រាប់ពូជថ្មី វិធីសាស្ត្រកាត់ និងបច្ចេកវិជ្ជាមើលថែ ទីផ្សារ វេចខ្ចប់ ការបំពេញតាមការបញ្ជាទិញ ឡូជីស្ទិក ការគ្រប់គ្រងទុន)។ ក្រុមហ៊ុនទាំងនេះជួយឱ្យអ្នកផលិតដែលមិនសូវហ៊ានប្រថុយ សមត្ថភាពតិចតួច និងទ្រព្យសម្បត្តិតិចតួច អាចចូលទៅទីផ្សារតម្លៃខ្ពស់ ប្រភេទទីផ្សារដែលអ្នកផលិតទាំងនេះមិនអាចចូលទៅបានដោយខ្លួនឯង ឬក៏សូម្បី តែតាមរយៈអង្គការកសិករ។ Timbali ជាពិសេស ជ្រើសរើស និងបណ្តុះបណ្តាលសហគ្រិនជាស្ត្រីស្បែកខ្មៅ ដើម្បីទទួលហ្វ្រែនឆាយស៍ពីពួកគេ។ អង្គភាពទាំងពីរបានបង្កើនសមត្ថភាព និងទំនាក់ទំនងផ្ទៃក្នុងដើម្បីធ្វើការ ឬក៏រកក្រុមហ៊ុនខាងក្រៅដើម្បី ស្រាវជ្រាវ និងតេស្តផលិតផលមុនពេលសម្ពោធ។

## ឧបសម្ព័ន្ធទី៦៖ ការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងកសិពាណិជ្ជកម្ម

តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់កសិពាណិជ្ជកម្ម ត្រូវបានកំណត់ក្នុងលិខិតុបករណ៍ច្បាប់មួយចំនួនរបស់រាជរដ្ឋាភិបាល។ ខាងក្រោមនេះ ជាសម្រង់នៃបទប្បញ្ញត្តិច្បាប់ដែលកំណត់ពីមុខងារ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេស នាយកដ្ឋានកសិ-ឧស្សាហកម្ម ស្តីពីវិស័យដែលទាក់ទងនឹងសកម្មភាពកសិពាណិជ្ជកម្ម/កសិ-ឧស្សាហកម្ម។

មាត្រា ១៤ នៃអនុក្រឹត្យលេខ ១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឆ្នាំ២០០០) ចែងក្នុងន័យទូលាយអំពីតួនាទីរបស់នាយកដ្ឋានកសិ-ឧស្សាហកម្ម។ មាត្រានេះចែងថានាយកដ្ឋានកសិ-ឧស្សាហកម្មមានដូចជា៖

- រៀបចំនយោបាយ ផែនការ កម្មវិធី គម្រោង និងវិធានការអភិវឌ្ឍដំណាំកសិ-ឧស្សាហកម្ម
- ចូលរួមដោះស្រាយរាល់បញ្ហាដែលទាក់ទងដល់ការអភិវឌ្ឍសហគ្រាសផ្នែកឧស្សាហកម្ម កសិកម្ម និងម្ហូបអាហារ
- ចូលរួមក្នុងការធ្វើទស្សនាទាន និងបំផុសនយោបាយលើកកម្ពស់ដល់សហគ្រាសកសិ-ឧស្សាហកម្ម និងកសិម្ហូបអាហារ
- ចូលរួមក្នុងការជំរុញ និងលើកកម្ពស់ការវិនិយោគ ការនាំចេញផលិតផលកសិកម្ម និងម្ហូបអាហារ
- ផ្សព្វផ្សាយព័ត៌មានបច្ចេកវិជ្ជា សេដ្ឋកិច្ចកសិកម្មដល់អង្គការកសិករ និងដៃគូខាងឧស្សាហកម្ម និងខាងពាណិជ្ជកម្ម ដោយសហការជាមួយស្ថាប័នសាធារណៈឯកទេស និងអង្គការកសិករ និង
- ទទួលភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

ចំណុចនេះបញ្ជាក់ថា នាយកដ្ឋានកសិ-ឧស្សាហកម្មត្រូវបានបង្កើតឡើងជាគោលដើម្បីផ្តល់ដំណើរការគាំទ្រ និងការប្រឹក្សាយោបល់ផ្នែកគោលនយោបាយ និងបច្ចេកទេស (ដូចជា គោលនយោបាយ កម្មវិធី គម្រោង និងការបង្កើតទស្សនទាន និងការចែកចាយព័ត៌មាន) ដែលគាំទ្រការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម។

ជារួម តួនាទី និងការទទួលខុសត្រូវពាក់ព័ន្ធនឹងកសិពាណិជ្ជកម្ម គឺសកម្មភាពកសិកម្ម និងការកែច្នៃបឋមក្នុងប្រព័ន្ធកសិម្ហូបអាហារ។ មាត្រា ១១ ដល់ មាត្រា ១៣ នៃសេចក្តីប្រកាសអន្តរក្រសួងលេខ ៨៦៨ (ឆ្នាំ២០១០) បានកំណត់ជាក់លាក់នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងសកម្មភាពផលិតកម្មដំបូង និងការកែច្នៃបឋម។ យោងតាមប្រកាសនេះ សកម្មភាពកែច្នៃបឋម សំដៅដល់ដំណើរការសាមញ្ញៗ ដូចជា ការកិន ការសម្អាត ការបកសម្បក ការចិតយកសម្បកចេញ ការហាន់ ការបោកបែន និងរោយ ការពិឃាតសត្វ ការពន្លាត់ស្បែក ការហាលសម្ងួត ការយកឆ្អឹងចេញ និងការផ្អាប់ដែលពុំផ្លាស់ប្តូរទម្រង់ធម្មជាតិនៃផលិតផលកសិកម្មពេកទេ។ បន្ថែមពីលើនោះ ប្រកាសនេះបានកំណត់ថា ការកែច្នៃបឋមពុំត្រូវរាប់បញ្ចូលការកែច្នៃទាំងឡាយ ដែលអនុវត្តនៅក្នុងរោងចក្រធុនតូច មធ្យម ធំ និងសិប្បកម្មនោះទេ។

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

*បាវចនា៖ បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ*

| ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម) | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប (ថ្លៃឆ្នាំ២០១៩) |
|---|---|---|---|---|---|
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 541,000.0 | 556,000.0 | 556,000.0 | 441,000.0 | 2,094,000.0 |
| ***១.១. អនុកម្មវិធីកសាងនិងអភិវឌ្ឍន៍សមត្ថភាព*** | *60,000.0* | *260,000.0* | *210,000.0* | *210,000.0* | *740,000.0* |
| ***១.១.១. គម្រោងកសាងនិងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | *30,000.0* | *180,000.0* | *130,000.0* | *130,000.0* | *470,000.0* |
| **សកម្មភាព 111a៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |
| **សកម្មភាព 111b៖** កសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 5,000.0 | 60,000.0 | 60,000.0 | 60,000.0 | 185,000.0 |
| ចំនួនមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល | 5.0 | 60.0 | 60.0 | 60.0 | 185.0 |
| **សកម្មភាព 111c៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ | - | 50,000.0 | - | - | 50,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | - | 1.0 | - | - | 1.0 |
| **សកម្មភាព 111d៖** កសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ ដើម្បីបង្កើនការចូលរួមនៅក្នុងសកម្មភាពកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនស្ត្រីដែលទទួលបានការបណ្តុះបណ្តាល | - | 20.0 | 20.0 | 20.0 | 60.0 |
| **សកម្មភាព 111e៖** លើកកម្ពស់ការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលការណ៍ ក្របខ័ណ្ឌ និងគោលនយោបាយទាក់ទងនឹងកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនសិក្ខាសាលាដែលបានរៀបចំ | - | 4.0 | 4.0 | 4.0 | 12.0 |
| **សកម្មភាព 111f៖** សម្របសម្រួលនិងគាំទ្រការបង្កើតក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម | - | 30,000.0 | 30,000.0 | 30,000.0 | 90,000.0 |
| ចំនួនក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្មដែលបានបង្កើត | - | 6.0 | 6.0 | 6.0 | 18.0 |
| ***១.១.២. គម្រោងអភិវឌ្ឍន៍ជំនាញវិភាគនិងត្រួតពិនិត្យលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | *30,000.0* | *80,000.0* | *80,000.0* | *80,000.0* | *270,000.0* |
| **សកម្មភាព 112a៖** ធ្វើការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការវិភាគនិងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្មនិងចំណីអាហារ | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |

នាយកដ្ឋានកសិ-ឧស្សាហកម្ម ត្រូវតែសកម្មនៅពេលអនុវត្តទាក់ទងនឹងកសិពាណិជ្ជកម្ម/កសិ-ឧស្សាហកម្ម បើមិនដូច្នេះទេផែនការ និងលទ្ធផលសម្រេចបានរបស់នាយកដ្ឋាននេះ ក្នុងការបង្កើនផលិតភាពកសិកម្ម ពង្រីកផលិតផលកសិកម្ម និងពិពិធកម្មកសិកម្ម នឹងមិនអាចផ្តល់អត្ថប្រយោជន៍បែបយុទ្ធសាស្ត្រសម្រាប់សេដ្ឋកិច្ច និងប្រទេសជាតិនោះទេ នៅពេលដែលការសម្របសម្រួលក្នុងចំណោមស្ថាប័នផ្សេងៗ ពុំសូវកើតមាននោះ។ ដោយមូលហេតុនេះ *រាជរដ្ឋាភិបាល (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ប្រហែលជាត្រូវពិនិត្យឡើងវិញនូវលិខិតុបករណ៍ច្បាប់ និងក្របខ័ណ្ឌដែលកំណត់តួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋានកសិ-ឧស្សាហកម្មសម្រាប់ការអភិវឌ្ឍកសិពាណិជ្ជកម្ម/កសិ-ឧស្សាហកម្ម។*

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឧបសម្ព័ន្ធទី៧៖ ម៉ាទ្រីសនៃផែនការយុទ្ធសាស្ត្រ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ

## នាយកដ្ឋានកសិ-ឧស្សាហកម្ម


គាំទ្រដោយ៖

គម្រោងកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ

ខែមេសា ឆ្នាំ២០១៩

ជំនាញការបច្ចេកទេសដោយ៖ លោក ស្រី ចន្ទី និងលោក ឃិន ពិសី

## មាតិកានៃសន្លឹកកិច្ចការ / CONTENTS OF THE SPREADSHEETS

| | Contents | មាតិកា | ឈ្មោះសន្លឹកកិច្ចការ<br>Worksheet name |
|---|---|---|---|
| 0 | Cover | ទំព័រមុខ | COVER |
| 0 | Contents | មាតិកា | Contents |
| | | | BLANK1 |
| 1 | AI4.0 Results Matrix | តារាងលទ្ធផល | Results |
| 2 | AI4.0 Program Summary Matrix | តារាងសង្ខេបកម្មវិធី | All Programs |
| 3 | AI4.0 Project Summary Matrix | តារាងសង្ខេបគម្រោង | All Projects |
| 4 | AI4.0 Implementation Arrangement | ការរៀបចំការអនុវត្ត | Arrangement |
| | | | BLANK2 |
| 5 | Projects of Program 1 in Stage 1 | បញ្ជីគម្រោងនៃកម្មវិធីទី១នៃដំណាក់កាលទី១ | S1P1 |
| 6 | Projects of Program 2 in Stage 1 | បញ្ជីគម្រោងនៃកម្មវិធីទី២នៃដំណាក់កាលទី១ | S1P2 |
| 7 | Projects of Program 3 in Stage 1 | បញ្ជីគម្រោងនៃកម្មវិធីទី៣នៃដំណាក់កាលទី១ | S1P3 |
| 8 | Notes to Projects and/or Sub-projects of Stage 1 | កំណត់សម្គាល់ផ្សេងៗនៃដំណាក់កាលទី១ | S1Notes |
| | | | BLANK3 |
| 9 | Projects of Program 1 in Stage 2 | បញ្ជីគម្រោងនៃកម្មវិធីទី១នៃដំណាក់កាលទី២ | S2P1 |
| 10 | Projects of Program 2 in Stage 2 | បញ្ជីគម្រោងនៃកម្មវិធីទី២នៃដំណាក់កាលទី២ | S2P2 |
| 11 | Projects of Program 3 in Stage 2 | បញ្ជីគម្រោងនៃកម្មវិធីទី៣នៃដំណាក់កាលទី២ | S2P3 |
| 12 | Notes to Projects and/or Sub-projects of Stage 2 | កំណត់សម្គាល់ផ្សេងៗនៃដំណាក់កាលទី២ | S2Notes |
| | | | BLANK4 |
| 13 | Projects of Program 1 in Stage 3 | បញ្ជីគម្រោងនៃកម្មវិធីទី១នៃដំណាក់កាលទី៣ | S3P1 |
| 14 | Projects of Program 2 in Stage 3 | បញ្ជីគម្រោងនៃកម្មវិធីទី២នៃដំណាក់កាលទី៣ | S3P2 |
| 15 | Projects of Program 3 in Stage 3 | បញ្ជីគម្រោងនៃកម្មវិធីទី៣នៃដំណាក់កាលទី៣ | S3P3 |
| 16 | Notes to Projects and/or Sub-projects of Stage 3 | កំណត់សម្គាល់ផ្សេងៗនៃដំណាក់កាលទី៣ | S3Notes |
| 17 | Select costing information | ព័ត៌មានគ្រឹះនៃការប៉ាន់ស្មានថវិកា | Costing |
| 18 | Budgetary gap | គម្លាតថវិកា | Gap |

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

*ជាវចនា៖ បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ*

ចក្ខុវិស័យ៖ នៅត្រឹមឆ្នាំ២០៣០ ប្រទេសកម្ពុជានឹងមានកសិ-ឧស្សាហកម្មបែបទំនើបកម្មមួយ ដែលមានឧត្តមភាពសេដ្ឋកិច្ចខ្ពស់ មានលក្ខណៈបរិយាប័ន្ន មានភាពរឹងមាំ និងប្រកបដោយចីរភាព។

| | កម្រិត | សេចក្ដីបរិយាយ | សូចនាករ | ទិន្នន័យ/របាយការណ៍ | ហានិភ័យ |
|---|---|---|---|---|---|
| | អតិផល | ចក្ខុវិស័យ | | | |
| ^^^^^ | | នៅត្រឹមឆ្នាំ២០៣០ ប្រទេសកម្ពុជានឹងមានកសិ-ឧស្សាហកម្មបែបទំនើបកម្មមួយ ដែល មានឧត្តមភាព សេដ្ឋកិច្ចខ្ពស់ មានលក្ខណៈបរិយាប័ន្ន មានភាពរឹងមាំ។ | ផ.ស.ស ក្នុងម្នាក់<br>ចំនួនការងារក្នុងកសិ-ឧស្សាហកម្ម បែងចែកតាមយេនឌ័រ | . គណនេយ្យជាតិ<br>. ជំរឿនសេដ្ឋកិច្ច | នយោបាយអន្តរជាតិ |
| | សមិទ្ធផល | គោលបំណង | | | |
| ^^^^^^^^^^^ | | បង្កើនការនាំចេញផលិតផលកែច្នៃកសិកម្ម (រាប់ទាំងផលិតផលកែច្នៃថ្មីៗ) ឱ្យបានស្មើនឹង ១២% នៃការនាំចេញសរុបនៅឆ្នាំ២០២៥ (គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម) និង ១៥% នៃការនាំចេញសរុបនៅឆ្នាំ២០៣០។ (ការសម្រេចគោលបំណងនេះនឹងចូលរួមចំណែក ដល់ការសម្រេចគោលបំណងរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យកម្ពុជាក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ២០៥០) | អនុបាតនៃការនាំចេញកសិ-ឧស្សាហផលធៀបនឹងការនាំចេញសរុប (បែងចែកតាមមុខផលិតផល) | . គណនេយ្យជាតិ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ | ដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក |
| | លទ្ធផល | គោលដៅយុទ្ធសាស្ត្រ | | | |
| ^^^^^ | | ជំរុញការកែច្នៃនិងបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ដែលឆ្លើយតបនឹងតម្រូវការទីផ្សារ ប្រកបដោយគុណភាពនិងសុវត្ថិភាព | - តម្លៃបន្ថែមដុល(GVA)នៃវិស័យក្រៅពីស្រូវ បែងចែកតាមអនុវិស័យ<br>- តម្លៃបន្ថែមនៃកសិ-ឧស្សាហកម្ម (រាប់ទាំងកិនស្រូវ) បែងចែកតាមអនុវិស័យ | . ក.ស.ក/នា.ផែនការនិងស្ថិតិ<br>. វិទ្យាស្ថានជាតិស្ថិតិ<br>. អង្កេតកម្លាំងពលកម្ម | កត្តាបម្រែបម្រួលអាកាសធាតុ |
| ^^^ | | បង្កើតការងារនៅជនបទ ដែលប្រកបដោយគុណភាពនិងបរិយាប័ន្ន | ប្រាក់ឈ្នួលក្នុងកសិ-ឧស្សាហកម្ម (បែងចែកតាមយេនឌ័រ) | . គណនេយ្យជាតិ<br>. អង្កេតកម្លាំងពលកម្ម | កង្វះជំនាញឌីជីថល និងភាសាអង់គ្លេស |
| | សកម្មភាព | សកម្មភាពយុទ្ធសាស្ត្រ | | | |

| | | | |
|---|---|---|---|
| ***ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម)*** | | | |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | . ចំនួនភាគីពាក់ព័ន្ធដែលបានពង្រឹងសមត្ថភាព<br>. ចំនួនលិខិតុបករណ៍ដែលបានដាក់ចេញ ដើម្បីឆ្លើយតបនឹងតម្រូវការ<br>. កម្រិតប្រសើរឡើងនៃសមត្ថភាពធានាគុណភាពនិងសុវត្ថិភាពចំណីអាហារ | | |
| ២. កម្មវិធីផ្ទេរបច្ចេកវិទ្យា និងគ្រប់គ្រងចំណេះដឹង | . ស្ថានភាពដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន(MIS)និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង(KMS)ដោយប្រើបច្ចេកវិទ្យាឌីជីថល<br>. កម្រិតប្រសើរឡើងនៃដំណើរការគ្រប់គ្រងកសិ-ឧស្សាហកម្ម<br>. អត្រាកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងនវានុវត្តន៍នៅក្នុងកសិ-ឧស្សាហកម្ម | . របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនៃផែនការយុទ្ធសាស្ត្រ | . ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>. ជំនួយបច្ចេកទេសគ្រប់គ្រាន់ |
| ៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | . ចំនួនមុខកសិ-ឧស្សាហផល ដែលបានអភិវឌ្ឍ ផលិត លក់ក្នុងទីផ្សារក្នុងស្រុក និងនាំចេញ<br>. ចំនួនមុខកសិ-ឧស្សាហផលដែលបាននាំចេញ | | |
| ***ដំណាក់កាលទី២៖ ការធ្វើពិពិធកម្ម និងបំប្លែងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៣-២០២៦(ដំណាក់កាលផ្លាស់ប្តូរនៃការកសិ-ឧស្សាហកម្ម)*** | | | |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | . ចំនួនភាគីពាក់ព័ន្ធដែលបានពង្រឹងសមត្ថភាព<br>. ចំនួនលិខិតុបករណ៍ដែលបានដាក់ចេញ ដើម្បីឆ្លើយតបនឹងតម្រូវការ<br>. កម្រិតប្រសើរឡើងនៃសមត្ថភាពធានាគុណភាពនិងសុវត្ថិភាពចំណីអាហារ | | |
| ២. កម្មវិធីអភិវឌ្ឍន៍បច្ចេកវិទ្យា និងគ្រប់គ្រងចំណេះដឹង | . ស្ថានភាពដំណើរការនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន(MIS)និងប្រព័ន្ធគ្រប់គ្រងចំណេះដឹង(KMS)ដោយប្រើបច្ចេកវិទ្យាឌីជីថល<br>. កម្រិតប្រសើរឡើងនៃដំណើរការគ្រប់គ្រងកសិ-ឧស្សាហកម្ម<br>. អត្រាកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងនវានុវត្តន៍នៅក្នុងកសិ-ឧស្សាហកម្ម | . របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ<br>. របាយការណ៍តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនៃផែនការយុទ្ធសាស្ត្រ | . ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់<br>. ជំនួយបច្ចេកទេសគ្រប់គ្រាន់ |

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

*ចក្ខុវិស័យ ៖ បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ*

| ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម) | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប (ថ្លៃឆ្នាំ២០១៩) |
|---|---|---|---|---|---|
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 541,000.0 | 556,000.0 | 556,000.0 | 441,000.0 | 2,094,000.0 |
| ***១.១. អនុកម្មវិធីកសាងនិងអភិវឌ្ឍន៍សមត្ថភាព*** | ***60,000.0*** | ***260,000.0*** | ***210,000.0*** | ***210,000.0*** | ***740,000.0*** |
| ***១.១.១. គម្រោងកសាងនិងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | ***30,000.0*** | ***180,000.0*** | ***130,000.0*** | ***130,000.0*** | ***470,000.0*** |
| **សកម្មភាព 111a៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |
| **សកម្មភាព 111b៖** កសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 5,000.0 | 60,000.0 | 60,000.0 | 60,000.0 | 185,000.0 |
| ចំនួនមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល | 5.0 | 60.0 | 60.0 | 60.0 | 185.0 |
| **សកម្មភាព 111c៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ | - | 50,000.0 | - | - | 50,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | - | 1.0 | - | - | 1.0 |
| **សកម្មភាព 111d៖** កសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ ដើម្បីបង្កើនការចូលរួមនៅក្នុងសកម្មភាពកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនស្ត្រីដែលទទួលបានការបណ្តុះបណ្តាល | - | 20.0 | 20.0 | 20.0 | 60.0 |
| **សកម្មភាព 111e៖** លើកកម្ពស់ការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលការណ៍ ក្របខ័ណ្ឌ និងគោលនយោបាយទាក់ទងនឹងកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនសិក្ខាសាលាដែលបានរៀបចំ | - | 4.0 | 4.0 | 4.0 | 12.0 |
| **សកម្មភាព 111f៖** សម្របសម្រួលនិងគាំទ្រការបង្កើតក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម | - | 30,000.0 | 30,000.0 | 30,000.0 | 90,000.0 |
| ចំនួនក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្មដែលបានបង្កើត | - | 6.0 | 6.0 | 6.0 | 18.0 |
| ***១.១.២. គម្រោងអភិវឌ្ឍន៍ជំនាញវិភាគនិងត្រួតពិនិត្យលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | ***30,000.0*** | ***80,000.0*** | ***80,000.0*** | ***80,000.0*** | ***270,000.0*** |
| **សកម្មភាព 112a៖** ធ្វើការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការវិភាគនិងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្មនិងចំណីអាហារ | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |

## ការរៀបចំការអនុវត្ត

កសិ-ឧស្សាហកម្មមានភាពទាក់ទងជាលក្ខណៈអន្តរវិស័យ។ ហេតុនេះ ក្រសួង-ស្ថាប័នរដ្ឋជាច្រើនមានការពាក់ព័ន្ធ ក៏ប៉ុន្តែត្រូវស្ថិតតែក្នុងតួនាទី ទំនួលខុសត្រូវ និងដែនសមត្ថកិច្ចរបស់ខ្លួន ដែលត្រូវបានកំណត់ក្នុងក្របខ័ណ្ឌច្បាប់ប៉ុណ្ណោះ។ តួអង្គសំខាន់ៗមានដូចជា៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងពាណិជ្ជកម្ម និងក្រសួងទេសចរណ៍។ យោងតាមក្របខ័ណ្ឌច្បាប់ តួអង្គទាំងនេះត្រូវសហការគ្នាយ៉ាងស្អិតរមួតក្នុងការបំពេញនូវតួនាទី មុខងារ និងទំនួលខុសត្រូវនីមួយៗរបស់ខ្លួន ពោលពុំអាចធ្វើការដាច់ដោយឡែកពីគ្នានោះឡើយ ដើម្បីអភិវឌ្ឍកសិ-ឧស្សាហកម្មឱ្យបានជោគជ័យ។

ក្នុងន័យនេះ ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០ ឱ្យបានសម្រេច នាយកដ្ឋានកសិ-ឧស្សាហកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបំពេញការងារ៖ (១)អនុវត្តនូវរាល់សកម្មភាពដែលស្ថិតក្នុងដែនសមត្ថកិច្ចផ្ទាល់របស់ខ្លួន ដូចមានចែងក្នុងបញ្ញត្តិនៃក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធ (២)សម្របសម្រួលនិងផ្តល់កិច្ចគាំទ្រដល់នាយកដ្ឋានផ្សេងទៀតនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការអនុវត្តសកម្មភាពដែលស្ថិតក្នុងដែនសមត្ថកិច្ចនីមួយៗរបស់នាយកដ្ឋានទាំងនោះ និង(៣)ចរចានិងពិភាក្សាជាមួយក្រសួង-ស្ថាប័នផ្សេងទៀត សំដៅជំរុញការអនុវត្តសកម្មភាពដែលស្ថិតក្នុងដែនសមត្ថកិច្ចនីមួយៗរបស់ក្រសួង-ស្ថាប័នទាំងនោះ។

ជារួម នាយកដ្ឋានកសិ-ឧស្សាហកម្មមានតួនាទីច្រើន នៅក្នុងដំណើរការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០ គឺរាប់បញ្ចូលទាំង៖ ដឹកនាំ សម្របសម្រួល(ទាំងក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួង-ស្ថាប័នផ្សេងទៀត) និងផ្តល់កិច្ចគាំទ្រ។

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

*បាវចនា៖ បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ*

| ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម) | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប (ថ្លៃឆ្នាំ២០១៩) |
|---|---|---|---|---|---|
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 541,000.0 | 556,000.0 | 556,000.0 | 441,000.0 | 2,094,000.0 |
| ***១.១. អនុកម្មវិធីកសាងនិងអភិវឌ្ឍន៍សមត្ថភាព*** | ***60,000.0*** | ***260,000.0*** | ***210,000.0*** | ***210,000.0*** | ***740,000.0*** |
| ***១.១.១. គម្រោងកសាងនិងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | ***30,000.0*** | ***180,000.0*** | ***130,000.0*** | ***130,000.0*** | ***470,000.0*** |
| **សកម្មភាព 111a៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |
| **សកម្មភាព 111b៖** កសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 5,000.0 | 60,000.0 | 60,000.0 | 60,000.0 | 185,000.0 |
| ចំនួនមន្ត្រីដែលទទួលបានការបណ្តុះបណ្តាល | 5.0 | 60.0 | 60.0 | 60.0 | 185.0 |
| **សកម្មភាព 111c៖** សិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ | - | 50,000.0 | - | - | 50,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | - | 1.0 | - | - | 1.0 |
| **សកម្មភាព 111d៖** កសាងសមត្ថភាពរបស់ស្ត្រី ទាក់ទងនឹងការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពចំណីអាហារ ដើម្បីបង្កើនការចូលរួមនៅក្នុងសកម្មភាពកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនស្ត្រីដែលទទួលបានការបណ្តុះបណ្តាល | - | 20.0 | 20.0 | 20.0 | 60.0 |
| **សកម្មភាព 111e៖** លើកកម្ពស់ការបញ្ជ្រាបយេនឌ័រ ទៅក្នុងគោលការណ៍ ក្របខ័ណ្ឌ និងគោលនយោបាយទាក់ទងនឹងកសិ-ឧស្សាហកម្ម | - | 20,000.0 | 20,000.0 | 20,000.0 | 60,000.0 |
| ចំនួនសិក្ខាសាលាដែលបានរៀបចំ | - | 4.0 | 4.0 | 4.0 | 12.0 |
| **សកម្មភាព 111f៖** សម្របសម្រួលនិងគាំទ្រការបង្កើតក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្ម | - | 30,000.0 | 30,000.0 | 30,000.0 | 90,000.0 |
| ចំនួនក្រុមស្ត្រីអភិវឌ្ឍន៍កសិ-ឧស្សាហកម្មដែលបានបង្កើត | - | 6.0 | 6.0 | 6.0 | 18.0 |
| ***១.១.២. គម្រោងអភិវឌ្ឍន៍ជំនាញវិភាគនិងត្រួតពិនិត្យលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ*** | ***30,000.0*** | ***80,000.0*** | ***80,000.0*** | ***80,000.0*** | ***270,000.0*** |
| **សកម្មភាព 112a៖** ធ្វើការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការលើការកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទាក់ទងនឹងការវិភាគនិងការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពផលិតផលកសិកម្មនិងចំណីអាហារ | 25,000.0 | - | - | - | 25,000.0 |
| ចំនួនការសិក្សាអំពីការប៉ាន់ប្រមាណតម្រូវការ | 1.0 | - | - | - | 1.0 |

| | | | | | |
|---|---|---|---|---|---|
| ២.១. អនុកម្មវិធីផ្ទេរនិងគ្រប់គ្រងចំណេះដឹង | 587,000.0 | ២.១. អនុកម្មវិធីពង្រឹងការគ្រប់គ្រងចំណេះដឹង | 601,000.0 | ២.១. អនុកម្មវិធីស្រាវជ្រាវមូលដ្ឋាននិងផ្ទេរបច្ចេកវិជ្ជា | 648,000.0 |
| ២.១.១. គម្រោងអភិវឌ្ឍន៍និងគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 472,000.0 | ២.១.១. គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 496,000.0 | ២.១.១. គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 496,000.0 |
| ២.១.២. គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | 115,000.0 | ២.១.២. គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | 105,000.0 | ២.១.២. គម្រោងអភិវឌ្ឍន៍និងអនុវត្តប្រព័ន្ធឌីជីថលលើផលិតកម្មកសិកម្មតាមកិច្ចសន្យា | 152,000.0 |
| ២.២. អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្តន៍និងផ្ទេរបច្ចេកវិជ្ជា | 570,000.0 | ២.២. អនុកម្មវិធីអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជា | 440,000.0 | ២.២. អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្តន៍និងផ្ទេរបច្ចេកវិជ្ជា | 660,000.0 |
| ២.២.១. គម្រោងស្រាវជ្រាវកម្រិតអនុវត្តន៍អំពីកសិ-ឧស្សាហកម្ម | 420,000.0 | ២.២.១. គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 260,000.0 | ២.២.១. គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 320,000.0 |
| ២.២.២. គម្រោងអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 150,000.0 | ២.២.២. គម្រោងអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 180,000.0 | ២.២.២. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍដំណើរនិងបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 340,000.0 |
| ៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | 9,451,400.0 | ៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពង្រីកពាណិជ្ជកម្ម | 9,385,100.0 | ៣. កម្មវិធីនវានុវត្តន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម | 8,868,000.0 |
| ៣.១. អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | 2,272,400.0 | ៣.១. អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | 2,145,600.0 | ៣.១. អនុកម្មវិធីនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | 2,220,000.0 |
| ៣.១.១. គម្រោងពង្រឹងគុណភាពផលិតផល | 1,090,000.0 | ៣.១.១. គម្រោងធានាគុណភាពផលិតផល | 1,160,000.0 | ៣.១.១. គម្រោងធានាគុណភាពកសិ-ឧស្សាហផល | 1,160,000.0 |
| ៣.១.២. គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | 1,182,400.0 | ៣.១.២. គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | 985,600.0 | ៣.១.២. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | 1,060,000.0 |
| ៣.២. អនុកម្មវិធីអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្ម | 6,367,000.0 | ៣.២. អនុកម្មវិធីពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្ម | 6,142,500.0 | ៣.២. អនុកម្មវិធីបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្ម | 5,456,000.0 |
| ៣.២.១. គម្រោងអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | 648,500.0 | ៣.២.១. គម្រោងពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | 472,000.0 | ៣.២.១. គម្រោងបង្កើតឡើងវិញនូវតំបន់កិស-ឧស្សាហកម្មភាគពាយ័ព្យ | 432,000.0 |
| ៣.២.២. គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 648,500.0 | ៣.២.២. គម្រោងពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 472,000.0 | ៣.២.២. គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 432,000.0 |
| ៣.២.៣. គម្រោងបង្កើតវេទិកាជួបផ្តើមកសិធុរកិច្ច | 5,070,000.0 | ៣.២.៣. គម្រោងសំយោគវេទិកាជួបផ្តើមកសិធុរកិច្ច | 4,550,000.0 | ៣.២.៣. គម្រោងបង្កើតឡើងវិញនូវវេទិការជួបផ្តើមកសិធុរកិច្ច | 4,160,000.0 |
| | | ៣.២.៤. គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | 648,500.0 | ៣.២.៤. គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | 432,000.0 |
| ៣.៣. អនុកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 812,000.0 | ៣.៣. អនុកម្មវិធីពង្រីកនិងសំយោគពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 1,097,000.0 | ៣.៣. អនុកម្មវិធីនវានុវត្តន៍លើពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 1,192,000.0 |
| ៣.៣.១. គម្រោងអភិវឌ្ឍន៍ទីផ្សារក្នុងស្រុក | 315,000.0 | ៣.៣.១. គម្រោងពង្រីកនិងសំយោគទីផ្សារក្នុងស្រុក | 460,000.0 | ៣.៣.១. គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារក្នុងស្រុក | 460,000.0 |
| ៣.៣.២. គម្រោងអភិវឌ្ឍទីផ្សារអន្តរជាតិ | 497,000.0 | ៣.៣.២. គម្រោងពង្រីកនិងសំយោគទីផ្សារអន្តរជាតិ | 637,000.0 | ៣.៣.២. គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារអន្តរជាតិ | 732,000.0 |

| | | | | | |
|---|---|---|---|---|---|
| ២.១. អនុកម្មវិធីផ្ទេរនិងគ្រប់គ្រងចំណេះដឹង | 587,000.0 | ២.១. អនុកម្មវិធីពង្រឹងការគ្រប់គ្រងចំណេះដឹង | 601,000.0 | ២.១. អនុកម្មវិធីស្រាវជ្រាវមូលដ្ឋាននិងផ្ទេរបច្ចេកវិជ្ជា | 648,000.0 |
| ២.១.១. គម្រោងអភិវឌ្ឍន៍និងគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 472,000.0 | ២.១.១. គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 496,000.0 | ២.១.១. គម្រោងពង្រឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យកសិ-ឧស្សាហកម្ម | 496,000.0 |
| ២.១.២. គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | 115,000.0 | ២.១.២. គម្រោងផ្ទេរចំណេះដឹងអំពីផលិតកម្មកសិកម្មតាមកិច្ចសន្យា | 105,000.0 | ២.១.២. គម្រោងអភិវឌ្ឍន៍និងអនុវត្តប្រព័ន្ធឌីជីថលលើផលិតកម្មកសិកម្មតាមកិច្ចសន្យា | 152,000.0 |
| ២.២. អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្តន៍និងផ្ទេរបច្ចេកវិជ្ជា | 570,000.0 | ២.២. អនុកម្មវិធីអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជា | 440,000.0 | ២.២. អនុកម្មវិធីស្រាវជ្រាវកម្រិតអនុវត្តន៍និងផ្ទេរបច្ចេកវិជ្ជា | 660,000.0 |
| ២.២.១. គម្រោងស្រាវជ្រាវកម្រិតអនុវត្តន៍អំពីកសិ-ឧស្សាហកម្ម | 420,000.0 | ២.២.១. គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 260,000.0 | ២.២.១. គម្រោងធ្វើពាណិជ្ជូបនីយកម្មបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 320,000.0 |
| ២.២.២. គម្រោងអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 150,000.0 | ២.២.២. គម្រោងអភិវឌ្ឍន៍និងផ្ទេរបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 180,000.0 | ២.២.២. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍដំណើរនិងបច្ចេកវិជ្ជាកសិ-ឧស្សាហកម្ម | 340,000.0 |
| **៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម** | **9,451,400.0** | **៣. កម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផលនិងពង្រីកពាណិជ្ជកម្ម** | **9,385,100.0** | **៣. កម្មវិធីនវានុវត្តន៍កសិ-ឧស្សាហផលនិងពាណិជ្ជកម្ម** | **8,868,000.0** |
| ៣.១. អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | 2,272,400.0 | ៣.១. អនុកម្មវិធីអភិវឌ្ឍន៍កសិ-ឧស្សាហផល | 2,145,600.0 | ៣.១. អនុកម្មវិធីនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | 2,220,000.0 |
| ៣.១.១. គម្រោងពង្រឹងគុណភាពផលិតផល | 1,090,000.0 | ៣.១.១. គម្រោងធានាគុណភាពផលិតផល | 1,160,000.0 | ៣.១.១. គម្រោងធានាគុណភាពកសិ-ឧស្សាហផល | 1,160,000.0 |
| ៣.១.២. គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | 1,182,400.0 | ៣.១.២. គម្រោងអភិវឌ្ឍន៍ផលិតផលថ្មី | 985,600.0 | ៣.១.២. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍកសិ-ឧស្សាហផល | 1,060,000.0 |
| ៣.២. អនុកម្មវិធីអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្ម | 6,367,000.0 | ៣.២. អនុកម្មវិធីពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្ម | 6,142,500.0 | ៣.២. អនុកម្មវិធីបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្ម | 5,456,000.0 |
| ៣.២.១. គម្រោងអភិវឌ្ឍតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | 648,500.0 | ៣.២.១. គម្រោងពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្មភាគពាយ័ព្យ | 472,000.0 | ៣.២.១. គម្រោងបង្កើតឡើងវិញនូវតំបន់កិស-ឧស្សាហកម្មភាគពាយ័ព្យ | 432,000.0 |
| ៣.២.២. គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 648,500.0 | ៣.២.២. គម្រោងពង្រីកនិងសំយោគតំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 472,000.0 | ៣.២.២. គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគបូព៌ា | 432,000.0 |
| ៣.២.៣. គម្រោងបង្កើតវេទិកាផ្តួចផ្តើមកសិធុរកិច្ច | 5,070,000.0 | ៣.២.៣. គម្រោងសំយោគវេទិកាផ្តួចផ្តើមកសិធុរកិច្ច | 4,550,000.0 | ៣.២.៣. គម្រោងបង្កើតឡើងវិញនូវវេទិកាផ្តួចផ្តើមកសិធុរកិច្ច | 4,160,000.0 |
| | | ៣.២.៤. គម្រោងអភិវឌ្ឍន៍តំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | 648,500.0 | ៣.២.៤. គម្រោងបង្កើតឡើងវិញនូវតំបន់កសិ-ឧស្សាហកម្មភាគទក្សិណ | 432,000.0 |
| ៣.៣. អនុកម្មវិធីអភិវឌ្ឍន៍ពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 812,000.0 | ៣.៣. អនុកម្មវិធីពង្រីកនិងសំយោគពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 1,097,000.0 | ៣.៣. អនុកម្មវិធីនវានុវត្តន៍លើពាណិជ្ជកម្មកសិ-ឧស្សាហកម្ម | 1,192,000.0 |
| ៣.៣.១. គម្រោងអភិវឌ្ឍន៍ទីផ្សារក្នុងស្រុក | 315,000.0 | ៣.៣.១. គម្រោងពង្រីកនិងសំយោគទីផ្សារក្នុងស្រុក | 460,000.0 | ៣.៣.១. គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារក្នុងស្រុក | 460,000.0 |
| ៣.៣.២. គម្រោងអភិវឌ្ឍទីផ្សារអន្តរជាតិ | 497,000.0 | ៣.៣.២. គម្រោងពង្រីកនិងសំយោគទីផ្សារអន្តរជាតិ | 637,000.0 | ៣.៣.២. គម្រោងនវានុវត្តន៍ និងបង្កើតឡើងវិញនូវទីផ្សារអន្តរជាតិ | 732,000.0 |

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិ-ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៩-២០៣០

***ចក្ខុវិស័យ៖ បង្កើតឱកាសសម្រាប់កសិផលកែច្នៃដែលអាចប្រកួតប្រជែងលើទីផ្សារ***

| ថវិកាសរុប (ដុល្លារ) | 37,932,504.00 |
|---|---|

| ដំណាក់កាល/កម្មវិធី/អនុកម្មវិធី/គម្រោង | ថវិកា (ដុល្លារ) |
|---|---|
| ដំណាក់កាលទី១៖ ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មកសិ-ឧស្សាហកម្ម ឆ្នាំ២០១៩-២០២២ (ដំណាក់កាលពង្រឹងកសិ-ឧស្សាហកម្ម) | 12,702,400.0 |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ន និងភាគីពាក់ព័ន្ធ | 2,094,000.0 |
| ១.១. អនុកម្មវិធីកសាងនិងអភិវឌ្ឍន៍សមត្ថភាព | 740,000.0 |
| ១.១.១. គម្រោងកសាងនិងអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ | 470,000.0 |
| ១.១.២. គម្រោងអភិវឌ្ឍន៍ជំនាញវិភាគនិងត្រួតពិនិត្យលើស្តង់ដារគុណភាព និងសុវត្ថិភាពចំណីអាហារ | 270,000.0 |
| ១.២. អនុកម្មវិធីអភិវឌ្ឍន៍និងពង្រឹងសមត្ថភាពស្ថាប័ន | 1,354,000.0 |
| ១.២.១. គម្រោងពង្រឹងស្ថាប័ននិងអភិវឌ្ឍន៍ក្របខណ្ឌច្បាប់និងក្របខណ្ឌគោលនយោបាយ | 291,000.0 |
| ១.២.២. គម្រោងពង្រឹងសមត្ថភាពនាយកដ្ឋានកសិ-ឧស្សាហកម្ម | 513,000.0 |
| ១.២.៣. គម្រោងអភិវឌ្ឍន៍មន្ទីរពិសោធន៍ | 550,000.0 |
| ២. កម្មវិធីផ្ទេរបច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | 1,157,000.0 |

>

| ដំណាក់កាល/កម្មវិធី/អនុកម្មវិធី/គម្រោង | ថវិកា (ដុល្លារ) |
|---|---|
| ដំណាក់កាលទី២៖ ការធ្វើពិពិធកម្ម និងបំប្លែងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៣-២០២៦ (ដំណាក់កាលវឌ្ឍនាការកសិ-ឧស្សាហកម្ម) | 12,810,104.0 |
| ១. កម្មវិធីកសាងនិងពង្រឹងសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 2,384,004.0 |
| ១.១. អនុកម្មវិធីសំយោគសមត្ថភាព | 840,000.0 |
| ១.១.១. គម្រោងពង្រឹងជំនាញការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) ការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) និងស្តង់ដារគុណភាពនិងសុវត្ថិភាពចំណីអាហារ | 520,000.0 |
| ១.១.២. គម្រោងពង្រឹងជំនាញស្តង់ដារគុណភាពនិងសុវត្ថិភាពចំណីអាហារ និងការវិភាគនិងត្រួតពិនិត្យគុណភាពចំណីអាហារ | 320,000.0 |
| ១.២. អនុកម្មវិធីពង្រឹងស្ថាប័ន | 1,544,004.0 |
| ១.២.១. គម្រោងសំយោគក្របខណ្ឌច្បាប់និងគោលនយោបាយ និងស្ថាប័ន | 96,000.0 |
| ១.២.២. គម្រោងពង្រឹងមុខងារនាយកដ្ឋានកសិ-ឧស្សាហកម្ម | 498,000.0 |
| ១.២.៣. គម្រោងពង្រឹងប្រតិបត្តិការមន្ទីរពិសោធន៍ | 950,004.0 |
| ២. កម្មវិធីអភិវឌ្ឍន៍បច្ចេកវិជ្ជា និងគ្រប់គ្រងចំណេះដឹង | 1,041,000.0 |

>

| ដំណាក់កាល/កម្មវិធី/អនុកម្មវិធី/គម្រោង | ថវិកា (ដុល្លារ) |
|---|---|
| ដំណាក់កាលទី៣៖ ការច្នៃប្រឌិតនិងការបង្កើតថ្មីក្នុងកសិ-ឧស្សាហកម្ម ឆ្នាំ២០២៧-២០៣០ (ដំណាក់កាលនវានុវត្តន៍កសិ-ឧស្សាហកម្ម) | 12,420,000.0 |
| ១. កម្មវិធីនវានុវត្តលើសមត្ថភាពរបស់ស្ថាប័ននិងភាគីពាក់ព័ន្ធ | 2,244,000.0 |
| ១.១. អនុកម្មវិធីអភិវឌ្ឍន៍ជំនាញនិងទេពកោសល្យបង្កើតថ្មីនិងនវានុវត្ត | 1,000,000.0 |
| ១.១.១. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍជំនាញនិងទេពកោសល្យខាងស្តង់ដារ នៃគុណភាពនិងសុវត្ថិភាពចំណីអាហារ ការអនុវត្តការគ្រប់គ្រងល្អ(GMP) ការអនុវត្តអនាម័យល្អ(GHP) និងការអនុវត្តចំណុចត្រួតពិនិត្យសំខាន់នៃការវិភាគគ្រោះថ្នាក់(HACCP) | 595,000.0 |
| ១.១.២. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍជំនាញនិងទេពកោសល្យ ខាងការវិភាគនិងការត្រួតពិនិត្យគុណភាពចំណីអាហារ | 405,000.0 |
| ១.២. អនុកម្មវិធីបង្កើតឡើងវិញនិងនវានុវត្តន៍ស្ថាប័ន | 1,244,000.0 |
| ១.២.១. គម្រោងនវានុវត្តន៍លើការអភិវឌ្ឍក្របខណ្ឌច្បាប់និងក្របខណ្ឌគោលនយោបាយ | 336,000.0 |
